n° 4-5-6
R le 19-11-52
« Mitsalapâli »
INDOCHINE FRANÇAISE RÉG. DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



Avril - Mai - Juin n° 4-5-6

ឆ្នាំទី ៣ មេសា ឧសភា មិថុនា លេខ ៤.៥.៦

ព.ស. ២៤៩៥ — គ.ស. ១៩៥២

ទស្សនាវដ្ដីអនុមាស

ផ្សាយព្រះពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ចាប - ពិន

ទីសំណាក់ការ លេខ ៣៥ អា. វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

# បញ្ជីរឿង


| រឿង | | ទំព័រ |
| --- | --- | --- |
| វិចារណកថា | | ១២១ |
| *ផ្នែកព្រះពុទ្ធសាសនា* | | |
| សេចក្ដីពិសេសនៃព្រះពុទ្ធសាសនា | តែ - ឌុន | ១២៦ |
| សុភាសិត ៥០ បទ | ប៊ូ—ប៉ូ | ១៣៤ |
| និទានប្រារព្ធការគប់ប្រសព្វពាលនឹងបណ្ឌិត | ចាប - ពិន | ១៤១ |
| វឌ្ឍនធម៌ | ព្រះទេពសត្ថា ស្វរ - ហាយ | ១៤៧ |
| *ផ្នែកអក្សរសាស្ត្រ* | | |
| អក្សរសាស្ត្រខ្មែរ | ភ៉ាយ—ប៊ុក | ១៦០ |
| ខេមរវេយ្យាករណ៍ | ព្រះមហា ពេជ្រ—ម៉ាន់ | ១៦៨ |
| អក្សរអង្គុលីលេខ | អៀង—ថ្វាង | ១៨០ |
| ដរីលេខ | សៀង—ឌិន | ១៨៤ |
| ឯកសារស្ដីពីប្រវត្តិសាស្ត្រនៃកម្ពុជរដ្ឋ | ភ៉ាយ—ប៊ុក | ១៩៦ |
| ប្រហែលជាលោក - អ្នកភ្លេចហើយ ឬ | ភ៉ាយ - ប៊ុក | ២០៥ |
| ម្ដាយនឹងកូន | ព្រះមហា ប៊ុង – ប៉ម | ២១១ |
| រឿងសកុន្តលា | ហេង—យ៉ាន់ | ២១៧ |
| បញ្ចតន្ត្រៈ | ភិក្ខុ ប៉ាង—ខាត់ | ២២៤ |
| មហាសន្និបាត | | ២៣០ |
| ពិធីបុណ្យព្រហ្មទាន | | ២៣៤ |

# វិចារណកថា

ព.ស. ២៤៩៤ ឆ្នាំ ១៩៥១ គោចរវិលចប់ចក្រាសី ដល់ពេលចែកឆ្នាំចូលឆ្នាំថ្មីជា ព.ស. ២៤៩៥ ឆ្នាំ ១៩៥២ តទៅតាមប្រពៃណី ទេពតាឆ្នាំចាស់ផ្លាស់វេន លែងគ្រប់គ្រងពិភពលោកតទៅទៀត ។ ក្នុងឆ្នាំចាស់ដែលកន្លងទៅនេះ ជើងមេឃរបស់យើង ត្របាញ់ខ្វល់ខ្វាញ់ ដូចព្រួញ ពពកមីរដេរដាសស្ទើរគ្រប់ទិសកន្ទើញគំរាមយើង សង្គ្រាមសន្ធិញចូលមកយ៉ាងសាហាវហានក្លា, ស្ទើរផ្ទុះ យើងក៏បានព្យាយាមផ្ចាញ់ឧបសគ្គទាំងឡាយដោយឥតរួញរា សមជាពុទ្ធសាសនិកពិតៗ ។ ទស្សនាវដ្ដី "មិត្តសាលាបាលី" ក៏បានប្រឹងប្រែងដោយពេញកំលាំង ដើម្បីបំពេញបេសកកម្មដ៏ថ្លៃថ្លារបស់សមាគមមិត្តសាលាបាលី គឺការណែនាំអ្នកអានទាំងឡាយ ឲ្យបានប្រឡប់ប្រទះតែនឹងសេចក្ដីសុខ សេចក្ដីចំរើន បានពន្យល់ដោយច្បាស់លាស់ពីកិច្ចស្វែងរកសេចក្ដីសុខក្នុងការធ្វើបុណ្យ ហើយបានសារស័ព្ទពណ៌នាអំពីឧបករណ៍ទាំងឡាយ ដែលគប្បីឧបត្ថម្ភគាំទ្រដើម្បីសម្រេចនូវវត្ថុបំណងដ៏ប្រសើរនោះ ។

ឃើញថាយើងកល់គ្នា បរិបូណ៌ដោយគ្រឿងដៃគ្រប់ព្រម ល្មមនឹងប្រព្រឹត្តដំណើរជីវិតក្នុងឆ្នាំថ្មីដោយសុវត្ថិភាព ។ មុននឹងធ្វើដំណើរទៅតាមកម្មវិធីដែលយើងបានរៀបចំហើយ នឹងតាមឧត្ដមគតិដែលយើងបានតាំងទុកជាស្រេចនោះ គួរយើងរំលឹកដល់គោលការណ៍សំខាន់ៗ

ដែលត្រូវបង់ចាំជាមុនសិន ៗ ជាដំបូង យើងត្រូវជឿជាក់ដោយច្បាស់លាស់ថា សេចក្ដីសុខនិងទុក្ខពុំមាននរណាឲ្យយើងទេ គឺខ្លួនយើងជាអ្នកតាក់តែងជោគវាសនារបស់យើង ជាអ្នកសាងឋានសួគ៌ឬឋាននរករបស់យើង យើងធ្វើល្អបានជួបផលល្អ ធ្វើអាក្រក់បានជួបផលអាក្រក់ ៗ បន្ទាប់មក គួរដឹងថា ទុក្ខវេទនា សេចក្ដីក្ដៅក្រហាយទាំងឡាយពុំមែនកើតមានខ្លាំងក្លាតែក្នុងវេលាដែលសង្គ្រាមកំពុងផ្ទុះក្នុងលោកប៉ុណ្ណោះទេ សូម្បីក្នុងលោកសន្តិសុខ ក៏ទុក្ខវេទនា សេចក្ដីក្ដៅក្រហាយទាំងនោះនៅបៀតបៀនញាំញីយើងពេញបន្ទុកដែរ ដោយអំណាចសង្គ្រាមខាងក្នុង គោលគឺកិលេសគ្រប់ចំពូក ៗ ការកៀរគរសម្បត្តិទ្រព្យជាមហាសាល, ការវាតឫទ្ធិអំណាចផ្សាយទូទៅ, ការចំរើនកំលាំងអានុភាពឲ្យវិសេសវិសាលឡើង, ការផ្សាំងឥទ្ធិពលធម្មជាតិយកប្រើប្រាស់តាមសេចក្ដីត្រូវការ, ការកសាងសន្សំកិត្តិយសឲ្យបានធំទូលាយ; ទាំងអស់នេះអាចផ្ចាញ់បានត្រឹមសង្គ្រាមខាងក្រៅប៉ុណ្ណោះ តែពុំបានញុំាងសាមីខ្លួនឲ្យបានទទួលនូវសេចក្ដីសុខដ៏ប្រពៃទេ ព្រោះពុំបានស្ងប់ក្នុងចិត្តដោយការប្រាសចាកសង្គ្រាមខាងក្នុង មានតែចំរើនកំលាំងកិលេសឲ្យហាវហានឡើងទៅវិញ ៗ ក្នុងទីបញ្ចប់ យើងគួរកើតសេចក្ដីជ្រះថ្លាយ៉ាងក្រៃលែងដោយយើងបានជួបប្រទះនឹងព្រះពុទ្ធសាសនា ដែលជាផ្លូវទៅកាន់សន្តិវរបទ (ឧបាយដ៏ស្ងប់ប្រសើរ) ឬសេចក្ដីសុខដ៏ពេញលេញបរិបូណ៌ ព្រោះជាផ្លូវនាំឲ្យ

យកឈ្នះខ្លួនឯងបាន គឺឈ្នះសង្គ្រាមខាងក្នុងដែលជាសេចក្ដីឈ្នះវិសេស លើសសេចក្ដីឈ្នះទាំងពួង ។

ក្នុងលោកដ៏គ្រប់ដណ្ដប់ដោយមោហៈ ដែលកំពុងរេលរល ដោយភ្លើងលោភ មានលោភយសសក្តិ លោភទ្រព្យសម្បត្តិ លោភអានុភាព លោភបុណ្យអំណាចជាដើម ដុតកំដៅចិត្តមនុស្សឲ្យប្រែទូស្តដល់គ្នាទឹងគ្នា រវាងជាតិ រវាងត្រកូល រវាងញាតិមិត្ត ឲ្យឈ្លោះប្រកែកគ្នា ឲ្យកាប់សំឡាប់គ្នា ឲ្យចងពៀរពយាបាទគ្នានេះ, យើងគប្បីកាន់ធម៌សន្ដោសឲ្យបានខ្ជាប់ខ្ជួន ព្រោះធម៌សន្ដោសជាទ្រព្យដ៏ប្រសើរ ជាទឹកដ៏ត្រជាក់អាចរំងាប់ភ្លើងលោភៈបាន តែសូមកុំភ័ន្តច្រឡំថា ធម៌សន្ដោសនេះ ហាមឃាត់យើងមិនឲ្យខំប្រឹងប្រែងធ្វើការងារឲ្យបានចំរើនលូតលាស់ត្រសុំត្រសាយឡើងនោះឡើយ; យើងត្រូវតែខំដើរទៅមុខជាដរាប រហូតដល់ចប់ករណីយកិច្ចបានពេញបរិបូណ៌ មិនគប្បីលះបង់ធុរៈដោយគិតថាអស់ហើយត្រឹមប៉ុណ្ណេះ ត្រឹមប៉ុណ្ណោះ នៅក្រិនតែមួយកន្លែងនោះទេ ។ ប៉ុន្តែការស្វះស្វែងរកនោះគប្បីដើរទៅតាមផ្លូវល្អ គឺឲ្យពេញចិត្តតាមរបស់ដែលមាន ដែលរកបាន ដែលអាចរកបានដោយផ្លូវល្អ ដោយសម្មាអាជីវៈ ឬសម្មាកម្មន្តៈ ជាប្រយោជន៍ផងខ្លួន ដល់ក្រុមគ្រួសារដល់អ្នកដទៃ, មិនស្វះស្វែងឲ្យបានជាប្រយោជន៍ចំពោះតែខ្លួនម្នាក់ឯង ឬចំពោះតែក្រុមគ្រួសាររបស់ខ្លួន ហើយឲ្យវិនាសដល់អ្នក

ផ្ទៃក្នុងកាយក្តី ក្នុងទ្រព្យសម្បត្តិក្តី ក្នុងចិត្តក្តី ក្នុងសិទ្ធិក្តី ក្នុងជីវិតក្តី ព្រោះការប្រព្រឹត្តិបែបនោះឃ្លាងចាកសេចក្តីសុខដោយពិត ចំរើនតែសង្គ្រាមខាងក្រៅនិងខាងក្នុងជានិច្ច ៗ សន្តោសបន្តាប់ឲ្យស្វែងរកសេចក្តីសុខ-ចំរើនជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃទូទៅ ឲ្យគោរពសេចក្តីសុខ គោរពសិទ្ធិនិងជីវិតនៃជនទាំងពួងព្រមទាំងសព្វសត្វផង ៗ

លក្ខណសម្បត្តិសំខាន់នៃការស្វែងរកសេចក្តីសុខ-ចំរើនគឺនិយាយអ្វី គិតអ្វី ធ្វើអ្វី ឲ្យបានប្រយោជន៍រួមទូទៅ ហើយកិច្ចការដែលយើងត្រូវធ្វើ គប្បីធ្វើឲ្យបានល្អហ្មត់ចត់ហើយឲ្យបានវិសេសផង ខំប្រឹងប្រែងឲ្យបានប្រសើរជានិច្ច ឲ្យបានឈ្នះជាដរាប ថ្ងៃនេះឲ្យបានគ្រាន់បើជាងថ្ងៃម្សិល ថ្ងៃស្អែកឲ្យបានប្រសើរជាងថ្ងៃនេះ តែដូច្នេះជារៀងរាល់ ៗ ថ្ងៃទៅ ៗ ដើម្បីឲ្យបានសមដូចបំណងនេះ, យើងគប្បីរៀបចំកិច្ចការរបស់យើង ប្រដាប់ប្រដារបស់យើង ឲ្យមានរបៀបរៀបរយល្អ, របស់នីមួយ ៗ ដាក់ត្រង់កន្លែងដែលត្រូវដាក់, កិច្ចការនីមួយ ៗ ធ្វើនៅពេលដែលត្រូវធ្វើ ហើយគប្បីគោរពដល់ពេលវេលានោះ ដល់ពេលធ្វើកិច្ចការអ្វីគប្បីធ្វើតែកិច្ចការនោះ ដល់ពេលណាត់សន្យា ត្រូវតែដល់ទៅកន្លែងដែលបានកំណត់ទុក ៗ លក្ខណសម្បត្តិមួយទៀតគឺការបេះសំរបខ្លួនទៅតាមកាលៈទេសៈ ហេតុការណ៍ ទីស្ថានការណ៍ ធ្វើខ្លួនឲ្យសមរម្យទៅតាមលក្ខណៈ តាមដំណើររបស់លោក ព្រោះខ្លួនយើងពុំអាចកែប្រែ

លោកទាំងមូល ឲ្យអនុលោមតាមបំណងរបស់យើងបានទេ គប្បីរិះរកហេតុបច្ច័យដើម្បីកែប្រែឧបសគ្គដោយសមហេតុសមផល , យើងយកគោលការណ៍មួយមកតាំងជាផ្លូវដើរ គឺត្រូវកសាងមិនត្រូវទំលាយទេ ។

នៅចំពោះគ្រោះទុព្វលភាពយ៉ាងណាក៏ដោយ យើងមិនត្រូវតាំងចិត្តប្រទូស្តឬអស់កំលាំងប្រឹងប្រែងទេ ត្រូវញញឹមរកជោគអាក្រក់ ញញឹមទាំងមាត់ ញញឹមទាំងមុខមាត់ ញញឹមទាំងភ្នែក ញញឹមទាំងចិត្ត ឯព្រះអាទិត្យនៃឆ្នាំថ្មីដែលរះឡើងនោះ នឹងញញឹមរកយើងយ៉ាងប្រិមប្រិយរីករាយ ព្រោះលោកនេះមិនគឺអ្វីក្រៅពីស្រមោលឬរូបភាពរបស់យើងនោះទេ ។ ដូច្នេះចូរយើងញញឹមទទួលឆ្នាំថ្មី, សេចក្ដីញញឹមនេះនឹងតាមយើងជាប់ជានិច្ចអស់រយៈឆ្នាំនេះ ។

បណ្ណាធិការ

កាលណាឆ្នាំចាស់ ត្រូវធម្មតាផ្លាស់
មកជាឆ្នាំថ្មី, យើងក៏ត្រូវផ្លាស់
ចិត្តចាស់ជាថ្មី ឲ្យកើតសេចក្ដី
ចម្រើនជាងមុន !

ប.ព.

## ម្ហូបអ្វី មិនស្មើម្ហូបព្រះពុទ្ធសាសនា

# សេចក្តីពិសេសនៃព្រះពុទ្ធសាសនា

ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ មាន៨ហ្មឺន៤ពាន់ធម្មក្ខន្ធ ។ បើបំព្រួញឲ្យខ្លីមក មានតែ ២ :–

១.– ទ្រង់ប្រៀនប្រដៅឲ្យកាន់យក :

២.– ទ្រង់ប្រៀនប្រដៅឲ្យលះបង់ ។

កិច្ចដែលទ្រង់ប្រៀនប្រដៅឲ្យកាន់យកនោះ ចំពោះអំពើណាដែលនាំឲ្យកើតសេចក្តីសុខ - ចំរើនក្នុងបច្ចុប្បន្ន និងបរលោក ដូចទ្រង់ប្រៀនប្រដៅឲ្យប្រឹងប្រែងរៀនចំណេះវិជ្ជា, ឲ្យខំធ្វើការងារ, ឲ្យស្វែងរកទ្រព្យ, ឲ្យសង្គ្រោះបុត្តភរិយាព្រមទាំងញាតិ - មិត្ត និងអ្នករួមសង្គមជាដើម ; ដូចទ្រង់ប្រៀនប្រដៅឲ្យធ្វើទាន - សីល - ភាវនា ឬធ្វើសីល - សមាធិ - បញ្ញាឲ្យបានមគ្គផលឡើង ។

កិច្ចដែលទ្រង់ប្រៀនប្រដៅឲ្យលះបង់នោះ ចំពោះអំពើណាដែលនាំឲ្យកើតសេចក្តីទុក្ខក្នុងបច្ចុប្បន្ន និងបរលោក ដូចទ្រង់ប្រៀនប្រដៅឲ្យលះបង់នូវអំពើទុច្ចរិតតាមផ្លូវ កាយ - វាចា - ចិត្ត, ដូចទ្រង់ប្រៀនប្រដៅឲ្យលះបង់នូវអំពើថោកទាបទាំងឡាយនាបច្ចុប្បន្ន, ដូចទ្រង់ប្រៀនប្រដៅ

ឲ្យលះបង់នូវកាមសុខ ទៅកាន់និរាមិសសុខ ដោយការលះបង់នូវវដ្តប្បដិបត្តា ទៅកាន់វិវដ្តប្បដិបត្តា ដោយបហាតតួកិច្ចទាំងឡាយ ដែលទ្រង់ណែនាំឲ្យធ្វើ ។

ហេតុបានជាទ្រង់ប្រៀនប្រដៅសត្វលោកជា ២ ផ្នែកដូច្នេះ ព្រោះទ្រង់ត្រាស់ដឹងថា សត្វលោកតែងប្រាថ្នារកសេចក្តីសុខសេចក្តីចំរើនដូចគ្នាទាំងអស់ ប៉ុន្តែសត្វលោកមិនដឹងថា សេចក្តីសុខដែលខ្លួនត្រូវការនោះមានល្បឿន ឬមានសន្ទុះត្រឹមណា, មានទុក្ខអាចជ្រៀតជ្រែកចូលមកតាមគន្លងនៃសេចក្តីសុខនោះ បានឬមិនបាន ។

លុះទ្រង់ជ្រាបដូច្នេះហើយ ទ្រង់ចែកសេចក្តីទុក្ខជា ២ផ្នែក ទ្រង់ចែកនូវសេចក្តីសុខជា ២ផ្នែក បញ្ជាក់ដល់ពពួកសត្វទាំងឡាយឲ្យបានក្តីច្បាស់ ។

មុនដម្បូងទ្រង់ត្រាស់សំដែងអំពីសេចក្តីទុក្ខ ដែលកើតមកអំពីបាបកម្មដែលសត្វបានកសាង ដូចជាទុក្ខក្នុងអបាយភូមិ ៤ ជាដើម ។

បន្ទាប់មកទ្រង់ត្រាស់សំដែងអំពីសេចក្តីសុខដែលកើតឡើង អំពីបុញ្ញកម្ម ដែលសត្វបានកសាង ដូចជាសុខក្នុងស្ថានមនុស្ស ស្ថានទេវតា ស្ថានព្រហ្មជាដើម ។

សេចក្តីទុក្ខដែលកើតមកអំពីបាបកម្មនោះ ទ្រង់ត្រាស់សំដែងថា សត្វធ្វើបាបកម្មបែបនេះ នឹងសោយទុក្ខបែបនោះ, សត្វធ្វើបាបកម្មបែបនោះ នឹងសោយទុក្ខបែបនេះជាដើម ។

លុះទ្រង់សំដែងអំពីផលនៃបាបកម្មរួចហើយ ទ្រង់ត្រាស់សំដែងអំពីផលនៃបុញ្ញកម្មតទៅទៀត ថាសត្វធ្វើបុញ្ញកម្មបែបនេះនឹងបានសុខបែបនោះ, សត្វធ្វើបុញ្ញកម្មបែបនោះ នឹងបានសុខបែបនេះ ។ មិនតែប៉ុណ្ណោះ ទ្រង់ត្រាស់សំដែងអំពីសេចក្ដីសុខដែលកើតមកអំពីការអប់រំ ក្នុងស្ថានមនុស្សនេះ ដោយអនាមយវិធីផង ដោយវេជ្ជកម្មវិធីផង ដោយបំណេះវិជ្ជានឹងសិល្បៈទាំងឡាយផង ដោយសេចក្ដីស្លូតត្រង់, សេចក្ដីសន្ដោស, សេចក្ដីព្យាយាម, សេចក្ដីវៃឆ្លាសគ្រប់បែបគ្រប់យ៉ាងផង ដែលជាករណីយកិច្ច គឺមនុស្សលោកគប្បីបំពេញក្នុងភារៈនៃខ្លួនជាមនុស្សជាតិ ដែលមិនប្រកបដោយសម្បត្តិទិព្វ ដូចជាស្ថានទេវតា ឬស្ថានព្រហ្ម ។

ឯសេចក្ដីទុក្ខដែលកើតមកអំពីការអប់រំ ក្នុងស្ថានមនុស្សនេះទៀតសោត ក៏ទ្រង់ត្រាស់សំដែងថា កើតមកអំពីការប្រាសចាកអនាមយវិធីនឹងវេជ្ជកម្មវិធីផង អំពីការល្ងង់ខ្លៅឥតបំណេះវិជ្ជានឹងសិល្បៈទាំងឡាយផង អំពីការប្រព្រឹត្តិនូវអំពើយង់ឃ្នងទាំងឡាយ ដែលទំនាស់ដល់គតិលោកផង ដែលទំនាស់ដល់ច្បាប់សម្រាប់លោកផង អំពីសេចក្ដីខ្ជិលច្រអូសក្នុងកិច្ចស្វែងរកផលប្រយោជន៍ផង ។ នេះទ្រង់ប្រៀនប្រដៅឲ្យគាត់យកនឹងឲ្យលះបង់ក្នុងបទទី ១. ។

សេចក្តីទុក្ខនិងសុខទាំង ២ ផ្នែកនេះ ទ្រង់ត្រាស់បញ្ជាក់ដល់សត្វ-លោកទាំងឡាយថា នែ! អ្នកទាំងឡាយ! សេចក្តីទុក្ខនិងសុខទាំង ២ ផ្នែកនេះ ជាវដ្តទុក្ខនិងជាវដ្តសុខទេ ព្រោះថាអំពើនេះ នៅគង់កណ្តាប់ដៃនៃវដ្តៈនៅឡើយ ។ អ្នកទាំងឡាយនៅមានសេចក្តីសោកសង្រេង នៅមានសេចក្តីខ្សឹកខ្សួល, នៅមានសេចក្តីអាក់អន់, នៅមានការមិនសមតាមប្រាថ្នាគឺ មិនចង់បាន ហើយបាន, ចង់បាន ហើយមិនបាន, មិនចង់ជួបប្រទះ ហើយជួបប្រទះ, ចង់ជួបប្រទះ ហើយព្រាសព្រាត់ទៅ, ទុក្ខហើយទុក្ខទៀត, ទុក្ខនឹងកើត, ទុក្ខនឹងចាស់, ទុក្ខនឹងឈឺ, ទុក្ខនឹងស្លាប់ ។ បើដូច្នេះតើ! អ្នកទាំងឡាយនឹងគេចចេញទៅផ្លូវណា ឲ្យផុតទុក្ខទាំងនេះបាន បើគតិទាំង ៣ សុទ្ធសឹងប្រកបដោយទុក្ខយ៉ាងនេះទៅហើយ ។

តថាគតដឹងផ្លូវ . . . . . . . . . . . . . . . . . . . .

១.– ហេតុដែលនាំឲ្យកើតទុក្ខមកអំពីអវិជ្ជា ដែលមានធាតុទាំង៥ គឺបថវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ និងអាកាសធាតុជាមូលដ្ឋាន;

២.– លុះតែរំលត់នូវអវិជ្ជា ដោយកុសលកម្មទាំងឡាយ ដែលបុគ្គលគប្បីធ្វើដោយកាយ - វាចា - ចិត្ត ដែលជាទីលំនៅនៃអវិជ្ជា ព្រោះការឧបត្ថម្ភ នៃធាតុទាំង ៥ នោះ;

៣.– ផ្លូវទីដំណាក់របស់ចិត្ត គឺមគ្គនិងផល ដែលជាគូចិត្តឯងកសាងខ្លួនឯង ចរទៅខ្លួនឯង ឆ្លងវដ្តសង្សារទៅកាន់ព្រះនិព្វាន ដែលជាទីមានតែសុខសុទ្ធ ហើយឥតវិលត្រឡប់មកកាន់សេចក្តីទុក្ខវិញបាន ។

ផ្លូវទាំង ៣ នេះ ផ្លូវទី ១.– ទ្រង់ត្រាស់សំដែងអំពីបដិសន្ធិរបស់សត្វទាំង ៤ គឺ: សត្វដែលកើតអំពីស៊ុត, សត្វដែលកើតអំពីចំហាយទឹកកំញើមធាតុ, សត្វដែលឧបត្តិកកើតឯង, សត្វដែលកើតអំពីគភ៌ ។ កំណើតសត្វទាំង៤ពួកនេះ ត្រង់កំណើត ៣ ខាងដើម មិនមែនសុទ្ធតែសត្វដែលមានបដិសន្ធិចាស់មកកើតទេ ប្រាកដជាមានសត្វដែលមានបដិសន្ធិថ្មីកើតជាមួយផង ព្រោះហេតុនោះ បានជាមានពាក្យថា ព្រះពុទ្ធទាំងអម្បាលខ្សាច់ដែលត្រាស់ដឹងកន្លងទៅហើយ នៅតែដឹកនាំសត្វទៅកាន់ព្រះនិព្វានមិនអស់ មកអំពីសត្វចេះតែកើតថ្មីឡើងទៀត, តែកើតឡើងហើយមានអវិជ្ជាជាប់នៅនឹងសត្វនោះៗ គ្រប់រូបទាំងអស់ ។ អវិជ្ជានេះ ប្រែថា "មិនដឹង", សត្វទាំងឡាយតែងកើតមកអំពីគ្រឿងមិនដឹង ដូចជាធាតុទាំង ៥ ជារបស់មិនដឹង ដល់វេលាផ្គុំប្រមូលកើតឡើងជារូបសត្វៗ នោះ ក៏មានការមិនដឹងជាប់នៅក្នុងខ្លួនជានិច្ច បានសេចក្តីថា "ដឹងនេះ នៅមិនដឹងនោះ, ដឹងត្រង់ណេះ នៅមិនដឹងត្រង់ណោះ, បើទុកជាដឹងយ៉ាងណា ក៏នៅតែមិនអស់ការមិនដឹង ព្រោះតែកើតមកអំពីគ្រឿងមិនដឹង ដូចបានរៀបរាប់មកហើយ ។ ការមិនដឹងនេះ

ចេះតែមិនដឹងហេតុដល់ថ្នាក់ទីបំផុត គឺមិនដឹងថា ខ្លួនកើតមកអំពីអ្វីជាដំបូង, ខ្លួននឹងស្លាប់ទៅជាអ្វីដល់ទីបំផុត, មិនដឹងថា ខ្លួនប្រកបដោយទុក្ខក្នុងសង្សារវដ្ត, មិនដឹងថា ហេតុអ្វីដែលនាំឲ្យកើតទុក្ខ, មិនដឹងថា ធ្វើដូចម្ដេចនឹងរំលត់ទុក្ខនេះបាន, មិនដឹងថា នឹងទៅកាន់ទីណាដែលជាទីផុតទុក្ខ ។ ការមិនដឹងនេះ នាំឲ្យសត្វមានសេចក្ដីប្រាថ្នាតាមចំណង់ដែលខ្លួននឹកឃើញ ដែលខ្លួនត្រូវការ មិនចេះអស់មិនចេះហើយរកទីបំផុតគ្មាន ។

លុះទ្រង់ជ្រាបច្បាស់ដូច្នេះហើយ ទ្រង់ក៏ខំសំដែងអំពីទុក្ខដូចខាងលើឲ្យសត្វដឹងរួចហើយ ទ្រង់សំដែងអំពីហេតុដែលនាំឲ្យកើតទុក្ខ ឲ្យសត្វដឹងតទៅទៀត លុះសត្វបានដឹងនូវហេតុនោះរួចហើយ ទ្រង់សំដែងអំពីការរំលត់នូវហេតុដែលនាំឲ្យកើតទុក្ខនោះតទៅទៀត :-

ផ្លូវទី ២.- ផ្លូវនេះទ្រង់បង្រៀនប្រដៅសត្វឲ្យលះបង់នូវការមិនដឹងនោះចោលចេញដោយបទថា នែ! អ្នកទាំងឡាយ ៗ គប្បីដឹងថា ការកើតឡើងជារូបនេះ អាស្រ័យដោយធាតុទាំង ៥ ជាគ្រឿងឧបត្ថម្ភកង់ខាងដើម កាលដែលធាតុទាំង ៥ កំពុងឧបត្ថម្ភនោះ ហៅថាសង្ខារ លុះសង្ខារគុបតែងបានកើតជាអង្គគ្រប់គ្រាន់ហើយ ក៏កើត ត ៗ គ្នា មកដល់ជាតិ-ជរា-ព្យាធិ-មរណ ដូច្នេះត្រូវអ្នកទាំងឡាយដឹងថា ខ្លួននេះជាធាតុ ធាតុនេះជារបស់បដិកូល, ជារបស់បែកធ្លាយ, ជារបស់មិនទៀង,

ជារបស់ឥតខ្លឹមសារ, ជារបស់នាំឲ្យកើតទុក្ខ ។ លុះពិចារណាដឹងច្បាស់ថាជាតិមានសភាពដូច្នេះហើយ គប្បីដឹងថា អ្វីដែលដឹកនាំជាតិឲ្យមានសភាពដូច្នេះ គឺចិត្តនឹងចេតសិក ដែលធ្វើជាតិឲ្យត្រឡប់ត្រឡិន ម្ដងអ៊ីចេះ ម្ដងអ៊ីចុះ យ៉ាងនេះ ជាចិត្តដ៏លាមក, ជាចិត្តមិនទៀងទាត់, ជាចិត្តនាំឲ្យកើតទុក្ខ ជាចិត្តឥតបានការ ។ ជាតិនឹងចិត្តទាំង ២ នេះ ហៅថាខ្លួន បើខ្លួនមានសភាពដូច្នេះ តើនឹងប្រកាន់ខ្លួនដូចម្ដេចកើត, តើនឹងសង្ស័យអំពីខ្លួនដូចម្ដេចកើត, តើនឹងប្រព្រឹត្តវត្តប្រតិបត្តិដែលនាំឲ្យកើតទុក្ខដូចម្ដេចកើត ។ បើដូច្នេះគួរតែលះបង់នូវរបស់មិនបានការនេះចោលចេញទាំងអស់ ។

ផ្លូវទី ៣.— លុះបានដឹងច្បាស់ដូច្នេះហើយ ចិត្តនោះក៏ក្លាយទៅជាមានក្រៃសប្បុរុះទៅក្នុងលោកុត្តរធម៌ថ្នាក់ទី ១ ហៅថាសោតាបត្តិមគ្គ-ចិត្ត លុះមគ្គចិត្ត ថ្នាក់ទី ១ នេះកើតហើយ ក៏ប្រែទៅជាសោតាបត្តិផលចិត្តមួយរំពេច ហៅថាជាដំណាក់ទី ១ ។ បើបុគ្គលមាននិស្ស័យចាស់ក្លា ក៏ដល់នូវសកទាគាមិមគ្គ-ផល ជាដំណាក់ទី ២, អនាគាមិមគ្គ-ផលជាដំណាក់ទី ៣, អរហត្តមគ្គ-ផល ជាដំណាក់ទីបំផុត គឺព្រះនិព្វាន ។ បើបុគ្គលមាននិស្ស័យទន់ខ្សោយក៏បានដល់ត្រឹមតែដំណាក់ទី ១, បើមាននិស្ស័យជាមធ្យម ក៏បានដល់ដំណាក់ទី ២ ឬទី ៣ ទៅ ។

ការដែលខ្លួនបានដល់នូវមគ្គនឹងផលទាំងនេះ មកអំពីខ្លួនលះបង់នូវការមិនដឹង គឺអវិជ្ជាបាន ដោយការដឹងគឺវិជ្ជា ។

ពាក្យថា "ដឹង" ក្នុងទីនេះ មិនមែនសំដៅយកការដឹង ដោយអំណាចរៀន - ស្តាប់ហើយចាំមកទេ គឺសំដៅយកការដឹង ដោយអំណាចបច្ចវេក្ខណញ្ញាណ ដូចជាអណ្តាតដែលដឹងនូវរសជាតិហឹរប្រៃប៉ះពាល់ត្រូវ ហើយមិនសាបរលាបទៅវិញ ។

មិនមែនសំដៅយកការដឹងធម្មតា គឺដឹងដោយការរៀនស្តាប់ហើយចាំមកទេ ។

នេះទ្រង់ប្រៀនប្រដៅឲ្យកាន់យកនឹងឲ្យលះបង់ក្នុងបទទី ២ ។

រួមសេចក្តីទៅឃើញថា ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងដោយបទតែ ២ ដូចបានពោលហើយខាងដើម ។

នេះសឲ្យឃើញថា ព្រះសម្មាសម្ពុទ្ធមានវិជ្ជាពិសេសជាងសត្វលោកមែន ព្រោះផុតវិស័យមនុស្សសាមញ្ញ នឹងការរកដំណើរទំនងនេះឃើញ ។

តែ - ជុន

ព្រះពុទ្ធទុកដូច អ្នកប្រាប់នូវផ្លូវ.<br>
ព្រះធម៌ត្រឹមត្រូវ ដូចតួផ្លូវនោះ ។<br>
ព្រះសង្ឃទុកដូច អ្នកលីលាឆ្ពោះ<br>
ទៅតាមផ្លូវនោះ ដែលទ្រង់ប្រាប់ហើយ ។

ប.ព.

# សុភាសិត ៥០ បទ

ស្រង់ចាកច្បាប់ផ្សេង ៗ មានធម្មបទខុទ្ទកនិកាយជាដើម

---

១ – មនុស្សល្អនៅសំណាក់អាស្រ័យក្នុងទីណា រមែងញ៉ាំងសេចក្ដីត្រជាក់ចិត្តឲ្យកើតក្នុងទីនោះ ។

២ – វិជ្ជាទាំងពួងជាគ្រឿងប្រដាប់ជីវិត ។

៣ – សេចក្ដីខ្ជិលច្រអូសហាក់ដូចជាមិត្តសំឡាញ់ក្នុងខាងដើម, ប៉ុន្តែត្រឡប់ក្លាយទៅជាសត្រូវក្នុងខាងក្រោយវិញ ។

៤ – គប្បីនាំភារៈទាំងឡាយទៅ ដោយទឹកមុខរីករាយ ។

៥ – ការពារទុកជាមុន លោកពោលថាល្អជាជាងកែប្រែ ។

៦ – ខ្លាចក្នុងរបស់ដែលគួរខ្លាច មិនត្រូវខ្លាចចំពោះរបស់ដែលកែប្រែមិនបានទេ ។

៧ – មនុស្សអ្នកសន្សំបុណ្យទុក រមែងបានសេចក្ដីសុខ ។

៨ – ការចេះស្វែងរកទ្រព្យដោយផ្លូវដែលត្រូវក្ដី ការចេះរក្សាទ្រព្យទុកឲ្យគង់នៅក្ដី ការចេះចាយវាយតែក្នុងរបស់ដែលជាប្រយោជន៍ក្ដី ទាំងអស់នេះជាគ្រឿងសំគាល់យ៉ាងល្អរបស់គ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ ។

៩ – មនុស្សមិនខ្ជិលច្រអូស មិនចាក់ដោតគេ មិនអួតអាងជាមនុស្សស្អាតទាំងខាងក្រៅទាំងខាងក្នុង ជាអ្នកស្មោះត្រង់មិនលោភចង់បានតែប្រយោជន៍ផ្ទាល់ខ្លួនមួយ លោកពោលថា ជាមនុស្សជាន់ខ្ពស់ ។

១០ – ដើមឈូកឬព្រលិតជាគ្រឿងកស់ទឹក, កិច្ចការដែលធ្វើជាគ្រឿងកស់ត្រកូល, សំដីដែលនិយាយជាគ្រឿងកស់បញ្ញា, ការស្ងុតក្រៀមនៃស្មៅជាគ្រឿងកស់ផែនដី ។

១១ – ធ្វើការអ្វីបុំកុំឲ្យកករល្អក់ ប៉ុន្តែឲ្យបានប្រយោជន៍យ៉ាងល្អ ។

១២ – សេចក្ដីលោភ សេចក្ដីកំណាញ់ សេចក្ដីក្រោធ សេចក្ដីស្រវឹង សេចក្ដីប្រកាន់ខ្លួន សេចក្ដីលុបគុណគេ សេចក្ដីឫស្យា សេចក្ដីប្រមាទ សេចក្ដីខ្ជិលច្រអូស ការដេកច្រើន ទាំងអម្បាលនេះ មានក្នុងខ្លួនអ្នកណា រមែងធ្វើអ្នកនោះ ឲ្យទៅជាមនុស្សថោកទាប ។

១៣ – សេចក្ដីល្អដែលគេបានធ្វើរួចហើយ សូម្បីតែមួយប៉ុណ្ណោះ ក៏ជាគ្រឿងលើកទឹកចិត្តឲ្យរីករាយរាប់រយដង ឬលើសទៅទៀត គឺថា នឹកឃើញពេលណា សប្បាយចិត្តពេលនោះ ដល់បានធ្វើតាមគំនិតនោះក៏សប្បាយចិត្ត កាលដទៃទៅទៀតក៏ជាសុខមិនថានៅក្នុងទីណាឡើយ ទោះដេកដើរឈរអង្គុយក៏ដោយ កាលបើនឹកឃើញការនោះក៏រីករាយ ទាំងអ្នកដែលបានឃើញប្រយោជន៍ដែលយើងធ្វើហើយ ក៏មានចិត្តសរសើរឲ្យសព្ទសាធុការពរ នឹងទុកចិត្តទៅមុខទៀត ។

១៤ – សេចក្ដីសុខសប្បាយ នឹងកើតមានឡើងបាន ព្រោះតែធ្វើអំពើល្អ, សេចក្ដីទុក្ខលំបាកនឹងកើតមានឡើងបាន ព្រោះតែធ្វើអំពើអាក្រក់, អ្នកដែលគិតមិនឃើញដូច្នេះ លោកពោលថាជាមនុស្សពាល ។

១៥ - សេចក្ដីអាក្រក់ដែលបានធ្វើរួចហើយ សូម្បីតែមួយក៏អាចអាក្រក់ឲ្យទោសរាប់រយដង ឬច្រើនជាងនោះទៀត កាលខឹងក្រោធឃើញក៏ក្ដៅក្រហាយចិត្ត ធ្វើឲ្យខូចកេរ្ដិ៍ឈ្មោះ តទៅមុខ ឥតនរណារាប់អាន គេលែងជឿទុកចិត្តរាប់ពាន់យ៉ាង ដូចដើមជ្រៃដែលកើតអំពីគ្រាប់តែមួយប៉ុណ្ណោះ ប៉ុន្តែមានឫសច្រើនរាប់មិនអស់ ។

១៦ - មនុស្សដែលមិនចេះអត់ធន់ រមែងមិនបានសម្រេចប្រយោជន៍ ។

១៧ - មនុស្សដែលធ្វើការអ្វីៗបានត្រូវល្អ ព្រោះបានធ្វើការខុសជាច្រើនរួចពីមុនមកហើយ, ហេតុនោះមនុស្សល្ងង់ទុកដូចជាគ្រូរបស់មនុស្សចេះ ដ្បិតថាមនុស្សចេះត្រូវតែមិនចេះមកពីមុនហើយ ។

១៨ - អ្នកប្រើអំណាចបំបាក់បំបបទាល់តែហួសការ បរិស័ទបរិវារក៏បែកបាក់ទឹងរួញកុញទ្រាន់ ដូចជាព្រះអាទិត្យបញ្ចេញរស្មីក្ដៅខ្លាំងពេក ផ្កាយក៏រលត់ពន្លឺអស់រលីង, អ្នកដឹងប្រយោជន៍របស់អំណាចនឹងមេត្តាករុណា ចេះប្រើឲ្យល្មមសមគួរដល់ហេតុការណ៍ ក៏នឹងមានតែសេចក្ដីសុខសម្រាន្តត្រជាក់ត្រជុំ, មនុស្សស្ទើរតែពេញលោកចូលចិត្តធ្វើជាមិត្តសំឡាញ់នឹងបរិវារ ដូចជាព្រះចន្ទបញ្ចេញរស្មីត្រជាក់រីករាយ ផ្កាយក៏ចោមរោមដេរដាសពេញផ្ទាំងវេហាស៍ ។

១៩ – ការសាកសួរទីងទៅមករកអ្នកសុខសាល ឬអ្នកជម្ងឺដែលគួរសាកសួរ នេះជាការសំដែងមេត្តាករុណាដល់គ្នា ឲ្យកើតធនុះស្នេហាបានមាំមួន ដូចជាកំភ្នាន់ដូច្នោះ ។

២០ – ការដេកទាល់ថ្ងៃរះ ១ សេចក្តីខ្ជិលច្រអូស ១ កាច ១ សេចក្តីបណ្តោះបណ្តោយពេលវេលា ១ ការដើរផ្លូវឆ្ងាយតែម្នាក់ឯង ១ ការសេពគប់ភរិយាអ្នកដទៃ ១, អ្នកប្រព្រឹត្តកិច្ចទាំង ៦ យ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសមួយចំណែក ។

២១ – មនុស្សមានសម្បត្តិទ្រព្យគេគប់មុខ បើទុកជាកើតក្នុងត្រកូលថោកទាប ក៏នៅតែមានគេស្រឡាញ់គោរពខ្លាច ដូចជាផ្កាឈូកពោះបីកើតក្នុងភក់ ក៏គង់តែមានមនុស្សស្រឡាញ់ពេញចិត្តទូទៅក្នុងលោក ។

២២ – អ្នកប្រាប់បាន ៤ ចំណែក, អ្នកធ្វើការបាន ៣ ចំណែក, អ្នកម្ចាស់ទានបានចំណែកពេញ, ឯអ្នកអនុមោទនាបាន ១ ចំណែក ។

២៣ – មនុស្សខ្ជិលច្រអូសទីងមានសិល្បៈពីណា, មនុស្សឥតសិល្បទីងរកទ្រព្យពីណាបាន, មនុស្សឥតទ្រព្យទីងមានមិត្តសំឡាញ់ពីណា, មនុស្សឥតមិត្តសំឡាញ់ទីងមានសុខពីណា, មនុស្សឥតសុខទីងមានបុណ្យពីណា, មនុស្សឥតបុណ្យទីងបាននិព្វានពីណា ។

២៤ – បានប្រយោជន៍ក្នុងទីណា ដោយប្រការឯណាៗ គប្បីប្រឹងប្រែងក្នុងទីនោះ ដោយប្រការនោះៗ ។

២៥ – បើស្រឡាញ់ខ្លួនហើយ ត្រូវឲ្យខ្ជាប់សេចក្ដីខុស ទើបចាត់ថាជាអ្នកគិតត្រូវ ។

២៦ – អ្នកប្រែប្រួលមិនជាទីកោតក្រែងចិត្តរបស់អ្នកត្រូវប្រែប្រួល បើប្រែប្រួលគេប៉ុនត្រឹមណា គេក៏មិនកោតក្រែងចិត្តខ្លួនប៉ុនត្រឹមណោះ ។

២៧ – សេចក្ដីពេញចិត្ត ១ សេចក្ដីព្យាយាម ១ សេចក្ដីយកចិត្តទុកដាក់ ១ ការឧស្សាហ៍ត្រិះរិះរកហេតុផលក្នុងកិច្ចនោះៗ ១, គុណទាំង ៤ យ៉ាងនេះ រមែងញុំាងកិច្ចដែលមិនហួសវិស័យឲ្យសម្រេចបាន ។

២៨ – កិរិយាល្អ ប្រសើរជាងគ្រឿងប្រដាប់ ។

២៩ – បុណ្យរបស់អ្នកឲ្យទានរមែងចំរើនប៉ុនឡើង ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ។

៣០ – អ្នកឲ្យជាទីស្រឡាញ់របស់អ្នកសូម, អ្នកសូមកាលបើមិនបាន ក៏មិនជាទីស្រឡាញ់ដូចគ្នា ។

៣១ – អ្នកឲ្យរបស់ល្អ តែងបានទទួលរបស់ល្អវិញដែរ ដូចជាអ្នកបូជាគេ រមែងបានការបូជាតបវិញដែរ ។

៣២ – អ្នកឲ្យរមែងចងមេត្រីទុកបាន ។

៣៣ – អ្នកត្រេកអរក្នុងការបរិច្ចាគទាន រមែងចងមិត្តទុកបាន នឹងជាទីស្រឡាញ់ពេញចិត្តរបស់អ្នកបានទទួល ។

៣៤ – ឲ្យធម៌គឺពាក្យប្រៀនប្រដៅជាទាន រមែងជាបណ្ណាការដ៏វិសេសជាងការឲ្យអាមិសទាំងពួង ។

៣៥ – ឈើមួយដើមគង់មានថ្នាំងផ្សេងគ្នា បងនឹងប្អូនគង់តែមានចិត្តផ្សេងគ្នាដែរ ។

៣៦ – កើតមកជាមនុស្ស ចូរធ្វើឲ្យជាមនុស្សទាំងកាយទាំងចិត្ត ។

៣៧ – ដើមឈើធំដែលមានមែកនឹងមានផ្កាផ្លែ រមែងជាប្រយោជន៍ដល់ហ្វូងសត្វបក្សីយ៉ាងណា, អ្នកធំដែលជាប្រធាន បើបានតាំងនៅក្នុងព្រហ្មវិហារធម៌ហើយ រមែងមានប្រយោជន៍ដល់ពួកជនជាច្រើនយ៉ាងនោះឯង ។

៣៨ – បើមិនរៀនហាត់ក៏មិនមានបំណិន ។

៣៩ – គេសាបព្រោះពូជដូចម្ដេច ក៏រមែងបានទទួលផលដូច្នោះ ។

៤០ – អ្នកប្រកបហេតុនៃសុខ សូម្បីមិនប្រាថ្នាសុខក៏គង់តែសុខហូរចូលមកឯង ។

៤១ – មនុស្សធ្វើហេតុល្អ រមែងបានទទួលផលល្អជាដរាប ។

៤២ – គេទ្រើជាម្ចាស់នៃសេចក្ដីល្អដូចម្ដេច គេទុកជាម្ចាស់នៃការគ្រប់គ្រងគ្រួសារនឹងទ្រព្យសម្បត្តិដូច្នោះដែរ ។

៤៣ – ទឹកដ៏ថ្លាស្អាត ប៉ុន្តែបើមានពណ៌ផ្សេងៗ ចូលមកលាយឡំហើយ ក៏រមែងធ្វើឲ្យទឹកនោះក្លាយទៅជាពណ៌លាយឡំល្អក់សៅហ្មងដូចម្ដេចវិញ, មនុស្សអ្នកមានសេចក្ដីល្អដែលបានធ្វើទុកមកហើយ សូម្បីយ៉ាងច្រើន បើមានសេចក្ដីអាក្រក់មកប៉ះពាល់ហើយ ក៏រមែងសៅហ្មង

នឹងលុបលាងសេចក្តីល្អដែលមានមកហើយនោះ ឲ្យសាបសូន្យទៅដូច្នោះដែរ ។

៤៤ – បុគ្គលក្រោធខឹងច្រើន រមែងមិនបានទទួលសេចក្តីសុខសម្រាន្ត ។

៤៥ – បុរសមានភរិយាមិនល្អ, ស្ត្រីមានស្វាមីទុជ៌ន, ប្រសិនបើជាគ្មានសោះប្រសើរជាង ។

៤៦ – អសិរពិសបើទុកជាសត្វដែលគួរខ្លាចក៏ពិតមែន ប៉ុន្តែនៅមិនគួរខ្លាចស្មើនឹងមនុស្សអាក្រក់ គឺមនុស្សពាលឡើយ ។

៤៧ – មានគេនិយាយថា មាន់ល្អព្រោះរោម សូម្បីមនុស្សនឹងល្អក៏ព្រោះការគាត់តែងខ្លួន, ដូច្នេះក៏មែនហើយ ប៉ុន្តែត្រូវឲ្យចេះគាត់តែងខ្លួនផងទើបបានសមល្អ ។

៤៨ – ការគាត់តែងពាក់កាយឲ្យស្រស់ល្អទៅផ្សេងៗ ត្រឹមតែខាងក្រៅប៉ុណ្ណោះ នៅមិនទាន់ល្អស្មើនឹងការគាត់តែងចិត្តឲ្យល្អទេ ។

៤៩ – មនុស្សយើងអាចធ្វើសេចក្តីល្អ និងអាក្រក់បានគ្រប់យ៉ាង ប៉ុន្តែបើចង់បានសេចក្តីសុខសប្បាយ ឬសេចក្តីរីករាយចិត្ត ក៏ចូរធ្វើតែអំពើល្អមួយចំណែកចុះ ។

៥០ – ការជួសជុលរបស់ចាស់ ជាសម្បត្តិរបស់អ្នកគ្រប់គ្រងផ្ទះ ។

ប៉ូ. ប៉ូ.

## និទានប្រាំរឿងការកប់ប្រុសពាលនឹងបណ្ឌិត

# រឿងកប់ប្រុសពាល

កាលព្រេងនាយ, គហបតីម្នាក់ មានមនុស្សបម្រើសុទ្ធតែជាជនខ្លួនពាល ។ ថ្ងៃមួយ គហបតីនោះទៅឆ្លងទឹកឯកំពង់ ឲ្យមនុស្សបម្រើម្នាក់ដើរតាមទៅផង, ដល់កំពង់ទឹក គហបតីដោះសំពត់ទុកលើគោក ហើយចុះទៅឆ្លងទឹក មានខ្យល់កំបុតត្បូងភ្លូបសំពត់បាត់ទៅ, គហបតីកំពុងតែមុជតាមរកសំពត់ មនុស្សបម្រើនឹកស្មានថាទឹកក្លួបម្ចាស់បាត់, ក៏រត់ទៅប្រាប់ភរិយាគហបតី ។ ភរិយាក៏យំរន្ធត់ក៏រត់ប្រញាប់ទៅប្រាប់អ្នករក្សាទ្វារ ។ ប្រញាប់ពេកពុំបានពាំងទ្វារ ។ ភរិយាទៅប្រាប់អ្នករក្សាកូនខ្ចី ៗ គិតថាបើផ្ញើកូនម្ចាស់នឹងគេ ក្រែងគេមិនរក្សាឲ្យ ក៏យកកូនទៅលាក់ក្នុងអណ្ដូងគ្មានទឹក ។ ភរិយាទៅប្រាប់អ្នកដាំបាយ ៗ ក៏យំខ្លាំងក៏ប្រញាប់ទៅដោយពុំបានលត់ភ្លើងជើងក្រាន ។ អ្នកទាំងបីនាក់នាំគ្នារត់ទៅកាន់កំពង់ទឹក ដោយយំសស្រាក់ស្រៀងខ្លួន ។ គហបតីសួរថាម្ដេចបានជាយំរត់មក? ភរិយាប្រាប់តាមដំណើរ ។

ឯភ្លើងជើងក្រានក៏ឆេះរាលដាល, កូនដែលដាក់ក្នុងអណ្ដូងក៏ក្ដៅស្លាប់, ពួកចោរឃើញផ្ទះចំហទ្វារក៏លួចយកទ្រព្យសម្បត្តិអស់ ។ គហបតីនឹងភរិយាមកដល់ផ្ទះ បានឃើញដូច្នោះ ក៏ហួសចិត្តគិតតែពីយំសោកស្ដាយឥតឧបមា ។

ហេតុដូច្នេះ បានជាអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើមតែងទូន្មានថា ត្រូវប្រយ័ត្ន ត្រូវកុំគប់ប្រសព្វនឹងជនពាលជាដាច់ខាត ព្រោះការគប់ប្រសព្វនឹងជនពាលតែងកាត់បង់នូវប្រយោជន៍ ក្នុងលោកនេះនឹងលោកខាងមុខ ។

## រឿងគប់ប្រសព្វបណ្ឌិត

កាលព្រេងនាយ, មានព្រះរាជាមួយព្រះអង្គទ្រង់សោយរាជ្យក្នុងនគរពារាណសី ទ្រង់មានព្រះប្រាជ្ញាអធ្យាស្រ័យល្អ ។

ព្រះអគ្គមហេសីនៃព្រះរាជាអង្គនោះ ទ្រង់ព្រះនាមខេមា ។ ព្រះនាងនោះក្បត់ព្រះរាជាទៅគប់ក័ន្តនឹងសេនាបតីម្នាក់ ។ ព្រះរាជាទ្រង់ជ្រាបទ្រង់សព្វព្រះរាជហឫទ័យចេញទៅប្រទេសក្រៅ ទ្រង់សួរបុរោហិតថា ប្រសិនបើខ្ញុំត្រូវការចេញទៅប្រទេសក្រៅ តើត្រូវយកនរណាទៅផងទើបបានសុខ?

បុរោហិតក្រាបបង្គំទូលថា បើទ្រង់យកអាមាត្យ ៤ នាក់ គឺពលអាមាត្យ (អ្នកមានកំលាំង) ១, សុវណ្ណការអាមាត្យ (ជាងមាស) ១, វិចារអាមាត្យ (អ្នកពិចារណាក្តី) ១, បណ្ឌិតអាមាត្យ (អ្នកដោះសាអាថ៌ប្រស្នា) ១ ទើបបានសុខ ។

ព្រះរាជាទ្រង់ចេញចាកព្រះនគរ ដោយទ្រង់យកអាមាត្យ ៤ នាក់ទៅតាមព្រះអង្គ ។ លុះស្ដេចទៅដល់ព្រៃប្រទល់ព្រះនគរ អស់ស្បៀង

អាហារ, ពលអាមាត្យ បានឃើញដូនចាស់ម្នាក់កាន់ត្បូងមកបម្រើន
នឹងពុះខ្ទះសក៏ជួយពុះខ្ទះសដូនចាស់ ៗ ដូនចាស់ត្រេកអរបានឲ្យអន្ទក់នឹង
ប្រាក់ឈ្នួលជាច្រើន ៗ ប្រាក់នេះបានជាស្បៀងលៀងជីវិតនៃជន
ទាំង ៥ រូបតទៅ ៗ ជនទាំង ៥ រូបក៏ចេញដំណើរពីទីនោះចូលទៅក្នុង
នគរមួយទៀត. នៅទីក្រុងនោះ មានសេដ្ឋីម្នាក់គិតធ្វើគ្រឿងមាសពេជ្រ
ឲ្យកូនស្រី តែនៅទីក្រុងនោះ ពុំមានជាងមាសស្ទាត់ជំនាញ, លុះបាន
ឃើញជនទាំង ៥ រូបក៏ចូលទៅរក ៗ ព្រះអាគន្ធកុមារ ទទួលធ្វើគ្រឿង
ការនេះឲ្យសុវណ្ណការអាមាត្យៗទទួលធ្វើគ្រឿងប្រដាប់ឲ្យសេដ្ឋីនោះបាន
ឈ្នួលជាច្រើន ៗ លុះចេញដំណើរពីទីនោះទៅដល់នគរធំមួយទៀត
ចូលទៅអាស្រ័យក្នុងសាលាមួយជិតផ្ទះសេនាបតីនៅទីក្រុងនោះ ៗ

គ្រានោះ បុរសម្នាក់មានបង្វិចប្រាក់ ១ ពាន់កហាបណៈ នឹងបាយ
មួយកញ្ចប់ ហែលឆ្លងស្ទឹងធំជ្រៅ មានទឹកហូរខ្លាំង, លុះហែលដល់ពាក់
កណ្ដាលស្ទឹង អស់កម្លាំងពុំអាចហែលឆ្លងបាន ក៏ស្រែកហៅគេឲ្យជួយ
ចម្លងដោយពាក្យថា “ បើអ្នកណាអាចចម្លងខ្ញុំបាន, ខ្ញុំនឹងជូនរបស់ជាទី
គាប់ចិត្ត ” ៗ

ខណៈនោះ បុរសម្នាក់ហែលទឹកចម្លងបាន ៗ លុះដល់ត្រើយ
បុរសម្ចាស់ទ្រព្យ បានឲ្យកញ្ចប់បាយដល់អ្នកចម្លង ដោយពាក្យថា
“ពេលនេះជាពេលបាយ, បាយនេះហើយជាទីគាប់ចិត្តជាងគេ” ៗ

អ្នកបម្លងទារប្រាក់ អ្នករងគ្រោះពុំឲ្យ ៗ អ្នកទាំងពីរក៏ទៅរកជនទាំង៥រូប នៅក្នុងសាលាឲ្យកាត់ក្តី ៗ ព្រះរាជាទ្រង់ប្រគល់ការៈនេះទៅវិចារអាមាត្យៗ អង្កេតសួរសព្វសេចក្តីហើយ ក៏ឲ្យអ្នករងគ្រោះជាម្ចាស់ទ្រព្យ ដាក់ប្រាក់នឹងកញ្ចប់បាយពីមុខ ហើយបង្គាប់ដោយពិសោធន៍ថា “ចូរអ្នកក្រោកឡើង, របស់ណាអ្នកស្រឡាញ់, ចូរអ្នកយកទៅ?” ម្ចាស់ទ្រព្យឮហើយក៏ស្ទុះចាប់យកបង្វិចប្រាក់ដើរទៅ, ទើបនឹងដើរបានពីរបីជំហាន, វិចារអាមាត្យហៅមកវិញសួរថា “បង្វិចប្រាក់នេះជារបស់គាប់ចិត្តអ្នកឬ ៗ ឆ្លើយថា ‘គាប់ចិត្ត” ៗ អើបើអ្នកគាប់ចិត្ត ចូរអ្នកឲ្យប្រាក់ទៅអ្នកបម្លងចុះ ព្រោះត្រូវតាមពាក្យដើមរបស់អ្នកហើយ” ៗ ម្ចាស់ប្រាក់ទាល់គំនិត ក៏ប្រគល់ប្រាក់ឲ្យអ្នកបម្លង ហើយលាចេញទៅដោយសេចក្តីក្រៀមក្រំ ៗ វិចារអាមាត្យ ឲ្យប្រាក់នោះទៅអ្នកបម្លង ៗ បែងប្រាក់នោះពាក់កណ្តាលជូនទៅវិចារអាមាត្យ ៗ ប្រាក់នេះបានទៅជាស្បៀងនៃជនទាំង៥រូបតទៅទៀត ៗ រឿងនេះក៏ល្បីឮទៅពេញទាំងព្រះនគរ ៗ

ក្នុងកាលមិនយូរ សេនាបតីមួយរូបចូលទៅគាល់ព្រះរាជា ក្នុងព្រះនគរនោះ ព្រះរាជាទ្រង់សួរថា “មង្គលហត្ថីជាព្រះទីនាំងយើងនេះ តើមានទម្ងន់ប៉ុន្មាន? ធ្វើម្តេចនឹងបានដឹងទម្ងន់ដំរីនេះពិតប្រាកដ? ចូរអ្នករិះរកប្រស្នានេះក្នុងរវាង៧ថ្ងៃ” ៗ សេនាបតីត្រឡប់មកផ្ទះត្រិះរិះរកពីរ

បីថ្ងៃពុំឃើញសោះ ក៏ទៅសួរជនទាំង ៥ រូប ដែលសំណាក់នៅក្នុងសាលា ។

ព្រះអាគន្តុករាជា ទ្រង់ប្រគល់ការៈនោះទៅបណ្ឌិតអាមាត្យៗ ប្រាប់សេនាបតីថា ចូរលោកធ្វើក្បូនបុស្សរ ហើយឲ្យបរដំរីឡើងទៅលើក្បូន ឲ្យក្រិតក្បូនជាសំគាល់ក្នុងពេលដំរីឡើង, ឲ្យបរដំរីចុះចេញពីក្បូន ហើយយកថ្មុំផុំផ្ទ ទៅដាក់លើក្បូនជំនួសដំរី ឲ្យដល់ក៏រិតដូចកាលដាក់ដំរី, រួចយកថ្មផ្ទនោះមកថ្លឹង, ទម្ងន់ថ្មផ្ទប៉ុន្មាន ទម្ងន់ដំរីប៉ុណ្ណោះឯង ។ សេនាបតីក៏ទៅធ្វើដូច្នោះថ្វាយព្រះមហាក្សត្រទត ។ ព្រះមហាក្សត្រទ្រង់សរសើរថា សេនាបតីនេះមានប្រាជ្ញាមែន, ក៏ព្រះរាជទានរង្វាន់ជាច្រើន មានមាសប្រាក់ គោក្របីដំរីសេះជាដើម ដល់សេនាបតីៗ នោះដឹងគុណ ក៏ជូនកូនក្រមុំម្នាក់អាយុ ១៦ ឆ្នាំ ដល់បណ្ឌិតអាមាត្យ ។ បានលើកនាងកញ្ញានោះថ្វាយចំពោះព្រះរាជារបស់ខ្លួន ។ ក្រោយមកមិនយូរប៉ុន្មាន ព្រះរាជាក្នុងព្រះនគរនោះ ទ្រង់ព្រះទិវង្គត ។ ដោយព្រះអង្គមានតែព្រះរាជបុត្រី ពុំមានព្រះរាជបុត្រានឹងគ្រងរាជ្យតទៅ, អ្នកនគរប្រាជ្ញារកអ្នកមានបុញ្ញានុភាពដើម្បីគ្រប់គ្រងព្រះនគរ ក៏ផ្សងបុស្សរ័ត្ន ។ រត់ជំរំទៅឈប់នៅមុខសាលាជាទីលំនៅនៃជនទាំង ៥ រូប ។ ទើបជនទាំងអស់គ្នាអញ្ជើញព្រះអាគន្តុករាជាគង់លើបុស្សរ័ត្ន ព្រមទាំងអាមាត្យ ៤ រូបនាំចូលទៅក្នុងព្រះនគរ អភិសេកព្រះរាជបុត្រី នៃព្រះអតីតរាជា

ជាអគ្គមហេសីស្តាំ, បុត្រីសេនាបតីជាអគ្គមហេសីឆ្វេង ។ ឯព្រះអាទ្ឋក-
ពជា កាលទ្រង់បានសោយរាជ្យជាសុខហើយ ទ្រង់តាំង :-

១ – បណ្ឌិតអាមាត្យ ជាឧបរាជ;

២ – វិធុរអាមាត្យ ជាសេនាបតី;

៣ – សុវណ្ណការអាមាត្យ ជានាយឃ្លាំង;

៤ – ពលអាមាត្យ ជាចមពល ។

ហេតុដូច្នេះ បានជាអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម សំដែងថា: គប្បីគប់ប្រសព្វនឹងជនជាបណ្ឌិត ព្រោះការគប់ប្រសព្វនឹងជនជាបណ្ឌិត រមែងបានសម្រេចប្រយោជន៍ ២ ប្រការ គឺប្រយោជន៍ក្នុងលោកនេះនឹងលោកខាងមុខ ។

ស្រង់ចាកសរុបជាតក

ហាប – ពិន

ពាលនាំអ្នកគប់ឲ្យខាតបង់, បណ្ឌិតនាំត្រង់ផ្លូវសុចរិត
ឲ្យបានប្រយោជន៍ប្រពៃពិត; គួរគប់បណ្ឌិតកុំគប់ពាល ។

ប. ៣.

# វឌ្ឍនធម៌

សេចក្ដីចំរើនដោយទ្រព្យសម្បត្តិ, ដោយចំណេះវិជ្ជាឬដោយវត្ថុណាមួយ សុទ្ធតែជាឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នាជាទីចាប់ចិត្តរបស់ប្រជាជនទាំងអស់ក្នុងលោក ឥតមាននរណាម្នាក់ស្អប់ខ្ពើមបដិសេធចោលសេចក្ដីចំរើនឡើយ ។ ពាក្យថា "សេចក្ដីចំរើន" នេះ ត្រង់នឹងពាក្យបាលីថា "វឌ្ឍនធម៌ ឬ វឌ្ឍិធម៌" ប្រែថា "សេចក្ដីចំរើន" ហេតុការជាគ្រឿងចំរើន, វត្ថុជាគ្រឿងល្អលាស់ដុះដាលឬថាវត្ថុផ្សេងៗ ដែលមិនធ្លាប់មាន. មិនធ្លាប់ឃើញ ហើយស្រាប់តែមានឡើង, កើតឡើង ឃើញប្រាកដដែលអាចទាយបានថា បុគ្គលអ្នកមានសេចក្ដីចំរើន ឬប្រទេសមានសេចក្ដីចំរើន" ។ ចំពោះបុគ្គលក្ដី ចំពោះប្រទេសក្ដី ដែលចេះតែមានសេចក្ដីចំរើនដោយភោគសម្បទ៍, ដោយវិជ្ជាសម្បទ៍ មិនឈប់នៅនឹងដដែលឬមិនឈរទ្រឹងគាំងនៅដដែល ៗ គឺចេះតែល្អលាស់លឿនប្លែកឡើងៗ ហៅថា "វឌ្ឍនធម៌" ។ ពាក្យបារាំងថា ប្រូគ្រេស (progrès) ។

ពាក្យថា "វឌ្ឍនធម៌" នេះ ជាពាក្យបាលីក៏ពិតមែន តែប្រជាជនជាតិខ្មែររបស់យើងក្ដី អ្នកប្រទេសថៃក្ដី តែងនិយមយកមកប្រើជាញឹកញយណាស់ហើយ ។ ពាក្យនេះ ឈ្មោះថាជាគ្រាមភាសាដោយស៊ប់ស្លួនណាស់ហើយ, មួយទៀត ពាក្យនេះ អ្នកប្រទេសដែលចេះភាសាបាលី តែងលើកដំកើងថាជាពាក្យប្រសើរខ្ពង់ខ្ពស់ថ្លៃថ្នូរជាទីបំផុត ។

ភាសាបាលីក៏និយមយកពាក្យថា "វឌ្ឍនធម៌" នេះ មកប្រើក្នុងប្រយោគដែលមានមកក្នុងគម្ពីរពុទ្ធសាសនាជាច្រើនកន្លែង ។ តែន័យខ្លះថា វឌ្ឍនធម៌, ន័យខ្លះថា វុឌ្ឍិធម៌ ។ នេះជានាមស័ព្ទ ។ បើជាកិរិយាស័ព្ទ ជាឯកវចនៈថា "វឌ្ឍតិ" ។ ជាពហុវចនៈថា "វឌ្ឍន្តិ" ប្រែថា "រមែងចំរើន, លូតលាស់តទៅ" ។

ពាក្យថា "វឌ្ឍនធម៌" នេះ ជាពាក្យដែលមានមកក្នុងភាសាបាលី យូរយារណាស់មកហើយ ។ លោកអ្នកប្រាជ្ញក្នុងសម័យបុរាណក្តី សម័យបច្ចុប្បន្នក្តី តែងនិយមរាប់អានលើកដំកើង យកមកប្រើជាញឹកញយណាស់ ដូចពាក្យដែលមានមកក្នុងអនុមោទនាវិធីថា "ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ" ប៉ុណ្ណោះជាដើម ប្រែថា "ធម៌ទាំង-ឡាយ ៤ យ៉ាងគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើន" ។ ធម៌ទាំង ៤ នេះ ក៏គួរឲ្យឈ្មោះថាវឌ្ឍនធម៌ គឺជាពាក្យសំរាប់សូត្រជូនពរដើម្បីចង់ឲ្យប្រែជាជនមានសេចក្តីចំរើនដោយអាយុ គឺចង់ឲ្យមានអាយុរស់នៅវែងឆ្ងាយ, ចង់ឲ្យមានពណ៌សម្បុរកាយល្អ, ចង់ឲ្យមានសេចក្តីសុខកាយ-ចិត្ត, ចង់ឲ្យមានកំលាំងកាយ កំលាំងប្រាជ្ញា ។

ក្នុងគាថាវៈបាលី មានពាក្យសំបូរសព្រែងជាពាក្យរបស់បុរាណ-បណ្ឌិត ដែលសំដែងទុកមកចង់ឲ្យពុទ្ធសាសនាមានវឌ្ឍនធម៌ គឺ សេចក្តីចំរើនផង ចង់ឲ្យលោកគឺប្រែជាជនមានវឌ្ឍនធម៌ផង ដូចបាលីថា :

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា ប៉ុណ្ណោះជាដើម ថែប្រែថា "សូមឲ្យសាសនានឹងលោកមានវឌ្ឍនធម៌ឡើងគ្រប់ ៗ កាល" ។ ព្រោះហេតុនោះ ពាក្យថាវឌ្ឍនធម៌នេះ ជាពាក្យដែលមានមកក្នុងភាសាបាលីយូរណាស់ហើយ ជាពាក្យរបស់បុរាណបណ្ឌិត ពុំមែនជាពាក្យថ្មីឡើយ ។

វឌ្ឍនធម៌នេះ បើចែកតាមគោលដោយសង្ខេប តាមបែបរបស់បុរាណបណ្ឌិត គួរចែកចេញជា ២ យ៉ាង ។

## គោលនៃវឌ្ឍនធម៌ ២ យ៉ាង

១ — សាសនវឌ្ឍនធម៌ សេចក្ដីចំរើនរបស់សាសនា;

២ — លោកវឌ្ឍនធម៌ សេចក្ដីចំរើនរបស់លោក ។

## សាសនវឌ្ឍនធម៌មាន ៣ យ៉ាង

១ — បរិយត្តិវឌ្ឍនធម៌ សេចក្ដីចំរើនដោយបរិយត្តិ;

២ — បដិបត្តិវឌ្ឍនធម៌ សេចក្ដីចំរើនដោយផ្លូវប្រតិបត្តិ;

៣ — បដិវេធវឌ្ឍនធម៌ សេចក្ដីចំរើនដោយការត្រាស់ដឹងឬដោយការយល់ច្បាស់លាស់នូវអត្ថនឹងធម៌ ។

## អធិប្បាយបរិយត្តិវឌ្ឍនធម៌

ពាក្យថា "បរិយត្តិ" ថែប្រែថា "ការសិក្សា ឬការរៀនសូត្រ" ។

អ្នកកាន់ព្រះពុទ្ធសាសនាក្ដី អ្នកកាន់សាសនាដទៃណាមួយក្ដី ត្រូវតែមានបរិយត្តិគឺការរៀនសូត្រនេះជាប្រធាន ទើបអាចចេះដឹងច្បាស់លាស់ យល់សេចក្ដីរបស់សាសនានោះៗទៅបាន ព្រោះថា ការសិក្សានេះចាត់ជាអគ្គការមួយដ៏ប្រសើរបំផុតដែលអាចធ្វើអ្នកសិក្សាឲ្យមានសមត្ថភាពតាមសមគួរដល់ឋានៈនៃខ្លួន ដែលមានឧបនិស្ស័យខ្ពង់ខ្ពស់ឬទន់ខ្សោយ ៗ ការសិក្សា រាប់ថាជាជំហានទី ១ នៃសេចក្ដីចំរើនគ្រប់យ៉ាង, ការសិក្សាជាប្រទីបបំភ្លឺនៃប្រាជ្ញាស្មារតី, ជាករណីយកិច្ច ១ ដ៏ប្រសើរបំផុតដែលអាចញ៉ាំងពលរដ្ឋឬពលសាសនាឲ្យប្រកបដោយឧត្ដមគតិ គឺឲ្យមានដំណើរខ្ពង់ខ្ពស់ថ្លៃថ្នូរ ៗ

ការសិក្សាក្នុងផ្លូវព្រះពុទ្ធសាសនារបស់ពុទ្ធបរិស័ទ នៅប្រទេសកម្ពុជាយើង កាន់តែចំរើនរើប ៗ ដែរហើយ តែថា ពុំទាន់ឈ្មោះថាមានបរិយត្តិវឌ្ឍនធម៌គ្រប់គ្រាន់នៅឡើយ ៗ បើគិតតាមចំនួនវត្តអារាមដែលបានទទួលការសិក្សារៀនសូត្រមានចំនួនតិចណាស់, ដែលមិនទាន់បានទទួលការសិក្សាតាមសម័យនិយមនោះ សល់នៅចំនួនច្រើនណាស់ ៗ បព្វជិតក្នុងព្រះពុទ្ធសាសនា លោកចាត់ថាជាជេដ្ឋបុត្រ ប្រែថា "កូនច្បងនៃព្រះសម្មាសម្ពុទ្ធ" ព្រោះហេតុនោះ គួរតែបព្វជិតខំប្រឹងសិក្សាច្បាប់ព្រះពុទ្ធសាសនា ឲ្យចេះដឹងជ្រៅជ្រះច្រើនជាងគ្រហស្ថ ដើម្បីណែនាំគ្រហស្ថដែលជាប្អូន ៗ ឲ្យយល់ប្រយោជន៍ទាំងបច្ចុប្បន្ននិងបរលោក

តែនៅមានបព្វជិតជាច្រើនរូប ដែលមិនព្រមទទួលការសិក្សារៀនសូត្រ នៅតែមានអស្មិមានៈប្រកាន់រឹងត្អឹង ពួនសម្ងំនៅក្នុងព្រះពុទ្ធសាសនា កុំថាឡើយដល់ទៅធម៌វិន័យជ្រាលជ្រៅម៉ត់ចត់ សូម្បីតែសូត្រធម៌ជាភាសាបាលីសុទ្ធ ក៏ឥតត្រឹមត្រូវត្រង់ផ្ទង់នៃអក្ខរប្បភេទសោះ ដូចបាលីថា "ឯវម្មេ សុតំ ។ សគ្គេ កាមេ ច រូបេ ។ ភវន្តុ តេ" ។ ប៉ុណ្ណេះជាដើម មានបព្វជិតខ្លះ សូត្រថា "អែវ៉ម្មែ សូតាង" ។ ថា "សគ្គឹ កម្ម៉ែ ច រូប៉ែ" ។ ថា "ភវន្តុ តែ" ដូច្នេះទៅវិញ ។

ការសូត្រភាសាបាលី ដែលខុសបុក្គាំងក្អាត់ដូច្នេះ ក៏ព្រោះទោសនៃខ្លួនដែលគ្មានការសិក្សាដោយត្រឹមត្រូវ ដែលចេះតែប្រកាន់តាមទម្លាប់ មិនប្រកាន់តាមច្បាប់អក្ខរប្បភេទសោះ ។ ការសូត្រខុសក្អាំងក្អាត់ដូចខាងលើប៉ុណ្ណេះជាដើមនេះ សសេចក្ដីឱ្យឃើញថា "មិនទាន់មានបរិយត្តិវឌ្ឍនធម៌នៅឡើយ" ។ ឈ្មោះថាជាអកប្បិតនៅក្នុងទីឆ្ងាយអំពីបរិយត្តិវឌ្ឍនធម៌ដោយពិត ។

## អធិប្បាយបដិបត្តិវឌ្ឍនធម៌

ពាក្យថា "បដិបត្តិ ឬ ប្រតិបត្តិ" ប្រែថា "ការប្រព្រឹត្តិតាម, ការធ្វើតាម, ការកាន់តាម ឬថា ការដើរតាមលំអានច្បាប់" ។

ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថ កាលបើបានបំពេញការសិក្សាបរិបូណ៌ហើយ រមែងចេះចាំយល់សេចក្តីបានដោយសព្វគ្រប់ ៗ ព្រោះជាការសិក្សា ទុកជាហេតុ ការប្រព្រឹត្តិកាន់តាម ទុកជាផល ៗ កាលបើហេតុមិនបរិបូណ៌ ផលក៏ពុំអាចបរិបូណ៌ទៅបាន ៗ បើតាមសេចក្តីសង្កេតដែលបានឃើញជាក់លាក់ឃើញថា ពុទ្ធបរិស័ទនៅមានប្រព្រឹត្តខុសឆ្គងឃ្លៀងឃ្លាតអំពីច្បាប់ព្រះពុទ្ធសាសនាជាច្រើនរូប ៗ

ព្រះវិន័យទាំង ៥ គម្ពីរ ទុកជាជាពុទ្ធក្រម គឺជាច្បាប់នៃព្រះសម្មាសម្ពុទ្ធ មាននៅគ្រប់គ្រាន់ឥតទាន់សាបសូន្យខ្វះខាតឡើយ ៗ ព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ជាព្រះប្រិយមហាក្សត្រ មហាធម្មិក បានទ្រង់ចាត់ការរៀបចំពុទ្ធសាសនា បានប្រជុំអ្នកប្រាជ្ញទាំងបព្វជិតទាំងគ្រហស្ថ ឲ្យប្រែបាលីក្នុងវិនយបិដក ព្រមទាំងអដ្ឋកថា ត្រង់សេចក្តីដែលនិយាយអំពីចីវរនឹងការប្រើប្រាស់ចីវរ ៗ លោកអ្នកប្រាជ្ញបានប្រែព្រមទាំងជំនុំជំរះវិនិច្ឆ័យដោយមូលមតិជាឯកច្ឆន្ទ ៗ ព្រះករុណាជាម្ចាស់ជីវិតក៏បានចេញព្រះរាជក្រមមួយ ដើម្បីរៀបចំធម៌វិន័យផ្នែកខាងបព្វជិត ឲ្យមានរបៀបរៀបរយដូចគ្នាឡើងមានការឃុំចីពរជាដើម តាមសេក្ខិយវត្តត្រង់សិក្ខាបទទី ៣ ថា សុប្បដិច្ឆន្ន:ក្និសារប្យ: ៗ

ព្រះពុទ្ធក្រម ក៏មាននៅបរិបូណ៌, ព្រះរាជក្រម ក៏មាន តែបញ្ញត្តិ ដែលនៅប្រកាន់គ្រាតគ្រាត បេះតែក្រាញមិនព្រមប្រព្រឹត្តតាមក្រម ក៏នៅក្រាស់ក្រែល ៗ ក្រមទាំងពីរ ទុកជាជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត គួរប្រព្រឹត្តគួរកាន់តាមណាស់ហើយ តែនៅបង្អែរបង្អង់ចាំប្រព្រឹត្តតាមក្រមណាទៀត ៗ

សេចក្ដីប្រព្រឹត្តិប្រតិបត្តិក្នុងផ្លូវព្រះពុទ្ធសាសនា របស់ពុទ្ធបរិស័ទ ដោយត្រឹមត្រូវឥតឃ្លៀងឃ្លាត ឈ្មោះថាមានបដិបត្តិវឌ្ឍនធម៌ ៗ ដែលនៅខុសឆ្គងឬឃ្លៀងឃ្លាតដោយសេចក្ដីប្រកាន់ខ្វះ ដោយសេចក្ដីល្ងង់ខ្លៅខ្វះ ដូច្នេះ ឈ្មោះថា មិនទាន់មានបដិបត្តិវឌ្ឍនធម៌នៅឡើយ ៗ

## អធិប្បាយបដិវេធវឌ្ឍនធម៌

ពាក្យថា "បដិវេធ:" ប្រែថា "ការត្រាស់ដឹង, ការយល់ច្បាស់លាស់នូវអត្ថនិងធម៌, ឬថា ការចាក់ធ្លុះចំពោះធម៌ដ៏ជ្រាលជ្រៅ មានអរិយសច្ចធម៌ជាដើម" ៗ ការយល់ច្បាស់លាស់នូវអត្ថនិងធម៌ ទុកជាជាផល ដែលកើតមកអំពីហេតុ គឺសេចក្ដីប្រតិបត្តិ ៗ បដិវេធវឌ្ឍនធម៌នេះ ជាផលចុងក្រោយបំផុត, កាលបើមានបរិយត្តិបរិបូណ៌ ទាំងប្រតិបត្តិក៏បរិបូណ៌, កាលបើហេតុទាំងពីរនេះ ចំរើនបរិបូណ៌ហើយ រមែងជាបច្ច័យជូនដំណើរឱ្យដល់នូវបដិវេធ: គឺការចាក់ធ្លុះចំពោះធម៌ដ៏ជ្រាលជ្រៅ មានអរិយសច្ចធម៌ជាដើម ដោយពិតពុំខាន ៗ ពុទ្ធបរិស័ទ

អ្នកមានសេចក្ដីចំរើន ដោយការយល់ហេតុនិងផល ឬ យល់ច្បាស់នូវប្រយោជន៍ក្នុងពុទ្ធសាសនា ដូចសំដែងមកដោយសង្ខេបប៉ុណ្ណេះ ឈ្មោះថា "អ្នកមានបដិវេធវឌ្ឍនធម៌" ។

## លោកវឌ្ឍនធម៌ មាន ៣ យ៉ាង

១—វិជ្ជាវឌ្ឍនធម៌ សេចក្ដីចំរើនដោយវិជ្ជា;

២—អាហារវឌ្ឍនធម៌ សេចក្ដីចំរើនដោយអាហារ;

៣—លិង្គវឌ្ឍនធម៌ សេចក្ដីចំរើនដោយភេទ ។

## អធិប្បាយវិជ្ជាវឌ្ឍនធម៌

ពាក្យថា "វិជ្ជា" ប្រែថា "ការចេះដឹង" ការទំលុះទំលាយនូវសេចក្ដីល្អិត ៗ ដែលហៅថាវិជ្ជានេះ គឺពប់តាំងអំពីវិជ្ជាអក្សរសាស្ត្រ គណិតសាស្ត្រឬវិទ្យាសាស្ត្រគ្រប់ប្រភេទ ដែលជាវិជ្ជាអាចកសាងវត្ថុគ្រប់យ៉ាងសម្រាប់ប្រើប្រាស់ក្នុងសាកលលោក ។ វិជ្ជាទុកជាមិត្រសំឡាញ់ដ៏ខ្ពស់បំផុត ជាទ្រព្យដ៏ប្រសើរដែលគាត់ថ្លៃពុំបាន ។ វត្ថុនវត្ថុផ្សេង ៗ ក្នុងលោកដែលមិនគួរកើតមាន ក៏អាចកើតមានឡើងបាន មានគ្រឿងចក្រ, យន្ត, យាន, វិទ្យុ, ទូរលេខ, ទូរស័ព្ទជាដើម សុទ្ធតែកើតមកអំពីកំលាំងវិជ្ជាទាំងអស់ ។

ប្រជាជនប្រទេសកម្ពុជាយើង បើប្រៀបផ្ទឹមនឹងប្រជាជននៃប្រទេសដែលទាន់សម័យ ឃើញថាចាញ់ប្រៀបគេឆ្ងាយណាស់ គឺនៅក្នុងលេខរៀងចុងគេបំផុត ។ សេចក្ដីចំរើនដោយវិជ្ជាគ្រប់មុខ ឬដោយវិជ្ជាពិសេសណាមួយ ឈ្មោះថា "វិជ្ជាវប្បធម៌" ។ អ្នកប្រទេសយើងមានវិជ្ជានៅទន់ខ្សោយណាស់ កុំថាឡើយដល់ទៅវិជ្ជាជាន់ខ្ពស់មុខណាមួយ សូម្បីតែវិជ្ជាអក្សរសាស្ត្ររបស់ជាតិខ្លួនឯងក៏នៅទន់ខ្សោយ ។ ចំណែកខាងវិជ្ជាហត្ថកម្ម សូម្បីវិជ្ជាធ្វើឈើចាក់ធ្មេញ, ធ្វើទ្រនាប់ជើងឈើ, សម្ងាប់ស្បែកនឹងវិជ្ជាធ្វើសាប៊ូជាដើម ក៏មិនទាន់មានសោះ; ព្រោះហេតុនោះ ជនជាតិយើងនឹងឈ្មោះថាមានវិជ្ជាវប្បធម៌ពុំទាន់បាននៅឡើយទេ ប្រជាជនអ្នកស្នេហាជាតិ កាលបើពិចារណាដល់វប្បធម៌របស់ជាតិ គួរនឹកតូចចិត្ត ឈឺចិត្តជាទីបំផុត, សូម្បីវិជ្ជាសម្រាប់ធ្វើអាហារបរិភោគ ក៏មិនទាន់ចុះរបៀបតាមច្បាប់អនាម័យនៅឡើយ ។ វប្បធម៌ឬអរិយធម៌របស់ជាតិយើង ដែលគួររៀបចំពង្រីកកសាងឡើងជាថ្មីឲ្យបានល្អ ក៏មិនទាន់បានចម្រើន ដោយហេតុតែយើងបណ្ដែតបណ្ដោយខ្លួន អស់កាលជាយូរមកហើយ, ទាំងជនពួកខ្លះដែលបានរៀនអក្សរសាស្ត្រជាតិដទៃ ក៏ចេះតែឈ្លក់គំនិតក្នុងវប្បធម៌របស់គេ ដោយហេតុគេបំប៉នចំណីអាហារគឺយសស័ក្តិ មិនគិតធ្វើប្រទេសជាតិយើងឲ្យមានសេចក្ដីចំរើនឡើងសោះ; ព្រោះហេតុនោះជនជាតិយើងនឹងឈ្មោះថាមានវិជ្ជាវប្បធម៌ពុំទាន់បានឡើយ ។

# អធិប្បាយអាចារវឌ្ឍនធម៌

ពាក្យថា "អាចារៈ" ប្រែថា "ឫកមារយាទល្អ" សណ្ដាប់ធ្នាប់ល្អ, ការប្រព្រឹត្តិរៀបរយ" ។ ការបេះរៀបចំទីកន្លែងទុកដាក់គ្រឿងវត្ថុ សម្រាប់ប្រើប្រាស់មិនខ្ជះខ្ជាយមានរបបបែបបទល្អ ប្រកបដោយអនាម័យ ត្រឹមត្រូវគឺបេះសំអាតខ្លួនប្រាណ, សំអាតសំលៀកបំពាក់ សំអាតទីកន្លែង នៅតាំងអំពីខាងក្រៅផ្ទះ, ក្រោមផ្ទះ, លើផ្ទះព្រមទាំងអាហារបរិភោគ ។ ការប្រកបខ្លួនឲ្យត្រូវតាមរបៀបអនាម័យគឺវិធីបង្ការរោគ ប៉ុណ្ណេះជាដើម ហៅថាមានអាចារវឌ្ឍនធម៌ ។ មួយទៀត ការឈ្លាសវៃក្នុងកិច្ចបដិ-សណ្ឋារៈចំពោះភ្ញៀវសមគួរដល់កិត្តិយសភ្ញៀវ មិនឲ្យទាស់គ្គង ដើម្បីជាទីសរសើរ ជាទីជាប់ចិត្តនៃភ្ញៀវ ដើម្បីបងសាមគ្គីក្នុងរវាងខ្លួនយើងអ្នកម្ចាស់ទីកន្លែងនឹងភ្ញៀវអ្នកមក ប៉ុណ្ណេះក៏ឈ្មោះថា មានអាចារវឌ្ឍនធម៌ ។ មួយវិញទៀត បុរសស្ត្រីអ្នកមានសេចក្ដីចំរើនដោយសីលធម៌ គឺមានកាយវាចាចិត្តរៀបរយល្អ ក៏ឈ្មោះថាអ្នកមានអាចារវឌ្ឍនធម៌ ។

## សីលធម៌ មានសាខា ៦ យ៉ាង

១ – សីលធម៌សម្រាប់សង្គម;

២ – សីលធម៌សម្រាប់ជាតិសាសនាជាមួយគ្នា;

៣ – សីលធម៌សម្រាប់គ្រូនឹងសិស្ស;

៤ – សីលធម៌សម្រាប់មាតាបិតាស្វាមីភរិយានឹងបុត្រធីតា;

៥ – សីលធម៌សម្រាប់ម្ចាស់ផ្ទះនឹងភ្ញៀវ;

៦ – សីលធម៌សម្រាប់ទិសប្រាំ ។

បុរសស្ត្រីចាស់ក្មេងដែលចំរើនបរិបូណ៌ដោយសីលធម៌ ៦ យ៉ាងប៉ុណ្ណេះ ហៅថា អ្នកមានអាចារវត្តនធម៌ ។

## អធិប្បាយលិង្គវត្តនធម៌

ពាក្យថា "លិង្គ" នេះ ប្រែថា "ភេទ" ឬប្រែថា "បែបភាព" បានដល់ភេទស្ត្រីភេទបុរស ដែលមានបែបភាពអាចសំគាល់បានដោយផ្សេងគ្នា ។ ភេទនៃបុរសស្ត្រីនេះតែងជាប់ទាក់ទងដោយគ្រឿងស្លៀកពាក់ គឺថាគ្រឿងស្លៀកពាក់នេះរាប់ថាជាបច្ច័យមួយជាជំនួយដល់រាងកាយធ្វើរាងកាយឲ្យថ្កើងថ្កានតាមកាលសម័យ ដែលហៅថា អ្នកមានគ្រឿងស្លៀកពាក់ចុះបែបល្អ ។

របៀបពណ៌សំពត់អាវសម្រាប់ស្លៀកពាក់មានច្រើនយ៉ាង មានពណ៌សខ្មៅជាដើម ។ សូមសង្កេតមើលរបៀបស្លៀកពាក់របស់ប្រជាជនឯកពង្សគ្រប់ប្រទេសចុះមិនសូវឃើញប្រើប្រាស់ពណ៌ខ្មៅទេ ។

ក្នុងប្រទេសឥណ្ឌាសម័យបុរាណ គេចាត់វណ្ណៈ គឺជាតិត្រកូលឬពណ៌ស្លៀកពាក់មាន ៤ ពួក :

១ – ពួកក្សត្រស្លៀកពាក់ពណ៌ផ្សេង ៗ វៀរលែងតែពណ៌ខ្មៅ;

២ – ពួកព្រាហ្មណ៍ស្លៀកពាក់ពណ៌ក្រហមចាស់;

៣ – ពួកវេស្សៈ គឺអ្នកជំនួញ, អ្នកធ្វើស្រែចំការស្លៀកពាក់ពណ៌ខៀវ, ពណ៌ស ឬក៏ពណ៌លាយចំរុះ;

៤ – ពួកសូទ្រៈ ស្លៀកពាក់ពណ៌ខ្មៅសុទ្ធ ៗ

មនុស្សអ្នកឥណ្ឌៀក្នុងសម័យនោះ គេបញ្ញត្តរបៀបពណ៌ស្លៀកពាក់តាមឋានៈនៃជាតិត្រកូលដូចពោលមកនេះ ៗ ពណ៌ស្លៀកពាក់ខាងលើនេះសឲ្យឃើញថាពណ៌ខ្មៅជាពណ៌សម្រាប់មនុស្សថោកទាប ឬសម្រាប់សំគាល់ឲ្យដឹងថា បើអ្នកណាស្លៀកពាក់ពណ៌ខ្មៅអ្នកនោះឈ្មោះថាជាអ្នកមានខ្លួនចាំទទួលស៊ីឈ្នួលធ្វើការឲ្យគេ ព្រោះហេតុនោះពណ៌ខ្មៅទុកថាជាពណ៌សម្រាប់ទាសកម្មករ ឬពណ៌គូលី ដូច្នេះក៏បាន ៗ មួយទៀត អ្នកប្រទេសទាន់សម័យបច្ចុប្បន្ននេះ ច្រើននិយមពណ៌ខ្មៅជាពណ៌ហែខ្មោចដោយគេយល់ថាមនុស្សយើងដែលស្លាប់ទៅជាខ្មោចហើយមិនអាចកែប្រែបានឡើយ, ចំណែកពណ៌ខ្មៅសុទ្ធក៏ឈ្មោះថាជាពណ៌កែមិនឡើងដូច្នោះដែរ ព្រោះហេតុនោះបានជាគេស្លៀកពាក់ពណ៌ខ្មៅដែលជាពណ៌កែមិនឡើងទៅហែខ្មោចដែលកែមិនឡើងដូចគ្នា ឬថាពណ៌ខ្មៅជាពណ៌កាន់ទុក្ខចំពោះខ្មោចដូច្នេះក៏បាន ៗ ប្រជាជនអ្នកទាន់សម័យដែលមានដំណើរតាមរថយន្ត, តាមកប៉ាល់ឬចូលកាន់ទីប្រជុំមានទីផ្សារ ទីប្រជុំបុណ្យជាដើមមិនប្រើគ្រឿងស្លៀកពាក់ពណ៌ខ្មៅទេ ៗ គ្រឿងស្លៀកពាក់ពណ៌ខ្មៅគេប្រើប្រាស់តែក្នុងកាលដែលគួររាស់កាប់គាស់, នេសាទត្រី ៗ

មួយទៀត ពណ៌ខ្មៅជាពណ៌របស់មនុស្សមោហចរិតដែលច្រើនដោយសេចក្តីខ្ជិលច្រអូសក្នុងការគត់លាន់ ។ ពណ៌ខ្មៅអាចលាក់បិទបាំងនូវមន្ទិល គឺថា បើមានវត្ថុស្មោកគ្រោកប្រឡាក់មើលមិនសូវឃើញដោយច្បាស់លាស់ ។

គ្រឿងសម្លៀកបំពាក់ពណ៌ខ្មៅដូចរៀបរាប់មកនេះឈ្មោះថាជាពណ៌ថោកទាប មិនរាប់ថាជាពណ៌ប្រកបដោយវឌ្ឍនធម៌ឡើយ ។ មួយទៀត របៀបខោអាវដែលជាអ្នកកាត់ដេរ មានបែបផែនទាន់សម័យនិយមនោះ ដើម្បីតម្រូវតាមភេទបុរសស្ត្រីអ្នកទាន់សម័យ ។ ចំណែកខាងរាងកាយបុរសស្ត្រីដែលប្រដាប់ដោយសំលៀកបំពាក់ទាន់សម័យដូច្នេះទើបឈ្មោះថាអ្នកមានលិទ្ធិវឌ្ឍនធម៌ ។ ចុះប្រជាជនជាតិយើងមានវឌ្ឍនធម៌បរិបូណ៌ហើយឬនៅ ?

ព្រះទេពសត្ថា

ស្វា - ហាយ

វឌ្ឍនធម៌ ២ ដ៏បវរ

១ – វឌ្ឍនធម៌ ខាងសាសនា

២ – វឌ្ឍនធម៌ ខាងលោក

សម័យនេះណា៎ ខ្មែរគួរមាន

ប. ត.

# អក្សរសាស្ត្រ ជាជីវិតរបស់ជាតិ

អក្សរសាស្ត្រខ្មែរ

( គពីសៀវភៅ លេខ ១- ២- ៣ ឆ្នាំ ១៩៥២)

## មាត្រភាសាមានពីរយ៉ាង

ក) ភាសាឡាតាំង (latin) និងភាសាក្រិក (grec) ដែលជាបុព្វហេតុឲ្យកើតភាសា ខាងអឺរ៉ុប និងអាមេរិក;

ខ) ភាសា អរិយៀង (Langue Aryenne) មានភាសាសំស្ក្រឹត (Sanscrit) និងបាលី (Pali) ដែលជាបុព្វហេតុឲ្យកើតខេមរភាសា, សៀមភាសា, ភូមាភាសា, ឥណ្ឌូភាសា ជាដើម ។

តើភាសាឡាតាំង និងសំស្ក្រឹត ឬបាលីមានបឋមហេតុ ដូចគ្នាឬ? ប្រហែលជាដូចគ្នា ពីព្រោះបានសង្កេតមើលពាក្យឡាតាំងខ្លះមានសភាពដូចគ្នា និងពាក្យសំស្ក្រឹត ឬបាលី ដូចភាសាឡាតាំងថា « Navis » បានយកមកប្រើជា Navire, Navigation, Naviguer ជាដើម ពាក្យបាលីថា "នាវា" ខ្មែរយកមកប្រើជានាវា នាវិក, នាវិកសាស្ត្រ, នាវាចរ ។ល។ ឬពាក្យឡាតាំងថា « Mori » បានយកមកប្រើជា «Mourir», Mort, Mourant, Mortel, Moribond

ជាដើម ពាក្យបាលីថា "មរ" ខ្មែរយកមកប្រែជាមរណៈ មរណកាល មរណវេទនា មរណសញ្ញាជាដើម ។

គ) ភាសា, បើចែកមួយបែបទៀត មានពីរយ៉ាង គឺ:

១) ភាសាឥណ្ឌូ-អឺរ៉ុប៉ែន (Langue Indo-Européenne) ដែលមានជាតិមានចំនួនជាងពាក់កណ្ដាលក្នុងសាកលលោក យកទៅនិយមប្រើ មានភាសាសែរម៉ានិក (Langue germanique) ភាសាក្រេកូ-រ៉ូម៉ាន (langue Gréco-Romane) ភាសាអ៊ីរ៉ានីអែន (langue iranienne) ជាដើម;

២) ភាសាស៊ីណូ-ទីបេតែន (Langue sino-thibéitaine) ដែលមានភាសាចិន, ជប៉ុន ជាដើម មានជាតិចំនួន ១ ក្នុងភាគ ៤ ពោលនិយាយក្នុងផែនដីនេះ ។

ឃ) ភាសាបើចែកតាមផ្លូវរូបសាស្ត្រ មាន ៣ យ៉ាង គឺ:

១) ភាសាឯកព្យាង្គ (Langue Monosyllabique)

២) ឯកឃ្លាភាសា (Langue agglutinamte)

៣) ភាសាដែលមានវិភត្តិ (Langue à flexion ou flexionnelle)

ង) បើតាមយោបល់ខ្ញុំ, ភាសាមានជាប្រាំយ៉ាងទៀត គឺ:

១) ភាសានៃមនោធម៌ (Langue de l'esprit)

២) ភាសានៃអរិយាវៈដៃជើង សម្មតិប្រើជាផ្លូវការ

(langage du geste)

៣) ភាសាកញ្ចែរបិយន្ត, ត្រែកងទ័ពជើងគោក – ទឹក អាកាស ។ល។

៤) ភាសាសត្វ. មនុស្ស, ភូត, បិសាច, ទេវតា តាមភូមិគ្រប់ភូមិ, ភាសាព្រហ្ម, ភាសាលោកុត្តរភូមិ, ភាសាព្រះនិព្វាន, ភាសាស្ពានព្រះនិព្វាន ប្រហែលជាភាសាដែលជាបឋមហេតុនៃភាសាទាំងអស់ ទាំងផ្លូវលោក - ធម៌ - គឺភាសាស្ងាត់ (La voix du silence) ឬភាសាអាទិទេព (La voix divine) ដែលយប់ស្ងាត់, បើយើងផ្ទៀងសោតបសាទស្ដាប់ មានឮសំឡេងក្នុងហទយវត្ថុ ឬបើធ្វើសមាធិកម្មដ្ឋានរហូតដល់អប្បនាចិត្ត គឺចិត្តមូលជា ឯកគ្គតារម្មណ៍ ព្រោះយោគាវចរអាចឮបាននូវសំឡេងស្ងាត់នោះ គឺសំឡេងខាងក្នុង ។

## ៣) លក្ខណៈនៃភាសា

## ភាសាមានលក្ខណៈ បីយ៉ាង

ក) សូរសាស្ត្រ ឬ «phonétique» ពិនិត្យខាងសំឡេងនឹងវិធីអាន ;

ខ)- រូបសាស្ត្រ ឬ «morphologie» ពិនិត្យខាងរូបរបស់ពាក្យ ដែលប្រែប្រួលទៅតាម លិង្គ, វចនៈ, បុរិសៈ, គាថា, ប្រយោគ ។ល។

គ) និយមន័យសាស្ត្រ ឬ វាក្យសព្ទ (sémantique ou vocabulaire) ពិនិត្យខាងអត្ថរបស់ពាក្យ ព្រមទាំងប្រវត្តិរបស់ពាក្យ ។

## ក) សូរសាស្ត្រ

អក្សរដែលមានសំឡេងតឹងហៅថា អឃោសៈ អក្សរដែលមានសំឡេងធំហៅថា ឃោសៈ ។ អឃោសៈ (sourd) ដែលមានសំឡេងមិនគឹកកង ។ ឃោសៈ (sonore) ដែលមានសំឡេងគឹកកង ។

ស្រៈដែលមានសំឡេងខ្លីហៅថា រស្សៈ, ស្រៈដែលមានសំឡេងវែងហៅថា ទីឃៈ ។

ឋានកើតនៃព្យញ្ជនៈ តាមកន្លែង លោកចែកសំឡេង ដូចតទៅនេះ គឺ កណ្ឋជៈ (gutturales) កើតនៅក, តាលុជៈ (palatales) កើតនៅក្រអូមមាត់, មុទ្ធជៈ (Cérébrales ou linguales) កើតនៅក្បាល, ទន្តជៈ (dentales) កើតនៅធ្មេញ ឱដ្ឋជៈ (labiales) កើតនៅបបូរមាត់, នាសិកជៈ (nasales) កើតនៅច្រមុះ ។

ព្យញ្ជនៈសិថិលមានសំឡេងធូរ, ស្រុង, ស្រាល, ធនិត មានសំឡេងតឹង, បង្អៀត, ធ្ងន់ ៗ ព្យញ្ជនៈមានសិថិលអឃោសៈ, សិថិលឃោសៈ, ធនិតអឃោសៈ និងធនិតឃោសៈ ទៀត ៗ

ក្រៅពីនេះនៅមានសំឡេង ដែលកើតឡើងដោយព្យញ្ជនៈផ្សំនឹងស្រៈ ឬព្យញ្ជនៈ ផ្សំនឹងព្យញ្ជនៈ ឬវិធីអានពាក្យទៅតាមភាសាសព្វជាតិក្នុងសាកលលោកព្រមទាំងច្បាប់សូរសាស្ត្រ, លក្ខណៈផ្សេង ៗ នោះសូមទុកឲ្យវេយ្យាករណិកបណ្ឌិតពណ៌នាឲ្យបានសព្វគ្រប់ចុះ, យើងពិចារណាត្រឹមតែអក្សរសាស្ត្រ និងភាសាសាស្ត្រដោយសង្ខេបប៉ុណ្ណោះ ៗ

## ២) រូបសាស្ត្រ

រូបសាស្ត្រមាននាម, លិង្គរបស់នាម, វចនៈ, កិរិយាសព្ទ, សព្វនាម, វិសេសសព្វនាម, កិរិយាវិសេសនៈ, និបាតសព្ទ, សំខ្យាសព្ទ, បុព្វបទ, អាគម, ឧបសគ្គ, សម្ពន្ធ, សមាសនាម ៗ ល ៗ ទៅតាមច្បាប់វេយ្យាករណសាស្ត្រ គ្រប់ភាសា គ្រប់ជាតិ ៗ

## ៣) និរុត្តិសាស្ត្រ ឬ វាក្យសព្ទ

គឺពិនិត្យអត្ថរបស់ពាក្យ ទៅតាមលក្ខណភាសាគ្រប់ជាតិ ៗ

## ៤) អំបូរនៃភាសា

អំបូរនៃភាសា គឺត្រកូលភាសា, ពូជភាសា ឬវង្សភាសា; អំបូរនៃភាសា មានអំបូរឥណ្ឌូ-អឺរ៉ុប ១, អំបូរភាសាសេមីទិក (sémitique) ១

អំបូរភាសាម៉ាឡាយូ ប៉ូលីណេស៊ី (Malayo - polynésienne) ១, អំបូរភាសាមន - ខ្មែរ ១ ជាដើម ។

អំបូរភាសាឥណ្ឌូ - អឺរ៉ុប ដែលគេប្រើនៅកលទួលខ្ពស់ ប៉ាលមីរ (Plateau de Palmyr) មានភាសាសំស្ក្រឹត, បាលី, ភាសាប្រទេសឥណ្ឌៀ, ភាសាហិណ្ឌូស្ថានី, ភាសាប៉ែរ្ស, អារមេនី, ក្រិក, ឡាតាំង និងភាសាជាតិអឺរ៉ុបជាច្រើន ។

អំបូរភាសាសេមីទិកមានភាសាអារ៉ាប់, ហ៊ីប្រូ អស្សុរីយាន់, អាប៊ីស៊ីនី ជាដើម ។

អំបូរភាសាម៉ាឡាយូ ប៉ូលីណេស៊ី មានភាសាចាម, ភាសាម៉ាឡាយូ, ភាសាម៉ាដាកាស្កា, ភាសាសុម៉ាត្រា, ភាសាជ្វា, ភាសាបរណេអូ, ម៉ានីល ជាដើម ។

អំបូរភាសាមន - ខ្មែរ មានភាសាខ្មែរ, ភាសាមន, ភាសាប៉ាឡុង, ភាសារៀង, ភាសាកា, ភាសាធិន, ភាសាឃ្មុ, ភាសាព័រ, ភាសាជង, ភាសាកួយ, ភាសាស្ទៀង, ភាសាពនង ជាដើម ។

## ៥) វិវត្តន៍នៃភាសា

អ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ ដូចជាលោកអេឌីសុន (Edison) ឬលោកហែរត្ស (Hertz) ជាដើម បានរកមេសំឡេងឃើញ បានជា

សំឡេងទាំងអស់តែមកចូលជាសម៉ាស៊ីនច្រៀង (គឺតយន្ត phonographe) ឬ ទូរសព្ទ (téléphone) ព្រមទាំងទូរសព្ទឥតខ្សែ (téléphone sans fil) នេះផ្នែកខាងផ្លូវលោក ។

បើខាងចិត្តវិជ្ជា (psychisme) ពោលថា: " សំឡេងដែលយើងពោលទាំងអម្បាលម៉ានទៅតាមលក្ខណៈពាក្យ ដែលពោលដូចជាពាក្យថា: អញបំរុងនឹងសម្លាប់ឈ្មោះនេះ, នោះ, ពាក្យនេះឲ្យផលអាក្រក់; បើទុកជាមិនទាន់ឲ្យផល ក៏កំសួលពាក្យដែលពោលនោះឡើងទៅលើអជតាកាស ទៅជួបប្រទះនឹងពាក្យសំដីអ្នកដទៃ, ជាតិនានាប្រទេសក៏ចូលមូលជាសាច់មួយ ដែលហៅថាសម្ពន្ធធាតុ (Attraction) បើពាក្យនោះមានសភាពដូចគ្នា, តែបើពាក្យនោះមានសភាពខុសគ្នាវិញ ទៅជាចៀសចេញពីគ្នា ដែលគេហៅថា អសម្ពន្ធធាតុ (répulsion) ។

ហេតុដូចនេះបានជាថា បើប្រទេសណាមានសង្គ្រាម, ប្រទេសជិតខាង (សាមន្តគ្រាម) មិនយូរមិនឆាប់ មុខជាកើតសង្គ្រាមមិនខាន; មកពីអ្វី? មកពីពាក្យដូចជាពាក្យខាងលើនេះ ហុយទៅលើអាកាសទៅប៉ះនឹងពាក្យជន ដែលនៅប្រទេសជិតខាងនោះមានខ្សែចិត្តដូចគ្នា វេញចូលគ្នាទៅជាសំណុំចិត្តមួយ មានរូបភាពតែមួយ (cristallisation) ហើយរូបភាពនោះ បើចិត្តច្រើនមានសភាពដូចគ្នា ក៏ប្រមូលមកមូលជាឯកភាពអាចឲ្យផលអាក្រក់ល្អទៅតាមលក្ខណៈពាក្យនោះៗ ។

ភាសាអាចវិវត្តទៅបានដល់ភាសាពោលជាសំឡេង មានពណ៌តាមភាពសំឡេង ដែលអ្នកវិទ្យាសាស្ត្រសម័យថ្មី បានរកឃើញរហូតដល់មាត់ទិព្វ ( ទិព្វកថា ) ជាបរិយោសាន ។

ក្នុងទីនេះ យើងមិនអាចពោល នូវលក្ខណៈពាក្យសំឡេងគ្រប់យ៉ាង ឬវេយ្យាករណ៍របស់ពាក្យ, សំដី, ព្រមទាំងបុព្វហេតុនៃពាក្យជាដើមទេ, យើងទុកឲ្យបណ្ឌិតខាងវេយ្យាករណ៍ ឬខាងភាសាសាស្ត្រ, សូរសាស្ត្រដែលមានសមត្ថភាពខាងការស្រាវជ្រាវ នូវបឋមហេតុនៃសំឡេងសត្វ, មនុស្សទេវតា ។ល។ ស្វែងរកតទៅអនាគត ។

ប៉ាយ - ប៊ុក

( មានគ )

អក្សរខ្មែរបម្រើន នាំបង្កើនឲ្យខ្មែរប្រើ
ក្តីក្តើងជាងសព្វប្រើ បានស៊ីវិឡែទៅប្រើមុខ ។

ប. ព.

# ខេមរវេយ្យាករណ៍

(គតិសៀវភៅលេខ ១ – ២ – ៣ ឆ្នាំ ១៩៥២)

---

## វណ្ណយុត្តិ

(៧) គ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរហៅថា វណ្ណយុត្តិ; វណ្ណយុត្តិសម្រាប់ប្រើក្នុងភាសាខ្មែរមាន ១៨ យ៉ាង គឺ:

១ – វិសជ៌នីយ ឬវិសគ៌ៈ ឬរះមុខ (ះ)

២ – មូសិកទន្ត ឬ ធ្មេញកណ្ដុរ (៉)

៣ – ត្រីសព្ទ (៊)

៤ – ទណ្ឌឃាត ឬ បដិសេធ (៍)

៥ – របាទ ឬ រេផៈ (៌)

៦ – រស្សសញ្ញា ឬ បន្តក់ (់)

៧ – សំយោគសញ្ញា (័)

៨ – លេខទោ ឬ អាមេណ្ឌិតសញ្ញា (ៗ)

៩ – លេខអស្តា (៏)

១០ – កាកបាទ ឬ ជើងក្អែក (+)

១១ – កុក្កុដនេត្រ ឬ ក្អែកមាន់ (៙)

១២ – ល្បះ ឬ ខណ្ឌ (។)

១៣ – ល្បះចប់ ឬ ល្បះបរិយោសានឬគំខណ្ឌបរិយោសាន (៕)

១៤ – គោមូត្រ (៚)

១៥ – ពាក់ ឬ គាប ({)

១៦ – វដ្ឍុលេខា (–)

១៧ – មច្ឆណ្ឌសញ្ញា ឬ ពងត្រី (...)

១៨ – បេយ្យាល (។ល។) ឬ (។បេ។)

ជា ១៩ ទីឯយុគលពិន្ទុ (:) ដែលទើបនឹងបង្កើតថ្មី សម្រាប់ប្រើចុះសម្រួលពាក្យឲ្យឆាយថា ដូចជាធុរៈ, ការៈ ព្យូហៈ លក្ខណៈ ជាដើម ។

ក្រៅពីនេះ មានប្រើវណ្ណយុត្តិរបស់អឺរ៉ុបផងគឺ , ; : ? ! < > “ ” ( ) – សម្រួលតាមសម័យនិយម ។

## វិធីប្រើវណ្ណយុត្តិ

(៨) វិសជ្ជនីយ ឬ វិសគ្គៈ ខាងអក្សរទេវនាគរី (សម្រាប់សំស្ក្រឹត) ប្រើជាចំណុចមួយគូលើក្រោម ដូចយុគលពិន្ទុ (:) មានសូរសំឡេងស្រ-ដៀងនឹងខ្យល់អក្សរ ស ដែលជាតួប្រកប ប៉ុន្តែមិនចេញសូរសមួស្យ តាមប្រទល់ដេញដូចតួ ស ទេ, ដូចជា កន្ទុះ, ពោះ សូរខុសគ្នានឹងកន្ទាស់ ពស់ ។ ពាក្យសំស្ក្រឹតដែលមានតួ ហ នៅខាងចុង បើផ្លាស់ ហ ជាវិសគ្គៈ (:) ហើយមិនត្រូវប្រើហថែមទៀតទេ ដូចជា គុហា, ចន្ទ្រ-គ្រាហ, សំគ្រហ, អនុគ្រហ, ទៅជា គុះ ឬ គ្រឹះ ចន្ទ្រគ្រាះ, សង្គ្រោះ, អនុគ្រោះ កុំប្រើជាគ្រឹះហ៍, ចន្ទ្រគ្រាះហ៍ សង្គ្រោះហ៍ អនុគ្រោះហ៍ ដូច្នេះជាដើមឡើយ ។

មូសិកទន្ត "ធ្មេញកណ្ដុរ" ខ្មែរយើងប្រើជាវណ្ណយុត្តិមួយយ៉ាង មានរូបជាគំនូសក្បៀសពីរ សណ្ឋានស្រដៀងនឹងធ្មេញកណ្ដុរ ( ៉ ) សម្រាប់ប្រើសម្រាប់បំបែរសំឡេងព្យញ្ជនៈ ៩ តួគឺ ង, ញ, ន, ប, ម, យ, រ, ល, វ ឲ្យមានសំឡេងជា ង៉, ញ៉, ន៉, ប៉, ម៉, យ៉, រ៉, ល៉, វ៉, នឹងប្រើដាក់ពីលើស្រៈ ិ ឲ្យជា ី ឬជាសម្រាប់ថែមលើអក្សរនៅខាងដើមព្យាង្គពាក្យ កាលណាពាក្យនោះ គ្មានសព្វព្យាង្គឯទៀតបន្ថែមមក ឬព្យាង្គនោះ ទោះជាប់តែឯង ដូចជា ប៉ុន្តែ, បុណ្យស៊ាន ញុំាញុី... បើកាលណាតួអក្សរដើមព្យាង្គបន្ថែមមកមិនត្រូវដាក់មូសិកទន្ត ( ៉ ) ទេ ដូចពាក្យថា ប្រមាទ ប្រមោយ, ស្រវឹង, បម្រុង, សង្កាត... ជាដើម ។

ត្រីសព្ទ "សូរសំឡេង ៣ យ៉ាង" ខ្មែរយើងប្រើជាឈ្មោះគ្រឿងវណ្ណយុត្តិ ( ៊ ) នេះ សម្រាប់ប្រើដាក់លើអក្សរ ៤ តួគឺ ប, ស, ហ, អ, ឲ្យមានសំឡេងធំជា ប៊, ស៊, ហ៊, អ៊, ដូចពាក្យថា ប៊ុត, ប៊ុន, ស៊ងស្វា, ពុ-ស៊ាន, ស៊ុន, សំដី, មិនហ៊ានទៅ, ចូលហ៊ុន, ដំណើរអ៊ឹកអ៊ាក, ក្រួបអ៊ុត អ៊ុះ អ៊ុះ... ជាដើម ប៉ុន្តែតួ ស កាលបើមានស្រៈ ិ ី នៅពីខាងលើនឹងផ្លាស់រូប ( ៊ ) នេះចេញ ដូចយ៉ាងសុីបាយដូច្នេះជាដើមវិញក៏បាន ។

ទណ្ឌឃាត សម្រាប់ប្រើបដិសេធតួអក្សរដែលលើសពីការ ដូចជា រ័តន៍ កេទ៍ ប្រយោជន៍ ស្រមណ៍ ជាដើម ។

របាទ "ជើងអក្សរ "រ" (ហៅដោយសន្មត), ខ្មែរយើងប្រើតាមបែបរេផៈ សំស្ក្រឹត មានរូបសណ្ឋានដូច្នេះ (-) ក្លាយរូបមកទៀតជា (៍) ក្នុងសិលាចារិកខ្មែរបុរាណច្រើនប្រើ "រ" ពេញតួ. សម្រាប់ប្រើដាក់អក្សរតួចុង ឲ្យអក្សរតួដើមបន្ទាប់នោះមានសូរសំឡេងញ័រ, ប្រើចំពោះតែភាសាសំស្ក្រឹត ឬ សំស្ក្រឹតក្លាយ ដូចជា ត័ក៌, ទុគ៌ត, ទុព៌ល, ធម៌, បព៌ត, ព័ណ៌, អាថ៌, ជាដើម. តែបើមានស្រៈដែលទើសពិបាកសរសេរ នោះត្រូវដាក់អក្សរ "រ" ពេញតួ ពីលើជើងអក្សរខាងចុងវិញ ដូចជា ទុរ្ភិក្ស, បូរ្ណ, កមកេរ្តិ៍, តិរ្យ . . . ជាដើម, ជួនកាលមិនមានស្រៈទើសទែងទេ ប៉ុន្តែគួរឲ្យប្រចឡំពិបាកអានក៏ត្រូវដាក់តួ "រ" លើជើងអក្សរខាងចុងបានដែរ ដូចជា កមិ៌ន អស្ចាយ៌, អាចាយ៌ . . . បើជា កម្ម័ន, អស្ចារ្យ, អាចារ្យជាដើម (ប្រើសម្រួលឲ្យងាយមើលងាយថា) ។

បើមានអក្សរ "រ" ជាតួប្រកបពីខាងចុង ទឹងប្រើរបាទនេះផងមិនបានទេ ដូចជា ជ័រ, ដើមសង្ស័រ, ញ័រ, ទទ័រ . ជាដើម (យ៉ាងនេះត្រឹមត្រូវហើយ), កុំសរសេរជា ជ័រ៌, ទទ័រ៌, ញញ័រ៌, ឬ ជារ៌, ទទារ៌, ញញារ៌, ឬក៏ ទទារ, ជារ, ញញារ, ដូច្នេះឡើយ ។

តួអក្សរណាដែលមិនសូវប្រើផើជើងគ្រវាត់ តួតម្រួតអក្សរនោះ ផ្លាស់ជារបាទ (៍) ។ បើតួអក្សរណាធ្លាប់ប្រើគ្រវាត់ក្នុងផើជើង តួតម្រួតអក្សរនោះផ្លាស់ជា "រ" គ្រវាត់ ។

តួតម្រួតផ្លាស់ជារបាទ ( ៌ ) ដូច្នេះ

ណ្ណ > ណ៌, ម្ម > ម៌, ត្ត > ត៌, ក្ក > ក៌, វណ្ណ > ពណ៌, ធម្ម > ធម៌, គក្ក > គក៌, បុញ្ញ > បូញ៌, បរិបុណ្ណ > បរិបូណ៌ . . . ។

តួតម្រួតផ្លាស់ជា "រ" គ្រាត់ដូច្នេះ

បក្ក > បក្រ, ខត្ត > ក្សត្រ, បុត្ត > បុត្រ, សមុទ្ទ > សមុទ្រ, ប៉ុន្តែ មានអក្សរខ្លះ ដែលធ្លាប់មានជើងជើងគ្រាត់ ជាប់ដោយរបាទខ្លះក៏មានដែរ ដូចជា កក្កដ > កក៌ដ, វិសជ្ជនីយ > វិសជ៌នីយ, មគ្គ > មាគ៌ា, សគ្គ > សូគ៌ - សួគ៌ . . . ជាដើម ។

រស្សសញ្ញា "គ្រឿងសំគាល់ឲ្យដឹងថាមានសំឡេងខ្លី" ពាក្យនេះ វេយ្យាករណបណ្ឌិតខ្មែរ សន្មតជាឈ្មោះវណ្ណយុត្តិមួយយ៉ាង មានសណ្ឋានកំបុតខ្លីនេះ ( ់ ) សម្រាប់ប្រើបំបែរសំឡេងវែង ឲ្យខ្លីកំបុតផុន, ប្រើដាក់បានចំពោះតែតួអក្សរប្រកបរបស់ពាក្យខ្មែរដែលជាស្រៈ អ, អា, ពីរនេះ ដូចជា អត់, កត់, ចប់, ដល់ អាក់, កាន់, ស្គាល់ . . . ជាដើម (ហៅថា "សក្កត់ឬបន្តក់ សៀមហៅថា ម៉ៃអេក ប្រែថា "ឈើមួយ" សម្រាប់ប្រើបំបែរសំនៀងដោយវិធីផ្សេងពីខ្មែរយើង ) ។ វៀរលែងតែស្រៈ "អា" ប្រកបនឹង "ង" ដែលប្រើបំបែរសំឡេងវែង ឲ្យជាសំឡេងខ្លី នោះត្រូវដាក់និគ្គហិត ( ំ ) ពីលើស្រៈ "អា" ដូចជា កាំង, ចាំង, ប៉ាំង, តាំង, ពាំង . . . ជាដើម ។

ឯអក្សរជាតួប្រកបរបស់ពាក្យ ហើយមានសមត្ថភាពអាចទទួលសញ្ញាបន្តក់ (់) បាន មានតែអក្សរ ក, ង, ច, ញ, ត, ន, ប, ល, ស, ប៉ុណ្ណោះទេ, អក្សរក្រៅពីនេះ ទោះកាត់សំឡេងវែងជាទីក៏ដោយ ក៏មិនទទួលវណ្ណយុត្តិបន្តក់ (់) ដែរ ដូចជា បទ, បថ, សត្វ, កព . . . ជាដើម; ប៉ុន្តែបើពាក្យណាដែលចេញមកពីបាលី ឬសំស្ក្រឹត ទោះអក្សរដែលត្រូវទទួលបន្តក់ (់) បានក៏មិនត្រូវដាក់បន្តក់ (់) ដែរ ដូចពាក្យថា: កុសល, ផល, ធនធាន, ជន, លាមក, ទុគ៌ត, ទុព៌ល . . . ជាដើម ។

សំយោគសញ្ញា "គ្រឿងសំគាល់អក្សរតម្រួត" យើងប្រើជាឈ្មោះវណ្ណយុត្តិមួយយ៉ាង មានសណ្ឋានដូច្នេះ (័) ជាជំនួសអក្សរសំយោគ សម្រាប់ដាក់លើពាក្យមគធ ឬសំស្ក្រឹតពួកខ្លះ ដែលប្រើបំប្លែងសំឡេងឲ្យក្លាយល្អៀងពីសូរដើម, កាលបើមិនដាក់ (័) នេះ នាំឲ្យពិបាកថា: ដូចជា ក្ស័យ, ជ័យ, ទ័ល, នង្គ័ល, ពិន័យ, ពិកល័យ, ភ័យ, រហ័ស, រំហ័ស, វេស្ម័ន, វេស្សវ័ណ អនាម័យ, អាល័យ, អាស្រ័យ . . ជាដើម ។ ទោះបើពាក្យដែលមានអក្សរសំយោគហើយ ប៉ុន្តែបើមិនដាក់ (័) នេះផ្សំផងទេ នាំឲ្យពិបាកថា ត្រូវប្រើសំយោគសញ្ញាថែមទៀតក៏មានខ្លះ ដូចជា គ័ភ៌, ទក្ខិណាព័ត៌, ព័ណ៌, ព័ទ្ធ, ព័ន្ធ, ពិទ័ទ្ធ, ពិភ័ក្តិ, ភ័ព្វ, ម្រ័ក្សណ៍, យ័ន្ត, ឬយ័ន្ត្រ, ល័ទ្ធ . . ជាដើម ។ សម្រាប់ពាក្យខ្មែរក៏មានខ្លះ ដូចជា ទ័រ, ជ័រ, ញ័រ, ទទំរ, ទូទ័រ, ទំព័រ, ទំប៉ុង, សូរប៉ុងៗ, ភ្ល័រ, ដើមសំព័រ,

ស្ពានជ័រ... ជាដើម ។ សម្រាប់ប្រើភាសាដទៃក៏មានខ្លះ ដូចជា កុងត្រូល័រ, ឌីរិកទ័រ, អ័ងស្ប៉ិកទ័រ... ជាដើម ។

លេខទោ ឬ អាមេណ្ឌិតសញ្ញា "លេខផ្ទួន ៗ គ្រឿងសំគាល់ពាក្យផ្ទួន", ខេមរៈ យើងប្រើជាឈ្មោះវណ្ណយុត្តិមួយយ៉ាង មានសណ្ឋានខាងក្បាល ឬ ខាងលើជាលេខ ២ ប៉ុន្តែខាងកន្ទុយ ឬ ខាងក្រោមទាញចុះ (ៗ) នេះ សម្រាប់សរសេរពីខាងចុងពាក្យដែលត្រូវថាផ្ទួន ដូចជា ផ្សេងៗ, ទទៃៗ, តូចៗ, ធំៗ, ប្អូនៗ, បងៗ, ប្រុសៗ, ស្រីៗ... ជាដើម ។

ប៉ុន្តែពាក្យមគធៈ ដូចជា អាបោ, អាបោ...ជាដើម កុំប្រើ អាបោៗ ត្រូវប្រើ អាបោ អាបោ តាមរូបដើម ។

លេខអស្ដា "លេខ ៨" វណ្ណយុត្តិនេះសម្រាប់ដាក់លើអក្សរពោល កញ្ចក់សំឡេងឲ្យខ្លីរហ័ស ដូចជាៈ ក៏បាន, ក៏ដោយ, ដ៏ប្រសើរ, ឮង៏អាកាស, ហ៏, ហ៏យកចុះ ! ន៎ុះន៏ !, អុញន៏ ! ។

កាកបាទ "ជើងក្អែក" សម្រាប់ដាក់លើពាក្យឧទានសព្ទ ឬ លើពាក្យគួរឲ្យស្រណោះ នឹងពាក្យវិសេសនសព្វនាមខ្លះ ដូចជាៈ ក៎ុក !, ប៎ះ !, ចា៎ !, បងណាហើយណា៎ប្អូនណា៎ !, ន៎ុះ, ន៎ុះន៏ ។

កុក្កុដនេត្រ "ក្អែកមាន់" សម្រាប់ដាក់ដើមសេចក្តី (តែសម័យបច្ចុប្បន្ននេះ មិនសូវប្រើទេ) ។

ល្បះ សម្រាប់ប្រើរះរាំងឃាត ឬ សង្កាត់សេចក្ដីមួយៗ ឲ្យដាច់ស្រឡះដោយឡែក ល្បះខ្លី, ល្បះវែង, (ខណ្ឌ) ។ ល្បះលូកបន្ទាត់ គឺល្បះដែលរះនៅបន្ទាត់មួយខាងលើ ហើយត្រូវសរសេរត្រង់បន្ទាត់មួយខាងក្រោម បន្ទាត់នោះលូកចូលមកក្នុងបន្ទិច (ខណ្ឌដក) ។

ល្បះចុះ ឬ ល្បះបរិយោសាន មានរូបយ៉ាងនេះ (។ៗ) ឬ យ៉ាងនេះ (។ ៚—) ឬក៏យ៉ាងនេះ (។ ៚—) សម្រាប់ដាក់ក្នុងទីបំផុតនៃសេចក្ដីមួយៗ ឬ រឿងមួយ ៗ ដែលចប់ស្រេចហើយត្រឹមតែប៉ុណ្ណោះ (ខណ្ឌបរិយោសាន), ល្បះទាំង ៣ បែបក្រោយនេះ មិនមានកំណត់ឲ្យប្រើដោយដាច់ខាតទេ, ប្រើក៏បានមិនប្រើក៏បាន, ប្រើត្រឹមតែប៉ុណ្ណោះ (។) ដូចខណ្ឌដកបានហើយ ក៏គង់តែហៅថាល្បះចប់ ឬ ខណ្ឌបរិយោសានបាន ។

គោមូត្រ "ទឹកនោមគោ" វណ្ណយុត្តិនេះ មានសណ្ឋានស្រដៀងនឹងកង្កាញទឹកនោមគោ (៚—) សម្រាប់ប្រើសរសេរដាក់ត្រង់កន្លែងបញ្ចប់សេចក្ដីដែលចប់អស់ហើយត្រឹមតែប៉ុណ្ណោះ ។ គ្រឿងវណ្ណយុត្តិនេះ អ្នកលង្កាទ្វីបប្រើដាក់ត្រង់ទីចប់នៃគាថាបាលីមួយៗ សំគាល់ជាខ្យល់សំឡេងរនន្ទាន ដូចកង្កាញរលកតាមទំនងបទសាគញ្ញាម្យ៉ាង ដែលហៅថា តរង្គ; ប្រហែលជាពួកបុព្វបុរសរបស់យើងពីដើម ប្រើបែបនេះ អ្នកឥណ្ឌា ឬ អ្នកលង្កាទ្វីប សម្រាប់ដាក់ចំពោះតែត្រង់កន្លែងបញ្ចប់

ពាក្យកាព្យឃ្លោងជាគ្រឿងសំគាល់ខ្យល់សំឡេងរនទេដឹង? លុះយូរៗតមកទោះបីពាក្យរាយក៏ប្រើវណ្ណយុត្តិនេះដែរ ។

ពីតបុគាប វណ្ណយុត្តិ (|) នេះ សម្រាប់សរសេរតាមពាក្យទន្ទឹមគ្នា

ដូចជា ថ្ងៃ ៨ កើត / រោច } នឹង ១៥ កើត / រោច } ឬ ១៤ រោច តែសម័យឥឡូវមិនសូវប្រើ ច្រើនសរសេររាយគ្នា ដោយប្រើវណ្ណយុត្តិរបស់អឺរ៉ុប (, ;) នេះ ជា: ថ្ងៃ ៨ កើត, ៨ រោច, នឹង ១៥ កើត, ១៥ រោច ឬ ១៤ រោច ដូច្នេះវិញ ។

វង្គុលេខា ឬ នយសញ្ញា សម្រាប់ប្រើគូសខាងចុង ពាក្យដែលមានសេចក្តីដូចគ្នាខាងដើម ឬ សម្រាប់គូសខាងក្រោមពាក្យដែលត្រូវទន្ទេញឲ្យចាំ ឬ ដែលជាសេចក្តីសំខាន់ គួរពិនិត្យឲ្យពិតប្រាកដ ។

មច្ឆណ្ឌសញ្ញា "ពង់ត្រី" សម្រាប់ប្រើចុចពីមុខពាក្យណាមួយឲ្យដឹងថានៅមានពាក្យតទៅទៀត ដូចជា: គោ, ក្របី, ដំរី, សេះ . . . ជាដើម ។

បេយ្យាល សម្រាប់ប្រើក្នុងសេចក្តីដែលនិយាយមិនទាន់ចប់ ហើយបញ្ឈប់សេចក្តីនោះទៅ ឬពាក្យដែលមានមកខាងដើមហើយ មិនបាច់ដាក់ពាក្យនោះមកទៀត គេត្រូវប្រើបេយ្យាលនេះ, តែវេលានឹងប្រើ

ត្រូវលុប យ្យាល ខាងចុងចេញទុកត្រឹមតែ បេ ។ បេ ។ ឬលុប បេយ្យា ខាងដើមចេញទុកត្រឹមតែ ល ។ ល ។ យ៉ាងនេះ ។

យុគលពិន្ទុ "ចំណុចមួយគូ" ឬ "ចំណុចពីរទន្ទឹមគ្នា" ពាក្យសន្មតឲ្យជាឈ្មោះវណ្ណយុត្តិមួយយ៉ាង (:) សម្រាប់ប្រើចុចពីខាងមុខអក្សរដែលមានសំឡេងជាៈ អៈ, អាៈ, អេះ, ... ជាដើម ដូចជាៈ ខេមរៈ ធុរៈ, ភារៈ, មរណៈ, លក្ខណៈ, សក្ការៈ, ស្រះ, អក្ខរៈ, ឬជាៈ អេះ អុ, រអេៈរអុ, យេ៉ៈយ៉ុៈ ជាដើម, ប៉ុន្តែពាក្យដែលសមាសនាម មានដើមជា កម្មជវដ្ឋ, ខេមរជាតិ, មគធភាសា, មរណភាព, រាជបុត្រ, សក្ការបូជា, អក្ខរវិធី ... នេះ កុំចុចអក្សរកណ្តាលជា កម្មជៈវដ្ឋ, ខេមរៈជាតិ, មគធៈភាសា, មរណៈភាព, រាជៈបុត្រ, សក្ការៈបូជា, អក្ខរៈវិធី ... ដូច្នេះឡើយ ។

មួយទៀតយុគលពិន្ទុនេះ មិនមានសំឡេងទេ សម្រាប់ប្រើជាគ្រឿងសំគាល់ការបង្អុលពាក្យ ឬ សេចក្តីខាងមុខ ដែលជាឧទាហរណ៍ ឬ ជាភ័ស្តុតាងជាដើម ដូចជាៈ ម្តាយ និយាយថាៈ កូន! ឯង! ខំរៀនទៅ ទាន់ខ្លួននៅក្មេង! ។

(,) នេះហៅថា "ចុល្លភាគ" សម្រាប់ដាក់ក្នុងសេចក្តីមួយៗ ដែលត្រូវដកឲ្យដាច់ពីគ្នា ដើម្បីអានទៅកុំឲ្យច្រឡំ ។

(;) នេះហៅថា "មហាភាគ" សម្រាប់ដាក់ក្នុងសេចក្តីដែល

និយាយ អស់មួយឃ្លាមួយល្បះហើយ ប៉ុន្តែខ័ណ្ឌ ព្រោះនៅមាន តទៅទៀត ។

(:) នេះហៅថា "ទ្វេភាគ" សម្រាប់ដាក់ក្នុងសេចក្ដីដែលត្រូវ ពប់ឬដាក់ក្នុងបទដែលវែង (មគធភាសា) ។

(?) នេះហៅថា "បុច្ឆនសញ្ញា" សម្រាប់ដាក់ខាងចុងនៃពាក្យសួរ, ដណ្ដឹង, ឆ្ងល់ ឬ សង្ស័យ អ្វីមួយៗ ។

(!) នេះហៅថា "អច្ឆរិយសញ្ញា" សម្រាប់ដាក់ក្នុងសេចក្ដីរបស់ អ្នកនិយាយ ដែលនិយាយកោតញញើតស្ញប់ស្ញែង ឬ អស្ចារ្យនឹងអ្វីមួយ ដូចពាក្យថា "យីអើ! ខ្ញុំមិនដែលឃើញសោះទេតើ!" ។

(!) នេះហៅថា "វិម្ហសញ្ញា" សម្រាប់ដាក់ខាងចុងពាក្យរបស់ អ្នកនិយាយ ដែលមានសេចក្ដីសរសើរ ឬ ស្រឡាញ់ចូលចិត្តនឹងរបស់ អ្វីមួយ ដូចជា: "យី! ល្អអីល្អម្ល៉េះទេ! ។

(!) នេះហៅថា "សំវេគសញ្ញា" សម្រាប់ដាក់ខាងចុងនៃសេចក្ដី ថ្ងូររៀបរាប់ ដែលនិយាយទៅហើយមានតំអែរតំអូញ ឬ ធុញទ្រាន់ ក្រៀមក្រំចិត្ត លំបាកចិត្តត្អូញត្អែរផ្ងើស ដូចជា: អកុសលខ្ញុំអើកក្រាស់ ម្ល៉េះទេ! តាំងពីកើតមកមិនដែលបានស្រាកស្រាន្តសោះ!" ។

(<) នេះហៅថា "អាគតសញ្ញា" សម្រាប់សំគាល់ឲ្យដឹងថា មកពី, ដូចជា: "ឧដ្ឋ<ឧស្ឋ, ជេដ្ឋ<ជេស្ឋ, បិដ្ឋ<ប្រឹស្ឋ". ជាដើម ។

(>) នេះហៅថា "គតសញ្ញា" សម្រាប់សំគាល់ឲ្យដឹងថាទៅជា, ដូចជា: ពស្ត្រ>វត្ថ. ស្ទាវ>ស្ទាត, ក្សណា>ខណា, ក្សយ>ខយ, ជាដើម ។

(") នេះហៅថា "វិឡាសសញ្ញាបើក" ឬ "ក្រចកឆ្មាបើកសម្រាប់បើក" ឬ ខណ្ឌពំងសេចក្ដីណាមួយ ដែលជាសេចក្ដីសំខាន់គួរឲ្យចេះចាំ ។

(") នេះហៅថា: "វិឡាសសញ្ញាបិទ" ឬ "ក្រចកឆ្មាបិទ" សម្រាប់បិទសេចក្ដីទាំងពាក្យ ទាំងឈ្មោះដែលសំខាន់នោះ កុំឲ្យច្រឡំ សេចក្ដីដទៃ ។

( ) នេះហៅថា "នខសញ្ញា" ឬ "វង់ក្រចក" សម្រាប់ដាក់ ពំងសេចក្ដីដែលត្រូវបញ្ចូល ឬពំងសេចក្ដីដែលនិយាយពន្យល់ឲ្យស្ដាប់ បាន ។

(–) នេះហៅថា "យតិភង្គ,, សង្កាត់ពាក្យមួយម៉ាត់ដែលផ្ដាច់ ចេញដោយខ្ទនពីគ្នា ត្រង់ចន្លោះឃ្លា គាថា, កាព្យ, ឃ្លោង គឺសង្កាត់ ឃ្លាមួយៗរបស់កាព្យឃ្លោង ដូចជា: ច្បាប់នេះថ្លៃថ្លា គួរឲ្យអស់មហា-ជន ផងត្រងត្រាប់. . ត្រូវភ្ជាប់មហាទាំងជន. បែរជាដកដាច់ពីគ្នាតាមឃ្លា របស់កាព្យ តែត្រូវប្រើគ្រឿងសញ្ញា (–) នេះ ជាសំគាល់ឲ្យដឹងថាជា កាព្យភ្ជាប់គ្នា ។

ភិក្ខុ មហា ពេជ្រ–ម៉ាន់

(មានត)

អក្សរអង្គុលីលេខ

( តពីសៀវភៅលេខ ១—២—៣ ឆ្នាំ១៩៥២ )

---

## ២—ស្រៈ

ស្រៈ ក៏មានសូរសម្ងន់វែងខ្លី មានការសរសេរវៀងតួ និងមានការអានជាលំដាប់លំដោយ ដូចស្រៈយើងមុនដែលកំពុងប្រើសព្វថ្ងៃដែរ ប្លែកតែរូប និងប្លែកតែចំនួនមានដល់ទៅ ២២ ព្រោះថែមតួ  ( ត្រូវអានថា អៈ) នៅខាងចុងបំផុតមួយទៀត ដូចបានកត់ខាងក្រោមនេះ ៖



រូបស្រៈទាំងអស់នេះ បានជាកែឲ្យមានសណ្ឋានយ៉ាងនេះ ព្រោះមានបំណងចង់ឲ្យបានល្អ និងចង់ឲ្យបានស្រួល ក្នុងការយកទៅប្រើតម្រូវអង្គុលីលេខ និងតម្រូវទៅតាមការសរសេរប្រើស្រៈដាក់ខាងមុខ ឬខាងស្ដាំព្យញ្ជនៈជាដើម ឃើញមានសេចក្ដីពិសេសតទៅទៀតតែតួ '  ដែលបង្កើតឡើង ដោយតម្រូវទៅតាមគោលការណ៍ខាងលើនេះផង ដោយតម្រូវប្រើជួសយុគលពិន្ទុ និងប្រើជួសសំយោគសញ្ញាផង ។

ការដែលយកស្រៈ  មកតម្រូវប្រើជួសយុគលពិន្ទុ និងប្រើជួស

សំយោគសញ្ញា នឹងមាននិយាយដោយច្បាស់លាស់នៅខាងមុខក្នុងពួក វណ្ណយុត្តិ ។

ចំណែកស្រៈ នមោ យើងពីដើម គឺ អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ មិនយកមកប្រើក្នុងរបៀបអក្សរនេះទេ ។

## ៣ — បំបែក

ការយកព្យញ្ជនៈមកផ្សំតាមលំដាប់ស្រៈ ក្នុងទីនេះ ហៅថា បំបែក មានដំណើរសព្វគ្រប់ដូចវិធីអក្សរយើងមុនដែរ ប៉ុន្តែការសរសេរត្រូវដាក់ស្រៈពីខាងមុខ ឬពីខាងស្តាំព្យញ្ជនៈជាដរាប នឹងមានលើសតួ ក៉ (ត្រូវអានថាកៈ) នៅខាងចុងបំផុតមួយទៀត ប៉ុណ្ណោះ ដូចជាតំរុកខាងក្រោមនេះ ៖



គ្រប់ព្យញ្ជនៈទាំងឡាយ ដែលមិនបានបំបែកក្នុងទីនេះ គប្បីដឹងថាមានដំណើរបំបែកដូចតួ ក ដែរ ។

## ៤ — សម្មាប់

ការកែសម្រួលព្យញ្ជនៈ ឲ្យប្លែកពីសម្រួលដើម ដោយយក វណ្ណយុត្តិ ២ យ៉ាង គឺមូសិកទន្ត ( ៉ )១ ត្រីសព្ទ ( ៊ )១ ទៅដាក់

ពីលើតួព្យញ្ជនៈ ហៅថា សម្លាប់ មានរបៀបដូចអក្សរយើងមុនដែរ មានប្រែប្រួលតែតួ ប៊ ដែលត្រូវសម្លាប់ជា ប៉ មិនត្រូវការយកមកប្រើទេ ដោយបានបង្កើតតួ ប៉ុ នេះ ជំនួសហើយ ។ បំណែកតួ ប៉- ដែលសម្លាប់ជា ប៊ នៅប្រើដដែល ។

ឯតួ ប៉ុ ដែលបង្កើតឡើងដើម្បីជំនួសតួ ប៉ នេះ ដោយមានប្រាថ្នានឹងបំពេញសេចក្តី ២ យ៉ាងដូចតទៅនេះ ៖

១ – តួ “ ប៉ ” គឺរបៀបអក្សរយើងមុន កាលបើយកជើងតួអក្សរណាមួយទៅផ្ញើ មិនបាច់យកមូសិកទន្ត ( ៉ ) ទៅដាក់សម្លាប់ពីលើទេ អាចក្លាយទៅជា “ ប៉ ” តែម្តង ។ ហេតុដូច្នេះ ឃើញថាខ្លះរបៀបប្រើចំពោះពាក្យកើតឡើងថ្មី ដែលយកជើងអ្វីមួយទៅផ្ញើ ហើយមិនប្រែសម្លេងក្លាយទៅជា ប៉ ដូចពាក្យអឺរ៉ុបខ្លះ ដែលនិយមប្រើមកជាខ្មែរ ឧទាហរណ៍ដូច Blockhaus បើតាមរបៀបអក្សរយើងមុននឹងសរសេរមិនបាន សរសេរបានតែ Plockhaus ។ ដើម្បីនឹងឲ្យសរសេរបានទាំង ២ យ៉ាងគឺ Plockhaus ក៏បាន Blohaus ក៏បាន បានជាលោកបង្កើតតួ ប៉ុ នេះឡើង ។

បើសរសេរតាមរបៀបអក្សរថ្មីដូច្នេះ ៖

Blockhaus = **បលៃកកបស**

Phockhaus = **ប៉ុលៃកកបស**

២ គូ "ប៉" ក្នុងរបៀបអក្សរយើងមុន កាលដែលសរសេរទៅជាពាក្យហើយ នៅមានអានប្រឡំជាច្រើន ដូចពាក្យ បណ្ណាល័យ, បរ ជាដើម គឺអាចអានថា ប៉ ក៏បាន ថា ប ក៏បាន ដោយគូ ប៉ មិនត្រូវដាក់មូសិកទន្តសម្រាប់ពីលើ ព្រោះថាពាក្យនេះមកពីបាលី ។ ចំណែកខាងរបៀបអក្សរនេះ ទើបអានជា ២ យ៉ាងដូច្នេះពុំបាន គឺថាបើត្រូវអានជា ប៉ ត្រូវដាក់គូ បុ បើត្រូវអានជា ប ត្រូវដាក់គូ ប ។

បើសរសេរតាមរបៀបអក្សរថ្មីដូច្នេះ ៖

## បណ្ណាល័យ, បរ

គូដែលត្រូវសម្រាប់ ក្នុងរបៀបអក្សរនេះក៏មានតែ ១២ ដូចរបៀបអក្សរយើងមុនដែរ គឺ

## ង៉ ញ៉ ន៉ ម៉ យ៉ រ៉ ល៉ វ៉ ប៊ ស៊ ហ៊ អ៊

អៀង - ប៊ាង

ជរលេខ អៀរគើស

(តពីសៀវភៅលេខ ១.២.៣ ឆ្នាំ ១៩៥២)

សញ្ញាជម្មូតា

# ព្យញ្ជនៈ

ខ្សែបន្ទាត់លាតត្រង់



ស-ស៊ី

ត

ជ

រ-រ៉

រ-រ៉-ហ្វ



ព្យញ្ជនៈណាប្រើជាខ្យល់ ព្យញ្ជនៈនោះត្រូវបន្ថយប្រវែងមក នៅត្រឹមពាក់កណ្ដាល ។

ក្នុងពាក្យមួយម៉ាត់ ត្រូវសរសេរសញ្ញាទាំងឡាយឲ្យជាប់គ្នា ។

ឧ. រត់ ត្រូវសរសេរ

មិនត្រូវសរសេរ



បើមានសញ្ញាពីរតួទិសជាមួយគ្នា ត្រូវសរសេរត្រង់បណ្ដោយគ្នា

ឧ. សោះ ត្រូវសរសេរ (សស់) —

មិនត្រូវសរសេរកាប់ឲ្យមានមុំទេ ︿

## សញ្ញាកាត់

ទឹង

ទាំងអស់

ទាំងឡាយ

ទាំងពួង

ទាំងមូល

ដែល

ដដែល

ដោយ

| | |
|---|---|
| / | រួច |
| ⌐ | សេចក្តី |
| — | សុំ - សូម |

## សញ្ញាបុងពាក្យ

### ស្រៈ

| | | | |
|---|---|---|---|
| ....ា... | អា | — | សា |
| ...ែ... | អែ | — | សែ |
| ...˙... | អេ | — | សេ |
| ...‧... | អ័,អី,អៀ | — | ស៊ុ |
| ..ើ... | អឹ,អឺ,អឺ,អឿ | — | សើ |
| ...ោ... | អុ,អូ,អោ | — | សោ |
| ...ល... | អួ | — | សួ |

ក្នុងវិធីផរលេខ តាមគោលការណ៍ត្រូវកត់តែសំឡេង ៗ អក្សរណាមិនបញ្ចេញសំឡេងមិនត្រូវកត់ឡើយ ។

ការកត់យកតែសំឡេងដូច្នេះ

១. ដោះ ត្រូវសរសេរ ∠ (ដស់)

ឲ្យអ្នករៀនហាត់សរសេរបំបែកដូចតទៅនេះ ៖



## សញ្ញាធម្មតា

### ព្យញ្ជនៈ

ខ្សែបន្ទាត់កួចត្រង់



១- មត់ 

បែ 

សល់ 

លេ 

ផល់ 

បើសញ្ញាពីរតួសរសេរជាប់គ្នា នាំឲ្យកើតជាមុំត្រូវគូបចេញក្រៅមុំជាដកប

១- តាបស ត្រូវសរសេរ 

មិនត្រូវសរសេរ  ទេ

សេចក្ដីសង្កេត.— កុងពាក្យពហុព្យាង្គ ស្រះដែលប្រាកដគួ មានតែក្នុងព្យាង្គខាងចុង ក្នុងព្យាង្គមុនៗ ត្រូវប្រើស្រះ អ ជួសជាដកប

១. តាបស សរ.សរ ជា ត - បស់ 

សិលា សរសេរ ជា ស លា 

# សញ្ញាកាត់

| | |
|---|---|
|  | មក |
|  | មកពី, មកអំពី |
|  | មកកាន់, មកដល់, មកឯ |
|  | មាន, |
|  | ដ៏មាន, ដែលមាន |
|  | បាន |
|  | បានពី, បានអំពី |
|  | បានដល់ |
|  | បានមក |
|  | បានមកពី, បានមកអំពី |
|  | បានមកដល់, បានមកកាន់ |

 ឲ្យ

 មិន

 មិនបាន

 ឡើង

 ឡើយ

(ដើម្បីឲ្យចាំងាយ)

 (ហូរ) មកពី (លើ)

 មកដល់ (ក្រោម)

## សញ្ញាធម្មតា

### ព្យញ្ជនៈ

ខ្សែបន្ទាត់ណាតគោង

 ប  បរលើ

 គ  គឺ

| | | | |
|---|---|---|---|
|  | ក |  | កន |
|  | ន |  | នក |
|  | ខ |  | ខក |
|  | ដ |  | ដក |
|  | ផ |  | ផល់ |
|  | ឈ |  | ឈប់ |

សញ្ញា កាលបើជាខ្យល់ប្រកបនឹងព្យញ្ជនៈ ដែលមានស្រៈ អ អា ស្រ័យ ដូចជា  ទៅជា  (ប) អាចនឹងប្រែចុះស្រៈ អូ ទៅជាកូ ប៉ុន្តែក្នុងភាសាយើង មានពាក្យទំនង កប គប ចំនួនតិចណាស់ ៗ បើមានខ្លះ ដូចជា (ប៉ើប) ប៉ប ក្នុងអសាធារណនាមខ្លះ ក៏សូមឲ្យធ្វើខ្យល់ ប ឲ្យធំជាងស្រៈ អូ បន្តិចទៅចុះ ៗ ។ ប៉ប  ៗ អសាធារណនាម ត្រូវសរសេរជាអក្សរធម្មតា តែបើត្រូវសរសេរអសា-ធារណនាមនោះ ច្រើនដងដដែល ៗ នោះ អាចសរសេរជាសញ្ញាជំនួសលេខបាន

# អក្សរកាត់



ខ្ញុំ



ខ្ញុំបាទ



ខ្ញុំប្របាទ



ខ្ញុំប្របាទម្ចាស់



កម្ម



កម្ម

ទៅ



នៃ



# សញ្ញាបុងពាក្យ

## ខ្យល់ក្នុងស្រៈ

ស្រៈដែលសំដែងមកហើយក្នុងទំព័រទី ២ អាចជាស្រៈទទេក៏បាន

អាចជាស្រៈមានខ្យល់ ស ឬវិសជ៌នីយក៏បាន ឬអាចមានខ្យល់ គ ក៏បាន ដោយមិនចាំបាច់សរសេរខ្យល់នោះផងទេ ។

ក.  សេះ

 សិស្ស

 បែ, បែត្រ, បែះ

 ដួ, ដួស, ដួត

 គិត

 បាទ

កាលបើស្រៈនៅជាប់ពីព្យញ្ជនៈ ត្រូវសន្មតថាមានខ្យល់ ល

ខ.  កាល

 បូល

 មួល

ត្រង់ស្រៈ អី នឹងស្រៈ អេ ដែលសរសេរភ្ជាប់ពីព្យញ្ជនៈស្រាប់ ហើយ ត្រូវប្រើគំនូសបញ្ឈរត្រង់

១. \ វិល

~ រនេល

---

## ហាត់អាន

តំព ? លោក ៸.२ γ ទីខុកញ៉ាសុគន្ធប្រើជាឥន្ទ អ្នកតែងឡើង ដើម្បី ? អ្នករៀន បុកណ ~ បែបយ៉ាង គ្រាន់អាន បៀបនាំ ? ប្រាវ្គ ? លោកថ្មី / កើត ? ឡើង ទើបតាំង ~ ពាក្យ ? ពាក្យ ? ក្នុងតំព ? ទីសណ្ដាប់ / ផាយ ៗ

ដើម្បី ? កូន ? គ្រូថា ? ប្រោស ពាក្យ ? ថា ? លោក ? ប្រែដូចម្ដេច ៗ

សេចក្ដីសង្កេត.— ខណ្ឌសញ្ញា លោកមិនប្រើ ក្នុងដវលេខទេ គ្រាន់តែដកឃ្លាជាការស្រេច ៗ

# សញ្ញាធម្មតា

## ព្យញ្ជនៈ

### ខ្សែបន្ទាត់កុកត្រង់

 ថ-  ថៃ

 ៖  ទូល

 ឆ  ធំ

 យ  យល់

 ក្ស, ខ្ស  ខ្សែ

---

# សញ្ញាចុងពាក្យ

## ស្រៈខ្យល់ ង

 អុង  សារុង

 ការុង

### សៀង - ឌិត

(មានត)

ឯកសារ ស្ដីពីប្រវត្តិសាស្ត្រ នៃកម្ពុជរដ្ឋ

លោក វ៉ាយ–ប៊ុកប្រែ លោក ហប–ពិន ពិនិត្យ

(ត ពីសៀវភៅលេខ ១ – ២ – ៣ ឆ្នាំ ១៩៥២)

---

## ៧– ទីរេស៊ីដង់កំពត

### ក) ខែត្រពាម

ព្រះគោហាហង្ស: *សិលាចារិក*

គោហាភ្នំទទឹង: *សិលាចារិក*

### ខ) ខែត្រទូកមាស

វត្តប្រាសាទ: *បូជនីយដ្ឋានធ្វើពីឥដ្ឋ*

ព្រះឱង្ការ: *សិលាចារិក*

## ៨– ទីរេស៊ីដង់កំពង់ស្ពឺ

### ក) ខែត្រកណ្ដាលស្ទឹង

ភ្នំហ្យព្នៀ: *បូជនីយដ្ឋានធ្វើពីឥដ្ឋ, សិលាចារិក*

### ខ) ខែត្រគងពិសី

វត្តព្រះនិព្វាន: *បូជនីយដ្ឋានពីរបាក់បែក, លិង្គមានសិលាចារិក*

### គ) ខែត្រសំរោងទង

ភ្នំសិត: ប៉ូជនីយដ្ឋានធ្វើពីឥដ្ឋ

ឧត្តុង្គ: ក្បាច់ចំឡាក់

## ៩ – ទីរេស៊ីដង់ក្រំពង់ធំ

### ក) ខែត្រជីក្រែង

ប្រាសាទស្លាប់ប្តី: ប៉ូជនីយដ្ឋានបីធ្វើពីឥដ្ឋ, ក្បាច់ចំឡាក់

ប្រាសាទតាមេង: ប៉ូជនីយដ្ឋានបីធ្វើពីឥដ្ឋ, ក្បាច់ចំឡាក់

ត្រាំខ្លា: ប្រាសាទធ្វើពីឥដ្ឋ, ក្បាច់ចំឡាក់

ស្ពានជុំងកែវ: ស្ពានធ្វើពីលោហធាតុដែក

ស្ពានបាប: ស្ពានធ្វើពីលោហធាតុដែក

ស្ពានត្បូ: ស្ពានលោហធាតុដែក

ប្រាសាទភឹងជង: ប៉ូជនីយដ្ឋានធ្វើពីឥដ្ឋ

ស្ពានព្រាបធ្លុស:(១) ប៉ូជនីយដ្ឋានធ្វើពីលោហធាតុដែក

ប្រាសាទព្រាបធ្លុស: ប៉ូជនីយដ្ឋានលោហធាតុដែក. មាន

កំពែងទីងប្រាសាទអាណាប, អក្សរចារិក

---

១ ព្រាបធ្លុស ប្រហែលជាបុព្វទិស ។

វត្តជីក្រែង: ក្បាច់ចំឡាក់អក្សរចារឹក

ដីណូ: ក្បាច់ចំឡាក់នឹងអក្សរចារិក

ស្ពានគ្រោគតាជើរ: ស្ពានតូចលោហធាតុដែក

បឹងមាលា: ប្រាសាទធំនឹងប្រាសាទអាណាបៈ

ប្រាសាទដូនចន្ទ, ប្រាសាទបឹងកែវ,

ប្រាសាទកុងភ្លុក, គោកតែធំ ៗ

ទំពជាយ: ប្រាសាទថ្មកក់

ស្ពានកេង: ស្ពានលោហធាតុដែក

ស្ពានតាឱង: ស្ពានលោហធាតុដែក

## ១) ខេត្តព្រះវិហារ

ស្ពានតូប: ស្ពានលោហធាតុដែក

ស្វាយក្បាលទឹក: បូជនីយដ្ឋានធ្វើពីឥដ្ឋ, កំពែងថ្មកក់

ភ្នំគូលេនព្រះព្យល: អក្សរចារិក

ភ្នំគូលេន: គោហាព្រះទ្វារ អក្សរចារិក

ស្ពានក្មេង: ស្ពានតូចលោហធាតុដែក

គោកឫស្សី: សិលាចារិក

ថ្ពុងកោង - គេង: អក្សរចារិក និងក្បាច់ចំឡាក់

តាជុង: បូជនីយដ្ឋានធ្វើពីឥដ្ឋ

ព្រះធាតុខ្វារ: បូជនីយដ្ឋានលោហធាតុដែក, អក្សរចារិក

ប្រាសាទតិត្ថ: ប្រាសាទថ្មភក់

ប្រាសាទប្រាំ: បូជនីយដ្ឋានថ្មភក់, កំពែង

ប្រាសាទស្ពានជ័យ: បូជនីយដ្ឋានបីធ្វើពីឥដ្ឋ

ប្រាសាទឈូក: បូជនីយដ្ឋានបីធ្វើពីលោហធាតុដែក

គោហាព្រះខ្វរ: ក្បាច់ចំឡាក់

ប្រាសាទព្រែប បូជនីយដ្ឋានពីរធ្វើពីឥដ្ឋ. អក្សរចារិក

បំផៀកបៅ: បូជនីយដ្ឋានបីធ្វើពីឥដ្ឋ, កំពែងធ្វើពីលោហធាតុដែក

ប្រាសាទព្រះត្រពាំងខាងជើង: បូជនីយដ្ឋានធ្វើពីលោហ-ធាតុដែក

ប្រាសាទព្រះត្រពាំងខាងត្បូង: បូជនីយដ្ឋានបីធ្វើពីលោហធាតុដែកនិងកំពែង

ឥង្គុ: បូជនីយដ្ឋានធ្វើពីឥដ្ឋនិងថ្មភក់ កំពែងលោហធាតុដែក, អក្សរចារិក

ប្រាសាទប្រាំ: បូជនីយដ្ឋានប្រាំមួយ. អក្សរបារាំក

ប្រាសាទភ្នំកុល: បូជនីយដ្ឋានធ្វើពីលោហធាតុដែក

ប្រាសាទប្រាំ (កោះកេរ): បូជនីយដ្ឋានបីធ្វើពីឥដ្ឋ កំពែង លោហធាតុដែក

ប្រាសាទនាងខ្មៅ: បូជនីយដ្ឋានទីងកំពែងលោហធាតុដែក (កោះកេរ)

ប្រាសាទរលួស: ព្រះវិហារថ្មកក់ (កោះកេរ)

ប្រាសាទជិរ (កោះកេរ): បូជនីយដ្ឋាន ទីងកំពែង លោហធាតុដែក, ក្បាច់ចំឡាក់

ប្រាសាទបិទ: ក្រុមប្រាសាទលោហធាតុដែក មានកំពែង, អក្សរបារាំក, ក្បាច់ចំឡាក់ (កោះកេរ)

អណ្តូងបេង[1] (កោះកេរ): អាងទឹកមានគែមធ្វើពីលោហធាតុដែក

ប្រាសាទដូងគុក (កោះកេរ): បូជនីយដ្ឋានប្រាំធ្វើពីឥដ្ឋ, កំពែង, យ៉, អក្សរបារាំក

---

១ ប្រហែលជាអណ្តូងប្រេង ។

ប្រាសាទប្រាំប្អូន: ខាងកើតនឹងខាងជើងប្រហាល់ (កោះកេរ)

ព្រះវិហារធំកោះកេរ: ប្រាសាទសិលាចារឹក, ក្បាច់ចម្លាក់

ស្ពានទ្រុង: ស្ពានតូចលោហធាតុដែក

ប្រាសាទជាមស្រម: បូជនីយដ្ឋានប្រាំធ្វើពីឥដ្ឋ, កំពែងធ្វើពីលោហធាតុដែកនឹងថ្មភក់

ភ្នំសណ្តុក: បូជនីយដ្ឋានធ្វើពីឥដ្ឋ, កំពែងនឹងសិលាគ្រឹះអាណាបធ្វើពីលោហហាតុដែក, ក្លោងទ្វារធំថ្មភក់, អក្សរចារឹក

ប្រាសាទជិប់: បូជនីយដ្ឋានធ្វើពីឥដ្ឋ, កំពែងធ្វើពីលោហធាតុដែក

ប្រាសាទបឹះ: បូជនីយដ្ឋាន បី ថ្មភក់

ប្រាសាទខ្នាសេនកែវ: បូជនីយដ្ឋាននឹងកំពែងថ្មភក់

ប្រាសាទសំឡាញ: បូជនីយដ្ឋានបីធ្វើអំពីលោហធាតុដែក

ប្រាសាទប៉ែនជុំ:(១) បូជនីយដ្ឋានបីធ្វើពីឥដ្ឋ

អ្នកតាបារិក: សិលាចារឹក

ប្រាសាទខ្នា: បូជនីយដ្ឋាន, កំពែង, សិលាគ្រឹះអាណាបលោហធាតុដែក, អក្សរចារឹក

---

១ ប្រហែលជាពែនជុំ?

ព្រះលានៈ បូជនីយដ្ឋាន, ធ្វើពីឥដ្ឋ, សិលាគ្រឹះត្រពាំងគុក, គុកថ្មកក់

## គ) ខេត្តកំពង់ស្វាយ

ព្រះខ័នៈ ប្រាសាទធំ ប្រាសាទតូចជាច្រើន, ព្រះថ្កល់, ព្រះដំរី

ស្ពានក្មេងៈ ស្ពានតូចធ្វើពីលោហធាតុដែក

ប្រាសាទធ្វើពីលោហធាតុដែកៈ ជិតស្ពានក្មេង

ប្រាសាទបេងៈ បូជនីយដ្ឋានទីងកំពែងលោហធាតុដែក, អក្សរចារិក

តួប្រាសាទៈ សិលាចារិក

ប្រាសាទវាលគុកខ្ញងៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ, បូជនីយដ្ឋានដប់ប្រាំជិតភូមិសំបូរ, អក្សរចារិក

វត្តមហាៈ អក្សរចារិក, ក្បាច់ចំឡាក់, កំពែងថ្មកក់

## ឃ) ខេត្តស្ទោង

ប្រាសាទអម្ពិលរលួសៈ បូជនីយដ្ឋានបីធ្វើពីឥដ្ឋ, អក្សរចារិក ក្បាច់ចំឡាក់

ប្រាសាទអណ្ដែតៈ បូជនីយដ្ឋានធ្វើពីឥដ្ឋ

ប្រាសាទស្វាយយោរៈ បូជនីយដ្ឋានបីធ្វើពីឥដ្ឋ, ក្បាច់ចំឡាក់

ប្រាសាទទ្វារក្ដី: ក្បាច់ចំឡាក់, អក្សរចារិក

ប្រាសាទសិរីសាប់: បូជនីយដ្ឋានធ្វើពីលោហធាតុដែកកំពែង ។
សិលាចារិកទួលប៉ុ (វត្ដកំពង់ចិន)

បន្ទាយស្ទោង: បូជនីយដ្ឋានធ្វើពីឥដ្ឋ

## ង) ខេត្តព្រៃក្ដី

ប្រាសាទអ្នកតាប៉ាលប់[១] បូជនីយដ្ឋានធ្វើពីឥដ្ឋ

ភ្នំបាឡៀង: បូជនីយដ្ឋានពីរធ្វើពីឥដ្ឋ, ក្បាច់ចំឡាក់

## ប) ខេត្តតាំងក្រសាំង

សិលាចារិកកោះកុត

ក្បាច់ចំឡាក់ភ្នំសន្ទុក

ភូមិប្រាសាទ: បូជនីយដ្ឋានធ្វើពីឥដ្ឋ, សិលាចារិក

## ធ) ខេត្តបារាយណ៍

ប្រាសាទកំបុត: បូជនីយដ្ឋានធ្វើពីឥដ្ឋ, សិលាចារិក

ប្រាសាទត្នោតជុំ: បូជនីយដ្ឋានធ្វើពីឥដ្ឋ, សិលាចារិកមួយ

បារាយណ៍: អក្សរចារិកបី

---

១ ប្រហែលជាប្រាសាទអ្នកតាព្រលប់ ។

ប្រាសាទគុកនគរៈ  បូជនីយដ្ឋានកំពែងនឹងសិលាគ្រឹះអាណាប ធ្វើពីលោហធាតុដែក

## ១០– ទីរ៉េស៊ីដង់ក្រកំពង់ឆ្នាំង

### ក) ខេត្តកំពង់លែង

ប្រាសាទព្រះស្រីៈ  បូជនីយដ្ឋានធ្វើពីឥដ្ឋ

ប្រាសាទតួបៈ  បូជនីយដ្ឋានធ្វើពីឥដ្ឋ  អក្សរចារិក

ប្រាសាទកទ្វារៈ  បូជនីយដ្ឋានធ្វើពីឥដ្ឋ

ភ្នំជីជុះៈ  សិលាគ្រឹះធ្វើពីឥដ្ឋ

ប្រាសាទភ្នំពណ្ណរាយៈ  បូជនីយដ្ឋានបីធ្វើពីឥដ្ឋ

## ១១– ទីរ៉េស៊ីដង់ក្រពោធិ៍សាត់

### ខេត្តពោធិ៍សាត់

ព្រះខ័នឬបាកានៈ  បូជនីយដ្ឋានធ្វើពីឥដ្ឋ  នឹងថ្មភក់

ចប់

បុរាណវត្ថុកម្ពុជរដ្ឋ  ជនខ្មែរគួរកត់គួរសំគាល់
ដើម្បីជាគោលជាបន្ទាល់  ឲ្យស្គាល់ភូមិសាស្ត្រប្រទេសខ្លួន
ប. ៣.

# បញ្ហា

## ប្រហែលជាលោកអ្នកភ្លេចហើយ?

( សូមមើលវិសជ្ជនា នៅទំព័រ ២០៧)

---

១ - តើគណៈធម្មយុត្តិ ចូលមកប្រតិស្ឋាននៅប្រទេសកម្ពុជា ពីឆ្នាំណា? ព្រះសង្ឃណា ជាអ្នកនាំមក?

២- ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ - វរ្ម័ន ទ្រង់សាងព្រះផ្នួសពីថ្ងៃ ខែ ឆ្នាំណា?

៣ - សមាគមមិត្តសាលាបាលី បដិសន្ធិពីថ្ងៃ ខែ ឆ្នាំណា? លោកណា ជាមេផ្តើមបង្កើតជាបឋម?

៤ - សមាគមខេមរសហជីវិន កើតពីថ្ងៃ ខែឆ្នាំណា? លោកណា ជាអ្នកបង្កើតជាដំបូង?

៥ - អាសយដ្ឋានខេត្តខែរកើតពីឆ្នាំណា?

៦ - មហាសន្និបាតលើកទីមួយនៃសមាគមមិត្តសាលាបាលី ធ្វើនៅថ្ងៃខែឆ្នាំណា?

៧ - សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក "ជួន - ណាត" បដិសន្ធិនៅទីណា ឆ្នាំណា? ថ្ងៃខែឆ្នាំណាដែលព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានទ្រង់ព្រះរាជទានឋានន្តរស័ក្តិនេះចំពោះសម្តេច?

៨-មហាវិទ្យាល័យស៊ីសុវត្ថិ៍ស្ថាបនាពីថ្ងៃខែឆ្នាំណា?

៩. ច្បាប់ដែលអនុញ្ញាតឲ្យជនជាតិខ្មែរធ្វើសមាគម តើប្រកាសឲ្យប្រើពីថ្ងៃខែឆ្នាំណា?

១០- សមាគមនៃមិត្តនិងសិស្សចាស់វិទ្យាល័យស៊ីសុវត្ថិ៍ កើតពីឆ្នាំណា?

១១- លោកអ្នកឧកញ៉ាសិរីសម្បត្តិ អ៊ឹង-ទឹង-អ៊ួន បានបូជាគេហដ្ឋានមួយល្វែង លេខ ៣៥-a វិថីឧកញ៉ាពេជ្រក្រុំពេញ ជាទីសំណាក់ការសមាគមមិត្តសាលាបាលីពីថ្ងៃខែឆ្នាំណា? សំណាក់ប៉ុន្មានខែឆ្នាំបានយកវិញ?

១២- ថ្ងៃខែឆ្នាំណាដែលស្ថាបនានូវសាលាបាលីជាន់ខ្ពស់ នៅព្រះរាជធានីភ្នំពេញ?

១៣- ព្រះរាជបណ្ណាល័យកម្ពុជា ស្ថាបនានៅទីណា ពីថ្ងៃខែឆ្នាំណា?

១៤- មាត្រាណានៃក្រមព្រហ្មទណ្ឌ ដែលបញ្ញត្តអំពីសមាគមខុសច្បាប់ និងសមាគមសម្ងាត់?

១៥- ថ្ងៃខែឆ្នាំណា ដែលព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ប្រកាសឲ្យប្រើអក្ខរាវិរុទ្ធតាមពាក្យដែលមានក្នុងវចនានុក្រមខ្មែរ ភាគ-១-២?

១៦- ថ្ងៃខែឆ្នាំណាដែលសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត និមន្តទៅប្រជុំពុទ្ធិកសមាគមពិភពលោកឯលង្កាទ្វីប?

១៧- ថ្ងៃខែឆ្នាំណាដែលលោក អ៊ូ-គង់ ទីប្រឹក្សាព្រះរាជអាណាចក្របានប្រគល់គេហដ្ឋានផ្ទះព្រៃនគរមួយល្វែង មកឱ្យសមាគមមិត្តសាលាបាលីតាំងមន្ទីរសំណាក់ការបណ្ដោះអាសន្ន?

១៨- ថ្ងៃខែឆ្នាំណាដែលស្ថាបនានូវសាខាសមាគមមិត្តសាលាបាលីខេត្តកំពត? លោកណាជាលេខាធិការ?

១៩- ព្រែកចិនដំដែក ដែលឱ្យនាមទៅជាវត្តចិនដំដែកពីដើមហៅជាព្រែកអ្វី?

២០- ទន្លេចតុមុខពីដើមហៅថាអ្វី?

២១- ថ្ងៃខែឆ្នាំណាដែលសមាគមមិត្តសាលាបាលីស្ថាបនានូវគណៈកម្មការ អក្សរសាស្ត្រខ្មែរ?

## វិសជ្ជនា

### ប្រហែលជាលោកអ្នកភ្លេចហើយ?

(សូមមើលបុច្ឆា នៅទំព័រ ២០៥)

---

១- គណៈធម្មយុត្តិចូលមកប្រតិស្ឋាននៅកម្ពុជរដ្ឋពី ព.ស. ២៤០៧ គ.ស. ១៨៦៤ ដោយសម្ដេចព្រះសុគន្ធជាអ្នកស្ថាបនាដំបូង ។

២- ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តមសីហនុ វរ្ម័ន ទ្រង់សាងព្រះផ្នួសពីថ្ងៃ ៣១ កក្កដា ១៩៤៧ ។

៣- សមាគមមិត្តសាលាបាលីបដិសន្ធិពីថ្ងៃ ២៤ សីហា ១៩៤៩ ដោយលោកម៉ៅ-មុី យោក្ស័ត្រក្រសួងមហាផ្ទៃ ជាអ្នកផ្តើមធ្វើជាដំបូង ។

៤- សមាគមខេមរៈសហជីវិនីកើតពីថ្ងៃ ១០ តុលា ១៩៤៨ ដោយសម្តេចព្រះវរជននីនាថ នឹងសម្តេចព្រះបិតុច្ឆាស៊ីសោភ័ណ ។

៥- អាស្រយដ្ឋានខេត្តខ្មែរពីដើមហៅថា អាស្រយដ្ឋានខេត្តបាត់ដំបង ពី គ.ស. ១៩៤១ ។

៦- មហាសន្និបាតលើកទីមួយនៃសមាគមមិត្តសាលាបាលី បានធ្វើនៅថ្ងៃទី ៥ សីហា ១៩៤៩ ។

៧- សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ជួន - ណាត បដិសន្ធិក្នុង ព.ស. ២៤២៦ គ.ស. ១៨៨៣ នៅភូមិកំរៀង ឃុំរកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់បានព្រះរាជទានឋានន្តរៈជាសម្តេច ពីថ្ងៃ ១១ ឧសភា ១៩៥០ ។

៨- មហាវិទ្យាល័យស៊ីសុវត្ថិបានស្ថាបនានៅកម្ពុជរដ្ឋ ពីថ្ងៃ ១៤ កញ្ញា ១៩៣៥ ។

៩- ច្បាប់ដែលអនុញ្ញាតឲ្យជនជាតិខ្មែរធ្វើសមាគមបាន គឺព្រះរាជប្រកាសលេខ ១១ ចុះថ្ងៃ ៣១ ធ្នូ ១៩២៦ ។

១០- សមាគមមិត្តនឹងសិស្សចាស់វិទ្យាល័យស៊ីសុវត្ថិ បានស្ថាបនាក្នុងកម្ពុជរដ្ឋពីឆ្នាំ ១៩៣៥ ។

១១- លោកអ្នកឧកញ៉ាសិរីសម្បត្តិ អ៊ឹង-ទឹង-អួន បានបូជាគេហដ្ឋានមួយល្វែង លេខ ៣៥-a វិថីឧកញ៉ាពេជ្រ ភ្នំពេញ ជាទីសំណាក់ការសមាគមមិត្តសាលាបាលី ពីថ្ងៃទី ៦ តុលា ១៩៤៩, កំណត់ ៣៦ ខែ (៣ ឆ្នាំ) យកវិញ ។

១២- សាលាបាលីជាន់ខ្ពស់ បានស្ថាបនានៅព្រះរាជធានី ភ្នំពេញ ពីថ្ងៃទី ២៤ វិច្ឆិកា ១៩១៤ ។

១៣ - ព្រះរាជបណ្ណាល័យកម្ពុជាបានស្ថាបនានៅទីក្រុងភ្នំពេញ តាមព្រះរាជប្រកាសលេខ ២ ចុះថ្ងៃទី ១៥ មករា ១៩២៥ ។

១៤- មាត្រា ២៨៧-២៨៨-២៨៩ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តអំពីសមាគមធ្វើដោយខុសច្បាប់ និងសមាគមសម្ងាត់ ។

១៥- ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់បានប្រកាស ឲ្យសរសេរពាក្យខ្មែរឲ្យត្រឹមតាមអក្ខរាវិរុទ្ធ ដែលបានចារិកទុកនៅវចនានុក្រមខ្មែរ ភាគ ១-២ ពីថ្ងៃ ២៩ វិច្ឆិកា ១៩២៧ ។

១៦- ថ្ងៃទី ២០ ឧសភា ១៩៥០, សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក "ជួន ណាត" បាននិមន្តចាកចេញពីក្រុងភ្នំពេញតាមអាកាសយាន "អែរហ្វ្រង្ស" ដើម្បីធ្វើដំណើរទៅកាន់លង្កាចូលប្រជុំពុទ្ធិកៈសមាគមពិភពលោក ។

១៧- លោក អ៊ូ-គង់ ទីប្រឹក្សាព្រះរាជអាណាចក្រ បានប្រគល់គេហដ្ឋានមួយស្ទើរបិតនៅតាមផ្លូវព្រៃនគរ មកសមាគមមិត្តសាលាបាលី តាំងមន្ទីរសំណាក់ការបណ្ដោះអាសន្ន ពីថ្ងៃទី ២៨ សីហា ១៩៤៩ ។

១៨- សាខាសមាគមមិត្តសាលាបាលីខេត្តកំពតបានស្ថាបនាពីថ្ងៃទី ២០ មីនា ១៩៥០ ។ លោក ចាប-ស៊ុំ ចាងហ្វាងសាលាដំបូងកំពត ជាលេខាធិការ ។

១៩- ព្រែកចិនដំដែកដែលឲ្យនាមទៅជាវត្តចិនដំដែក ពីដើមហៅជាព្រែកពំពាយ ។

២០· ទន្លេបតុម្ពខ ពីដើមហៅជាត្រាបតាម ។

២១- សមាគមមិត្តសាលាបាលីបានស្ថាបនានូវគណៈកម្មការអក្សរសាស្ត្រខ្មែរនៅថ្ងៃ ទី ៨ វិច្ឆិកា ១៩៤៩ ។

ក៉យ-ប៊ុក

ថ្ងៃខែឆ្នាំកើតកិច្ចគ្រប់យ៉ាង ទាំងខាងពុទ្ធចក្រអាណាចក្រ
នៅក្នុងប្រទេសខ្មែរគួរស្មូត្រ បំណាំឲ្យជាក់សម្រាប់ដឹង
ប. ព.

# ម្ដាយនិងកូន

ម្ដាយ គឺស្រីអ្នកមានគុណជាអនេកលើកូន ៗ ក្នុង ១ ជាតិរបស់លោក ដែលលោកខំប្រកបការងារផ្សេងៗនោះ ក៏ដើម្បីតែជាប្រយោជន៍ដល់កូនប៉ុណ្ណោះ ៗ បើកូនបានខ្ពស់មុខប្រកបតាមដំបូន្មាន លោករមែងរីករាយចិត្ត ត្រជាក់ចិត្តយ៉ាងក្រៃលែង ៗ បើកូនអាប់មុខ បានទទួលសេចក្ដីទុក្ខ លោករមែងទទួលទុក្ខជាមួយ ៗ បើកូនខិលខូច ដើរប្រឡៃប្រកោប្រព្រឹត្តអាក្រក់ផ្សេងៗ មិនស្ដាប់បង្គាប់ លោកតែងមានសេចក្ដីទុក្ខយ៉ាងធ្ងន់បំផុត ៗ សេចក្ដីស្រឡាញ់របស់លោកចំពោះកូន ជាសេចក្ដីស្រឡាញ់យ៉ាងពិតប្រាកដ ៗ លោកតែងសន្ដោសដល់កូនជានិច្ច ទុកជាកូនខុសយ៉ាងណា ក៏មិនហ៊ានសម្លាប់កូនដែរ ៗ សូរសំឡេងដែលកូនហៅថា "ម៉ែៗ ម៉ាក់ៗ...." រមែងធ្វើឲ្យចិត្តរបស់លោកទន់ភ្លន់ ៗ សេចក្ដីសុខរបស់លោក តែងនៅត្រង់សេចក្ដីសុខរបស់កូន ទុកជានឿយហត់យ៉ាងណា ក៏ចេះតែទ្រាំទ្របានតាំងអស់ឲ្យតែកូនបានសេចក្ដីសុខ ៗ ពាក្យកាព្យខាងមុខនេះ ជាពាក្យជូររបស់មាតាដែលទុក្ខយ៉ាងធ្ងន់ចូលមកគ្របសង្កត់សន្ដានចិត្តរបស់លោក ក្នុងកាលដែលលោកឃើញកូនប្រព្រឹត្តអាក្រក់ពេក :—

## ពាក្យកាព្យបទពាក្យ ៩

ក្ដិអើយកូន! នាងបង្ក តែត្រៀងក្ដៅ
ម៉ែប្រដៅ ទូន្មាននាង យ៉ាងនេះឬ?

ម្ដេចវង្វេង ស្រវឹងយស គោះលែងពុំ
ភយបុកហឹ ឌឹខាងចាយ គ្មានសំចៃ ៗ
មានប៉ុន្មាន ចាយទាល់អស់ លក់ខោអាវ
យកលុយប៉ាវ ភឿនមិត្តភក្តិ គ្រប់យប់-ថ្ងៃ
លុះអស់ទៀត ចេញស្ទៀតបោក អ្នកដទៃ
ម៉ែនឹងឪ ក៏លែងកើត អស់ផ្លូវកែ ៗ

កាលនៅតូច ម៉ែបីបម ថ្នមល្ងាចព្រឹក
គីផ្តតទឹក បំបៅដោះ កល់ថ្ងៃ-ខែ
លុះល្មមរៀន ក៏ឲ្យរៀន តាមហូវៃ
ដកបតៃ បានសម្រេច សមបំណង ៗ

តែស្រេចហើយ នាងគ្មានគិត អាណិតម្ដាយ
ត្រឡប់ក្លាយ ជាវិលខូច ខុសអ្នកផង
គ្មានគិតទឹក នឹងតាំងខ្លួន ពេលណាម្ដង
ចិត្តប៉ុនប៉ង តែសប្បាយ ចាយហ៊ឺហា ៗ

បានបុណ្យច្រើន រឹតតែឡើង ខាងរឹងត្អឹង
ម៉ែមិនដឹង ជានឹងគិត កែបែបណា
ប៉ុណ្ណឹងហើយ ល្មមឈប់ទៅ! ស្ដាប់មាតា
នាងមេត្តា ដល់ទូនម៉ែ ដែលទុក្ខក្រំ ៗ

គ្រឿងមាសប្រាក់ ម៉ែក៏លក់ ស្ទើរគ្មានសល់
យកលុយផ្តល់ ឲ្យកូនរៀន លុះដល់ធំ
ឯលុយថ្មី ដែលម៉ែរក ដោយខំខិតខំ
ទុកសន្សំ ត្រៀមការពារ នាគ្រាក្រ ៗ

ទាំងប្អូននាង ក៏នៅតូច ត្រូវពឹងម៉ែ
ម៉ែត្រូវតែ ថែទាំផង ជាបន្ត
បែងប្រាក់កាស ដែលម៉ែបាន ដោយកម្រ
ខំបង្ក តទៅទៀត ទំរាំស្លាប់ ៗ

ម៉ែប្រាថ្នា សរសើរគុណ បុណ្យកូនឯង
ដោយទឹកក្រែង ថាកូនម៉ែ មិនទុនអាប់
គង់ចម្រើនយស ខ្ពស់ឋានៈ យ៉ាងចំណាប់
ប្រព្រឹត្តច្បាប់ ត្រូវបំណង នៃមាតា ៗ

បើនាងល្អ ទើបម៉ែបាន ក្តីសប្បាយ
ការនឿយណាយ ដែលម៉ែទ្រាំ ចិញ្ចឹមបា
គឺផ្ប័តទឹក បំបៅដោះ ទោះយ៉ាងណា
គង់តែវា រសាយបាត់ ពីសន្តាន ៗ

កាងនឹងបាន ជាសិរី នៃក្ខុកម៉ែ
មិនចាំតែ ថែចិញ្ចឹម ម៉ែប៉ុន្មាន

គ្រាន់តែលះ ក្ដីអាក្រក់ ពីក្នុងប្រាណ
គង់រាប់បាន ជាចិញ្ចឹម ចិត្តម៉ែហើយ ។
ពុទ្ធោអើយ! ម៉ែធ្លាប់តែ សរសើរថា
តាំងចិត្តថា នឹងនាំកូនឲ្យ ដល់ត្រើយ
តែកូនគ្មាន បំណងល្អ ដល់ម៉ែឡើយ
កូនម៉ែអើយ! នាងកម្ម ខ្លួនឯងទេ ។
កូឱអើយកូន! ម៉ែបានគិត មកខុសសោះ
ពីដើមនោះ ម៉ែសរសើរ បុណ្យបុព្វេ
ថាបាននាង ជាកូនប្រុស រៀនដូចគេ
ឥឡូវ...ទេ! នាងប្រាណម៉ែ ចោលចេញឆ្ងាយ ។
ម៉ែឆ្ងល់ណាស់! នាងសិក្សា បានច្រើនដែរ
ម្ដេចក៏បែរ ជាអាក្រក់ ឱ! គួរស្ដាយ!
ចេះច្រើនណាស់ តែខូចណាស់ គ្មានរសាយ
ហាក់ដូចម្ដាយ ឲ្យកូនរៀន រងទុក្ខភ័យ ។
ម៉ែធ្វើបុណ្យ ទំព្រួចទឹក ផ្សាយកុសល
ឧទ្ទិសផល សុំឲ្យកូន បានប្រពៃ
លះអាក្រក់ ប្រព្រឹត្តល្អ តាមវិន័យ
ម៉ែរំពៃ ត្រៀមខ្លួនចាំ ទទួលបា ។
បើកម្មធ្ងន់ មិនបាត់ខូច ក្នុងជាតិនេះ

ជាតិមុខនេះ   ប្តូរកូនល្អ   ណាកូនណា !
កើតជាកូន   ម៉ែទៀតចុះ   ម៉ែមិនថា
ម៉ែស្នេហា   ស្មើដួងចិត្ត   នៃម៉ែអើយ !!!

ចំណែកសេចក្តីស្រឡាញ់របស់កូនចំពោះមាតាវិញ ច្រើនតែជាសេចក្តីស្រឡាញ់ក្លែងក្លាយមិនសូវពិតប្រាកដ ផ្ទុយអំពីសេចក្តីស្រឡាញ់របស់មាតា ។ បើកូនមានទុក្ខ ម្តាយរមែងបញ្ចូនដៃជើងចូលទៅជួយភ្លាមដោយឥតទាមទារសោគុណអ្វីឡើយ ឬពោលម្យ៉ាងទៀតថា មាតាតែងមានគំនិតគិតដល់កូនជានិច្ច ។ ឯកូនវិញ មិនសូវមានចិត្តដូច្នោះទេ ច្រើននឹកឃើញដល់មាតា ចំពោះតែពេលខ្វះ សម័យខ្វះប៉ុណ្ណោះ ត្រូវនឹងសុភាសិតខ្មែរថា "ម្តាយនឹកកូនដូចច្រកប្រដេញ, កូននឹកម្តាយវិញដូចព្រះប្រក្រោយ" ។ កាលកូននៅតូច ពេលដែលមាតាទំនុកបំរុងគ្រប់ប្រការនោះ គ្មានព្យាក្យរបស់មាតាថា "កូនអញជំពាក់អញប៉ុណ្ណេះ-ប៉ុណ្ណោះ" ឡើយ ។ តែកាលកូនធំពេញរូបពេញពង់ឡើងហើយ ត្រឡប់ជាច្រើនតែព្យាក្យរបស់កូនថា "ម៉ែអញជំពាក់អញប៉ុណ្ណេះ-ប៉ុណ្ណោះ" ដូច្នេះវិញ ។ ទាំងការប្រព្រឹត្តិរបស់កូនចំពោះមាតាទៀតសោតក៏មិនទៀងទាត់ ព្រោះគំនិតរបស់កូន មិនមែនពឹងផ្អែក-ជឿ-ទុកចិត្ត-ស្មោះត្រង់ចំពោះមាតាដោយស្មោះអស់ពីចិត្ត គ្រប់តែពេលទេ ជួនកាលមានពេលខ្វះ ដាក់ម្តាយថាអន់ជាងខ្លួនទៀតផង ។ សេចក្តីខាងមុខនេះ ជាគំនិតរបស់កូនដែលកើតឡើងតាមខណៈៗ...

កូន(១)វ័យអាយុ ១១ ឆ្នាំ: "ម៉ែអញនេះវិសេសណាស់ ការអ្វីក៏គាត់ចេះគាត់ដឹងទាំងអស់" ។

កូនវ័យអាយុ ១៦ ឆ្នាំ: "បើតាមពិត ម៉ែអញមិនមែនជាវិសេសគ្រប់យ៉ាងដូចអញនឹកស្មាននោះទេ, មែនហើយ ! នឹងថាដឹងគ្រប់យ៉ាងទៅក៏មិនត្រូវ" ។

កូនវ័យអាយុ ១៩ ឆ្នាំ: "ម៉ែអញតែងនឹកសំគាល់ថាខ្លួនគាត់ត្រូវជានិច្ច តែបើតាមពិត គ្មានចេះដឹងអ្វីច្រើនប៉ុន្មានទេ អញចេះដឹងវែងឆ្ងាយទូលាយជាងគាត់ជាច្រើន" ។

កូនវ័យអាយុ ២២ ឆ្នាំ: "ម៉ែអញដូចជាប៉ុនតែខាងមិនចូលចិត្តនឹងមនុស្សកំលោះក្រមុំប៉ុណ្ណោះ ដូចជាគ្រាំគ្រែងនៅក្នុងសម័យចាស់ហួស-ពេក រឿងអ្វីក៏មិនដឹងដែរ" ។

កូនវ័យអាយុ ៣០ ឆ្នាំ: "បើពោលតាមពិតទៅម៉ែអញបញ្ចេញមតិអ្វីៗ បានល្អជាច្រើនប្រហែលនឹងអញដែរ" ។

កូនវ័យអាយុ ៤០ ឆ្នាំ: "ម៉ែអញវិសេសមែនៗ ការអ្វីៗ ក៏ពូកែទាំងអស់ មើលហេតុការណ៍ខាងមុខក៏ឃើញបានយ៉ាងច្បាស់លាស់, នឹងធ្វើ - និយាយ - គិតអ្វីក៏ត្រូវនឹងពេលវេលា ; ឱ ! ម៉ែអើយម៉ែ !

ព្រះមហា ឧត្តមវិជ្ជា ប៊ុន - ប៉ម

---

១ គំនិតកូនទាំងអស់នេះ, ស្រង់ចេញពីកាសែតថៃ ឈ្មោះ ប្រជា.ករ, ថ្ងៃចន្ទ ២ មករា ព.ស. ២៤៩៣, ទំព័រ ៩ ។

# សក្តុណា

(តមកពីលេខ ១ — ២ — ៣ — ឆ្នាំ ១៩៥២)

## យល់ព្រះទិវង្គទ្រង់និកឃើញ

ព្រេងនិទានមានបុរសម្នាក់កំព្រា សែនវេទនាក្រលំបាកតោកយ៉ាកក្រ
ខំប្រឹងប្រែងស្វែងស្វះរកតែរាល់ថ្ងៃ រិះសំចៃអាស្រ័យបាយស្មើរពុំគ្រាន់ ៗ
ថ្ងៃមួយនោះគាត់ខិតខំដុលសំណាញ់ ប្រឹងត្បាញវេញខ្សែផ្ចិតលៃឲ្យទាន់
គេឯទៀតឈ្លៀតចុះស្ទឹងប្រឹងគ្នេគ្នាន់ ចាប់ត្រីឈាន់ព័ទ្ធព័ទ្ធគ្នាជាអនេក ៗ
ត្រីសម្បូណ៌ហូរចូលពេញសំណាញ់គេ ច្រើនម៉្លេះទេរេគព្រួលដោល
ពេលរែក
ខំបំរះប្រះប្រឹងប្រែរកខែញែក ត្រសុលដែកហែកសំណាញ់
មុជចេញក្រៅ ៗ
មានត្រប់ពណ៌ល្អគួរគន់ច្រើនអនគ្ឃ គេលើកដាក់ចាក់លើគោកដេរ
ដាសស្មៅ
គរគ្រៀបត្រាស្រកាផ្លេកចាំងថ្ងៃក្ដៅ មានសម្ផិនផ្កាខ្មៅដូចនិលស
ដូចប្រាក់ ៗ
អ្នកនេសាទទុហាតខំមិនឲ្យស្អក ខ្លះធ្វើផ្អកប្រកការុងប្រុងប្រឡាក់
ទុកធ្វើងៀតគណ្ដៀតយកទៅទុកដាក់ ខ្លះស្ងោះស្ង័ត្រែកសែងលីទៅ
ទីផ្សារ ៗ

ខំរើកឡើងរវល់ទល់ព្រលប់ គ្មានឈរឈប់ដល់ហើយស្រេចសំរេចការ
ទើបវិលថ្កានបានលំនៅរកអាហារ ដោយអាការរីកស្រស់ស្រាយ
សប្បាយចិត្ត ។

ទៅកំសត់ហត់ផ្សែផ្សំខំតែកាញ់ ជួសសំណាញ់ត្រាតែបានបិទជុំជិត
ទើបទៅពើសំដៅស្ទឹងទឹងរិះគិត ទាំងផង់ផឹតលែបង់ត្រីក្នុងទីស្ងាត់ ។
ដល់ស្ទឹងស្មោះបោះសំណាញ់ប្រឹងក្នុងទឹក អគ្គិយទឹកដល់ដោតខ្លួនប្អូនវិបត្តិ
មៀងមើលផ្កាយឆ្ងាយលន្ទឹមលន្ទោចក្តាត់ ពពកសាត់កាត់ទៅឆ្ងាយ
ដាច់សង្វែង ។

លោសំណាញ់កាញ់ឆ្ងាយធ្លាក់កាត់ខ្សែទឹក ញ័រសន្ធឹកគគឹកហូរសូរ
ស្ងប់ស្ងែង

ទាញបុរសអស់ទំហឹងកឹងក្រវែង គាត់ខះខែងជ្រែងទល់ទប់ផ្ទប់គល់ឈើ ។
បង្រោក់ខ្លាប់ញាប់ញ័រញាក់ក្ងាក់អាត្មា ខំស្រេកស្រាវសំណាញ់ពុំរង្គើ
ទើបតែរកគេមកជួយទាញឡើងលើ មកជួយរើសំណាញ់ធ្ងន់ពន់ឡើងដី ។
គេផងធ្ងល់ខ្វល់ខ្វាយរកអុជចន្លុះ ក្តីព្រោងប្រុះធ្លុះទាំងផ្សែងខ្ញែងខ្ញាត់ខ្ចី
ជ្រុះកំទេចរាយបាយព្រាយរស្មី ទាំងប្រុសស្រីរញីទៅកាន់មាត់ស្ទឹង ។
ទាំងក្មេងចាស់រហ័សខំទាញសំណាញ់ អួសខ្វិលខ្វាញ់ឥតរេរង់ទង់
ទាញតឹង

ហាក់អូសទូកគ្រុកៗ គ្រឹបរឹបប្រាណព្រឹង អស់ទំហឹងរឹងសរសៃ-
គ្រប់ៗប្រាណ ៗ

លើកឡើងគោកឈោកមើលជាក់យល់មច្ឆា បែកក្រឡាស្រកាទៅធំ
ចំណាន

ក្បាលដុះស្នែកបំរះរមួលប្រាណ ផ្អើលសត្វហ៊ានមករជយគយគន់អាប់ ៗ

លាន់មាត់ថា "ដើសជាក់ជាស្តេចត្រីពិត ធ្លាយគំនិតថ្ងោះខ្លួនស៊យ
ឲ្យមនុស្សចាប់

ធ្លាប់ក្អេងក្អាងខាងគេចវេះប៉ុនចំណាប់ បានគេកាប់សាប់ស្លាបអសារបង់"ៗ

ឯស្តេចត្រីឃ្នាតខ្វីខំបំរះរើ ខ្ទូចក្បូនឈើលើខ្ទេរស្អឹងប្រឹងអស់អង្គ

មនុស្សក៏ប្រុតពួតដៃគ្នាចោមជំកង់ កាប់ដម្រង់ត្រង់កន្ទែងដែលសំខាន់ ៗ

ទុអនិច្ចាមច្ឆាធំរើត្រុប កាំបិតស្រួចក្បួចកាប់កាច់ផ្តាច់ជីវិន

ផ្តាច់ជីវិតងងឹតឈឹងប្រឹងមិនទាន់ គេស្រពន់ជាន់គ្នាន់ខ្ទាប់កាប់ញាប់ដៃ ៗ

វះពោះត្រីស្ទើដេញព្រាតដូចផ្កាយ គួរធ្លល់ធ្លាយកាយចេញមកអស់
សង្ស័យ

ឃើញចិញ្ចៀនមាសមួយវង់ទ្រង់ថ្លាថ្លៃ ពេជ្រវិស័យប្លែសំអាងយ៉ាង
វិចិត្រៗ

បុរសអរចរចោលត្រីខ្វីឃ្នាតទៅ កាន់លំនៅនៃជាងទងបំព្រងចិត្ត

ទិញលក់ដូរយកថ្វរទុកលៀងជីវិត សោះនឹងគិតព្រួយបារម្ភខំសព្វថ្ងៃ ៗ

ជាន់មាសយល់ព្រះសង្ហាត្រាលើវង់ ព្រះទំរង់ចិញ្ចៀនផើតកើតសង្ស័យ
ទើបគេចរិនប្ដឹងតំរួតប្រួតកែខ ចាប់ទាញដៃទៅកំសត់ទោរមោហា ។
តំរួតវៃលៃយ៉ាន់ឆាប់ចាប់ឲ្យទាន់ នាំរួសរាន់បណ្ដើរទៅកាន់សាលា
ឲ្យទៅក្រមចោទសាកសួរគេទោសា ទន់ផ្ដន្ទាទូរកំហុសតាមបទល្មើស ។
ឯបុរសអស់សង្ឃឹមប្រឹងអធិប្បាយ កែដោះស្រាយប្រាយប្រាប់សព្វ
ឥតឲ្យឃ្លើស

ថាទំរង់វង់នោះណាខ្ញុនបានរើស ឥតបំផ្លើសពីពោះត្រីដែលខ្ញុនចាប់ ។
ពួកនាហ្មឺនមិនជឿទេរែបរហិត ចិញ្ចៀនសុទ្ធដិតក្លិនត្រីទើបប្រញាប់
ឲ្យរន្ទាន់ទៅកំសត់តាមសណ្ដាប់ នាំគ្នាឆាប់នាំទំរង់ថ្វាយក្សត្រក្សាន្ត ។
ព្រះទ្រង់ឫទ្ធិពិនិត្យជាក់ក្បាក់ព្រះអង្គ នេត្រក្រឡេងស្គាល់ទំរង់ដែលទ្រង់
បាន

បំពាក់ឲ្យសកុន្តលាស្រស់កល្យាណ មុនប្រាសប្រាណខានយល់គ្នានា
គ្រានោះ ។

ទ្រង់រំលឹកនឹកដល់កាលស្ងួនពន្ធក បានចូលមករកព្រះអង្គដោយត្រង់ស្មោះ
ទ្រង់យល់កក្ដ្រហាក់គ្មានស្គាល់គ្មានអាលោះ អាល័យសោះធ្វើតោះតើយ
ធ្វើយបំភ្លៃ ។

គួរអាណិតចិត្តវរលក្ខណ៍ស្ង័គ្រគាមមក គ្មានទឹកក្លុកធ្វើដូចហាក់អ្នកដទៃ
សមនាងនឹករព្យួកពិតគិតមមៃ ទើបចាកព្រៃលែចូលមករកស្វាមី ។

ចាំកាលស្ងួនបោកខ្លួនយំផ្ទួលសន្ធប់ ស្ដេចទឹកសព្វថប់ចិន្តាគិតប្រណី
ស្រក់ទឹកនេត្រហូរស្រោចស្រប់កន្ត្រួចក្រី គិតស្រស់ស្រីខ្ញាក់អួលខ្សឹក
ខ្សួលថា ។

“ នុះអណ្ដូគ្គប្រុងចូលមករកប្ដូរប្ដី កម្មពៀរអ្វីស្រីឲ្យបាត់ទំរង់ថ្វា
នាំឲ្យបង់ហ្មង់សៅចិត្តឥតមេត្តា ឲ្យកនិដ្ឋាផ្សាក្ដៅក្តួលពុំស្រួលប្ទេះ ។
បង់ស្រណោះកាលចួបចួនស្ងួនក្មង់ព្រៃ ប្អូនលកលៃរំពៃរេទៅបោចបេះ
អស់ផលផង់ឲ្យបង់ញុំាចាំប្រលេះ នៅសំណោះបេះសំណាលគួរស្នេហា ។
តែពីរនាក់រក្សរួមរិតមិត្តមូលមួយ គ្មានទុក្ខព្រួយជាក្សេមក្សាន្តបានសុខា
បង់បីបមថ្នមថ្នាក់ស្រីក្មង់គុម្ពផ្កា ក្លិនកនិដ្ឋាក្រអូបឆ្អិតជិតជាប់កាយ ។
សាច់ទ្រលន់ទន់ត្រជាក់គួរស្ងួនគេស្ងោះ គន់ស្រណោះសព្វសំឡេង
សូរសៀងសាយ

បែរខ្ទិចខ្ទក់អស់សំណើចសើចក្អាកក្អាយ ឥតមានណាយសប្បាយក្រៃ
ណាថ្ងៃបង់ ។

មកឥឡូវពៅទៅណាធីតាអូន ស្ងាត់សោះសូន្យឲ្យតែរៀមក្រៀមសៅហ្មង
រង់រលឹកទឹកមាសមិត្រគិតកន្ទ្វង់ តើនួនល្អងនាងទៅណាធីតាស្រី ។
ខ្យល់ផាត់ផាយផ្សាយក្លិនផ្កាពីកាស្រម ជាប់អារម្មណ៍នឹងក្លិនពៅនៅថ្មី ។
លុះគេចកៃប្រែផ្ងាករួមមេត្រី ពុំឃើញស្រីបានក្ដីក្ដៅសៅទុក ។

នៅសល់តែព្រះទំរង់រង់ថ្លាថ្លៃ   នឹងប្រែស្រ័យសួរការអ្វីពុំស្តីថា
ទីរលឹកនឹកគ្មានស្រាន្តបានសុខា   នាងទៅណាសកុន្តលាមាសបងអើយ ៗ
ស្តេចកើតទុក្ខបុកអួលណែនសែនចម្បែង   តែឯកឯងតែងវិយោគផោរ
ផោកខ្មើយ

ផាទោម្នេញពេញទោមនស្សមិនអស់ហើយ   គ្មានធូរស្បើយល្ហែល្ហើយ
ប្រាណស្រាន្តទុក្ខា ៗ

ទ្រង់រះរឡេគេរកពន្លកស្ងួន   ក្រែងប្អូនប្អូនខ្លួនពាលពៅនៅត្រង់ណា
អស់មន្ត្រីខ្វីឃាតរកពល់អាត្មា   ក្នុងព្រឹក្សាគ្មានពើបពះប្រទះសោះ ៗ
ទុស្សន្តរាជផាទុក្ខលន់ពន់ប្រមាណ   សោយពុំបានខាននាំងផ្ទំក្រំ
ក្រៀមក្រោះ

ខ្យល់រំភើយល្ហើយប៉ះអង្គសែនស្រណោះ   រងាលោះវែងអាល័យថ្ងៃ
ពន់ពេក ៗ

ពេលព្រះពាយរាយពពកបោកពពួន   ផំនោរដួនពួនជាក្ដុំអនេក
បាំងសូរ្យសែងក្លែងស្អុះស្អាប់អព្ទពេញមេឃ   គួររំរើករល់វិកល្បក់ក្នុងទុក្ខៗ
ប្រាង្គណ៍ប្រាសាទស្អាតទុកាសមាសស្អិនស្អៅ   ប្រែជាសៅខ្មៅងងឹតងិត
គ្របមុខ

គ្រឿងតន្ត្រីស្រីប្រាំរៀបដាក់ទុក   ទាំងទំនុកគ្មានរន្ទឹព្វសូរសាយ ៗ

អស់មហោស្រពសត្វកន្ទុងក៏ស្ងប់ស្ងាត់ ខ្លាចមហាក្សត្រចាត់សំ-
ពាក់ផ្កាកសប្បាយ

ស្ងប់សូន្យឈឹងរំពឹងដូចក្នុងព្រៃឆ្ងាយ ហាក់ជិនណាយរសាយ
ចិត្តឥតចេតនា ។

ឧត្តមហាក្សត្រគាត់ពុំបានរំខានក្រៃ នឹកតែថ្ងៃស្រមៃយល់តែគនិដ្ឋា
ទន្ទេញសាំចាំតែឈ្មោះសកុន្តលា! សកុន្តលា! សកុន្តលា! ទៅណាទៅ ។

ហោង-យ៉ាន់

( មានត )

| | |
|---|---|
| បើរន្ធមួយ ៗ ឬក្នុងលោក | មានតែផ្លូវលោក មួយឯកឯង |
| លោកនេះនឹងឆេះ ជាភ្លើងផ្សែង | ដោយចិត្តមនុស្សឯង ក្តៅពេកក្រៃ ។ |
| មានតែផ្លូវធម៌ មួយឯកឯង | លោកនឹងផ្លាស់ផ្លែង ក្លាយជាព្រៃ |
| ដោយមនុស្សគ្មានគិត ដល់ស៊ីវិល្ប | ខ្មែរយើងគួរលៃ ទាំងពីរផ្លូវ! |

ប.ព.

## បញ្ចតន្ត្រៈ

# រឿងក្អែកញី-ឈ្មោល បបក និងពស់

(តមក ពីលេខ ១-២—៣ ឆ្នាំ ១៩៥២)

---

បបកករដក:សួរទៀតថា: "ចុះរឿងនោះ តើដូចម្ដេច?" ។

បបកទមនក:និយាយរៀបរាប់ប្រាប់ថា :

### កថាទី៧

### រឿងក្អែកញីឈ្មោល បបក និងពស់

ក្នុងប្រទេសមួយ មានក្អែកញីឈ្មោលអាស្រ័យនៅលើដើមឈើមួយដើម ៗ ពស់វែកមួយអាស្រ័យនៅក្នុងព្រង់ឈើនោះដែរ ។ ក្នុងពេលដែលពងក្អែកញាស់ ពស់នោះតែងតែចេញមកពីព្រង់ វារលូនទៅចាប់កូនក្អែកស៊ីអស់តែពល់ដង ៗ ក្អែកញីឈ្មោលកើតទុក្ខក្រៀមក្រំពេកក៏បបួលញីឈ្មោលហើរទៅរកបបកជាសំឡាញ់ ដែលអាស្រ័យនៅគល់ឈើមួយផ្សេងទៀត ទៅដល់ហើយ និយាយសារស័ព្ទពីក្ដីទុក្ខក្ដៅក្រហាយឲ្យបបកស្ដាប់ ដើម្បីឲ្យជួយដោះទុក្ខធុរៈដ៏អាក្រក់នេះថា: "សំឡាញ់អើយ! កាលបើអន្តរាយបែបនេះកើតឡើង តើឲ្យយើងខ្ញុំធ្វើដូចម្ដេច បើពស់វែកចង្រៃនេះចេះតែចេញពីព្រង់លូនមកចាប់ស៊ីកូនយើងដូច្នេះ? ចូរសំឡាញ់ប្រាប់ឧបាយណាមួយជួយរក្សាយើងផង! ព្រោះថា:

២០៨ - (១) នរជនណា មានស្រែនៅក្បែរត្រើយទន្លេ មានប្រពន្ធមានសហាយ មានពស់កាចនៅក្នុងផ្ទះ ធ្វើដូចម្តេចហ្ន៎! នរជននោះនឹងធ្វើចិត្តឲ្យក្សេមក្សាន្តត្រជាក់បាន ? ។

ធ្វើដូចម្តេចហ្ន: ? ទីនោះជាទីលំនៅរបស់យើងជាពល់ថ្ងៃទៅហើយ មើលទៅសូម្បីតែជីវិតយើងក៏មិនទៀងទាត់ដែរ" ។ ចចកឆ្លើយថា "ព្រហ៊ើយកុំកើតទុក្ខបុកម្នេញអ្វីសំឡាញ់រឿងប៉ុណ្ណេះនេះ! អាពស់ល្មោភចង្រៃនេះ យើងនឹងសម្លាប់វាបានដោយឧបាយណាមួយមិនខានទេ, ព្រោះថា: -

២០៩ - ការឈ្នះសត្រូវដោយគ្រឿងអាវុធ មិនប្រសើរស្មើដោយការឈ្នះដោយឧបាយកលទេ អ្នកចេះឧបាយកល សូម្បីមានខ្លួនតូចក៏មនុស្សក្រៀវក្លាមិនដែលយកឈ្នះបានឡើយ ។

២១០ - កុក ស៊ីត្រីទាំងតូចទាំងធំទាំងមធ្យមដោយក្តីល្មោភ ត្រូវក្តាមកៀបកសម្លាប់ចោលបង់សៀត" ។

ក្អែកញីឈ្មោលសួរថា: "ចុះរឿងនោះ តើដូចម្តេច?" ។ ចចកនិយាយរឿងប្រាប់ថា :-

---

១ — បញ្ចតន្ត្រៈសេចក្តីប្រែជាភាសាបារាំងនៃលោកឡង់ស៊ីរូ មានគាថាលើសផ្លួនេះ ការនៅក្នុងផ្ទះដែលមានពស់កាចឈ្មោះថាស្លាប់ស្រេចឥតសង្ស័យឡើយ អ្នកណាមួយនៅក្នុងភូមិមានពស់កាច ជីវិតនៃអ្នកនោះមិនទៀងទាត់ទេ ។

## កថាទី៨

# រឿងកុក និងក្តាម

ក្នុងប្រទេសមួយ មានត្រពាំងមួយជាទីលំនៅនៃសត្វជលចរទាំងឡាយ ។ នៅក្បែរត្រពាំងនោះ មានកុកមួយអាស្រ័យនៅដែរ ។ កុកនោះចាស់ជរា មិនអាចរកចាប់ត្រីជាចំណីអាហារបានឡើយ ។ ថ្ងៃមួយ កុកនោះមានសេចក្ដីស្រេកឃ្លានខ្លាំងណាស់ ចុះទៅទំនៅឆ្នេរត្រពាំងនោះ ពុតធ្វើជាយំសោកសៅ មានទឹកភ្នែកហូរហៀរធ្លាក់មក ដោតដីមើលទៅឃើញហាក់ដូចជាដុំគល់ក្ទឹព្រោត វាឈរតែជើងម្ខាង ដាក់កខុនចុះសំកុកបំភាន់ត្រីល្ងង់ ៗ ឲ្យយល់ថាជាដើមផ្កាឈូក ។ កាលនោះ ក្តាមមួយ វារគេមៗមកមួយអន្ទើដោយសត្វជលចរនានាទាំងឡាយ ដើម្បីរកអាហារ ទៅឃើញកុកសំកុកនឹងខ្លួនដូចដើមឈូក កើតក្តីអាណិតអត់ទ្រាំមិនបានក៏ចូលទៅសួរកុកបោកប្រាសនោះថា: “ នុបងកុកអើយ ! ថ្ងៃនេះ ហេតុអ្វីក៏បានជាបងមិនរវះរវាមស្វែងរកចំណីអាហារ គិតតែយំសោកសៅសំរក់ទឹកភ្នែកមុខគួរឲ្យអាណិតម្ល៉េះ?” ។ កុកឆ្លើយដោយធ្វើពុតជាអ្នកកាន់សីលថា: ‘នុអ្នកអើយ! អ្នកទាំងឡាយសំគាល់ខ្ញុំដូច្នេះចំជាត្រូវណាស់ហើយ, ខ្ញុំជាសត្វស៊ីត្រី តែខ្ញុំលះបង់តណ្ហាគឺចំណង់ដែលចង់ស៊ីត្រីនោះអស់ហើយ ពេលនេះ ខ្ញុំត្រូវអត់អាហារឲ្យស្លាប់ចុះ អ្នកទាំងឡាយមើល! ខ្ញុំមិនស៊ីត្រីទេ សូម្បីត្រីហែលមកជិត ខ្ញុំក៏មិនចាប់ស៊ីដែរ” ។

ក្តាមបានស្តាប់ពាក្យបរិយាយកុកហើយ ក៏សួររកហេតុតទៅទៀតថា : “បងកុក! ហេតុដូចម្តេចក៏បានជាបងលះបង់ចំណង់ស៊ីត្រីដូច្នេះ?” ។ កុកឆ្លើយប្រាប់ថា: “អ្នកអើយ! ខ្ញុំកើតនៅក្បែរត្រពាំងនេះ ចំរើនធំឡើងក៏នៅក្បែរត្រពាំងនេះដែរ, ហេតុដែលនាំឲ្យលះបង់ចំណង់ស៊ីត្រីនោះ មកពីខ្ញុំគិតភ័យខ្លាំងណាស់ ព្រោះខ្ញុំបានដឹងប្រាកដថា ស្រុកនេះនឹងកើតទុរ្ភិក្សអត់ឃ្លានមិនមានអាហារបរិភោគ ភ្លៀងក៏មិនបង្អុរចុះមកក្នុងរវាង ១២ ឆ្នាំ ត្រពាំងបឹងបួនឹងហួតហែងចាប់តាំងពីថ្ងៃនេះតទៅ” ។ ក្តាមសួរដេញដោលតទៅទៀតថា: “ហេតុអ្វីក៏បានជាបងដឹងហេតុការណ៍អន្តរាយនេះ?” ។ កុកឆ្លើយដោយមុខក្រៀមក្រំថា: “រឿងនេះ ខ្ញុំបានដឹងតមកពីលោកហោរាគេទាយថា សនៃស្ចរ:(១) ភៅម:(២) នឹងសុក្រ:(៣) ដើរកាត់ចូលកដរថរោហិនី(៤) ។ លោកវរាហមិហិរ:(៥) ពោលថា:-

២១១ – បើកូនព្រះអាទិត្យ(៦) ដើរកាត់ចូលកដរថរោហិនីនៅក្នុងលោកនេះ ក្នុងកាលនោះ ព្រះឥន្ទ្រមិនបង្អុរភ្លៀងមកលើផែនដីនេះ អស់កំណត់ ១២ ឆ្នាំ ។

២១២ – កាលកដរថនៃរោហិនីបាក់បែកហើយ ផែនពសុធានេះ

---

១ – ផ្កាយព្រះសៅរ៍ ។ ២ – ផ្កាយព្រះអង្គារ ។ ៣ – ផ្កាយព្រះសុក្រ ។ ៤ ផ្កាយព្រះចន្ទ មានរថប្រកបដោយកង់ជារូប ។ ៥ – អ្នកហោរាសាស្ត្រមានល្បីឈ្មោះក្នុងសតវត្សទី៦ នៃ គ. ស. ។ ៦ – ផ្កាយព្រះសៅរ៍ ។

ត្រូវបំពេញព្រតកាបាល (១) ព្រោះទុកដូចជាត្រូវមានទោស ត្រូវពេញ ដើរដាសដោយផេះ ទីងថ្ពីងទាំងឡាយ ។

២១៣ (២) ប្រសិនបើកូនព្រះអាទិត្យ (៣) ព្រះរុធិរៈ (៤) ឬព្រះសសី (៥) បរកាត់កជរថនៃរោហិនីវិញនោះតើខ្ញុំត្រូវនិយាយថាដូចម្ដេច ? ខ្ញុំត្រូវនិយាយថាលោកមនុស្សទាំងមូលនេះ នឹងត្រូវវិនាសឥតសេសសល់ ដល់តិចឡើយនៅក្នុងសាគរឥតខ្ទឹមសារនេះ (៦) ។

ដោយហេតុដូចពោលមកនេះ ត្រពាំងនេះមានទឹកតិចស្រាប់ផង មុខជារីងឆាប់ ៗ កាលត្រពាំងនេះរីងរហូតហើយ បណ្ដាសត្វទាំង-ឡាយដែលអាស្រ័យនៅធ្លាប់បានរែកពាយសប្បាយ មុខជានឹងវិនាសអន្ដរាយអស់ដែរ ព្រោះតែខ្វះទឹកនេះឯង ។ បំណែកខាងខ្ញុំ ខ្ញុំមិនអាចទប់ទល់សេចក្ដីទុក្ខសោក ដែលបានទឹកឃើញការព្រាត់ប្រាសបងប្អូននៅចំពោះមុខយ៉ាងនេះឡើយ ព្រោះហេតុនោះហើយ បានជាខ្ញុំសុំអត់ដង្ហើមសម្លាប់ខ្លួនឯងដូច្នេះ ។ ឥឡូវនេះ សត្វជលចរទាំងឡាយ

---

១ — ការបំពេញព្រតព្រះឥសូរ គឺត្រូវប្រឡាក់ផេះនឹងពាក់សង្វា ឬ ខ្សែក្រវាត់ជាវិការៈនៃក្បាលមនុស្ស ។ ២ — បញ្ចតន្ត្រៈសេចក្ដីប្រែជាបារាំងនៃលោកឡង់ស៊ីរូ មានគាថាលើសដូចតទៅនេះ កាលបើព្រះចន្ទឋិតនៅចំពាក់កណ្ដាលរថនៃរោហិនី ទោះមនុស្សលោកនឹងឥតទីលំនៅ ហើយចេះតែដើរត្រាច់តាមអំពើចិត្ត ស៊ីសាច់កូនតូចៗ ហើយផឹកទឹកក្ដៅដែលកំដៅដោយព្រះអាទិត្យ ។ ៣ — មើលឧបលក្ខណៈលេខ ៦ នៃគាថាលេខ២១១ ។ ៤ — ផ្កាយព្រះអង្គារ ។ ៥- ផ្កាយព្រះចន្ទ ។ ៦ — តាមសេចក្ដីអ្នកហោរាសាស្ត្រឥណ្ឌានិយាយថា កាលណាបើផ្កាយទាំងអស់ ដើរទៅផិតរថនៃរោហិនី សកលលោកនេះនឹងវិនាសយ៉ាងធំ ។

បណ្ដាដែលនៅក្នុងត្រពាំងទឹកតិចផ្សេងៗ ទាំងប៉ុន្មាន កំពុងដឹកកូនជញ្ជូនទៅ របស់ខ្លួនចេញទៅរកបឹងធំៗ ដើម្បីអាស្រ័យនៅ សត្វដទៃទៀតដូចមករពិនទងក្ដាមក្រពើដំរីទឹកក៏កំពុងរត់ចេញដែរ តែសត្វជលចរដែលនៅក្នុងត្រពាំងនេះហាក់ដូចជាឥតមានព្រួយបារម្ភអ្វីសោះ នេះហើយជាដើមហេតុដែលនាំឲ្យខ្ញុំយំសោកសៅ ព្រោះថានៅទីនេះ កុំថាអ្វីឡើយ សូម្បីស្មៅតែមួយទងក៏ធន់ទ្រាំនឹងការរាំងភ្លៀងនេះមិនបានដែរ ។

កាលនោះ ក្ដាមបានស្ដាប់ដំណឹងសេចក្ដីថា មានភ័យមកគម្រាមយ៉ាងនេះហើយ ក៏លាកុកប្រញាប់ប្រញាល់រត់ចេញទៅប្រាប់ដំណឹងអាក្រក់នេះ ដល់សត្វជលចរទាំងឡាយ ដែលអាស្រ័យក្នុងត្រពាំងនោះ ។ ត្រីក្ដាម មករពិនទង អណ្ដើកទាំងឡាយ បានដឹងហើយ ក៏ភ័យតក់ស្លុតរន្ធត់រវល់តែគ្រប់គ្នា ទើបបបួលគ្នាចូលទៅសួរកុកដោយទឹកមុខក្រៀមក្រំថា: “បងកុកអើយ! យើងបានដឹងថាមានសេចក្ដីអន្តរាយនឹងកើតឡើង តើបងមានមធ្យោបាយណាមួយជួយយើងខ្ញុំបានឬទេ?” ។ កុកឆ្លើយក្ដាមថា: “បងប្អូនអើយ! នៅមិនឆ្ងាយពីទីនេះប៉ុន្មាន មានបឹងមួយធំ ពេញព្រៀបដោយទឹកថ្លាត្រជាក់ ដេរដាសពាសពេញដោយឈូក កមុទ ឧត្បល, ឯត្រពាំងនោះធំហើយមានឫទ្ធិអស្ចារ្យណាស់ បើទុកជាព្រះឥន្ទ្រម្ចាស់ភ្លៀង មិនបង្អុរភ្លៀងចុះមកអស់កាល ២៤ ឆ្នាំ ក៏មិនរីងដែរ ។ (មានត)

# មហាសន្និបាត ឆ្នាំ ១៩៥២

(តពីសៀវភៅលេខ ១ — ២ — ៣ ឆ្នាំ ១៩៥២)

## ១ — សុន្ទរកថាលោកអធិបតី

សូមជំរាបមហាសន្និបាត សូមជ្រាប ។

សមាគមមិត្តសាលាបាលីបានធ្វើដំណើរការ តាំងពីថ្ងៃ ១៤ មករា ១៩៥១ មកទល់នឹងថ្ងៃ ១៣ មករា ១៩៥២ បានលទ្ធផលដូចខាងក្រោម :

### ខាងព្រះពុទ្ធសាសនា

សមាគមមិត្តសាលាបាលីបានព្យាយាមរកតកម្មិកភាពខាងព្រះពុទ្ធ-សាសនាដោយបានធ្វើបុណ្យដូចតទៅនេះ :–

១) បុណ្យប្រគេនព្រហ្មទានចំពោះព្រះសង្ឃ ៨៨ អង្គដែលប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ពីថ្ងៃទី ២៥ កុម្ភៈ ១៩៥១ សមាគមនឹងតាំងពិធីបុណ្យនេះតាមលំដាប់តទៅមុខទៀត ដើម្បីញុំាងទឹកព្រះទ័យព្រះសង្ឃជានិស្សិតសាលាបាលីជាន់ខ្ពស់ឲ្យព្យាយាមរៀនសូត្រព្រះពុទ្ធសាសនាកើនតែមាំមួនឡើង ;

២) បានប្រគេនសម្ភារៈផ្សេងៗ មានសៀវភៅ ទឹកខ្មៅ ដងប៉ាកកា ជាដើម ពីថ្ងៃទី ២៣ ធ្នូ ១៩៥១ ចំពោះសាលាបាលីរង ១៤ វត្តក្នុង

ព្រះរាជធានី (ភ្នំពេញ) ចំណាយអស់ប្រាក់សមាគម ២០០០រ.០០ ។ ដោយសមាគមមានធនធានស្តួចស្តើងណាស់, មិនអាចនឹងប្រគេនគ្រឿងសម្ភារៈនោះ ចំពោះសាលាបាលីរងគ្រប់វត្តក្នុងព្រះរាជាណាចក្រទាំងមូលឬសាលាបាលីជាន់ខ្ពស់ ឬក៏សាលាធម្មវិន័យបាន, សមាគមសូមទានអភ័យទោសពីព្រះតេជព្រះគុណគ្រប់វត្តចំពោះកិច្ចទាំងនេះ តែសូមសង្ឃឹមទុកជាមុនថា ក្រុមអភិបាលថ្មីនឹងព្យាយាមឃោសនាពន្យល់ផ្សាយចំពោះព្រះសង្ឃ នឹងគ្រហស្ថដែលជាពុទ្ធមាមកជន អំពីសារប្រយោជន៍នៃសមាគម មានការបណ្តុះធម៌សាមគ្គីនៃមិត្តនឹងសិស្សសាលាបាលីឲ្យទៅជាកំលាំងមួយសម្រាប់រចនាព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿងក្នុងកម្ពុជរដ្ឋទាំងមូល ។ សាមគ្គីនេះដែលនឹងរឹងប៉ឹងទៅបានមកពីព្រះតេជព្រះគុណនឹងលោកអ្នកទាំងអស់ព្យាយាមអានលក្ខន្តិកៈនៃសមាគមឲ្យយល់ច្បាស់នូវវត្ថុបំណងរបស់នៃសមាគម ហើយជួយផ្សាយដោយបសាទសទ្ធាដ៏មុតមាំ, ជួយធនធានទ្រព្យសម្បត្តិ, ជួយរំលឹកដាស់តឿនដោយឧបាយដ៏ប្រពៃ, ជួយកំលាំង ប្រៀបដូចជាទូកមួយមានអ្នកកាច់ចង្កូត-អ្នកអុំ-អ្នកចំក្បាល ព្យាយាមអុំ-វៃ ឲ្យមានកំលាំងស្មើគ្នា ប្រឹងអុំ-វៃព្រមៗគ្នា ទើបទូកនោះមានដំណើរលឿនទៅកាន់ត្រើយគឺការសម្រេចទៅតាមវត្ថុបំណងនៃសមាគមនេះបាន ។ ការដែលអស់លោកអ្នក

ពុទ្ធបរិស័ទបានជួយសមាគមដោយចុះឈ្មោះជាសមាជិក ទាំងបបួលគ្នាឲ្យមកជួយធ្វើការក្នុងសមាគម បានឈ្មោះថា លោកអ្នកបានបំពេញកងការកុសលចំពោះព្រះពុទ្ធសាសនា ព្រោះថា :–

ជួយសមាគមមិត្តសាលាបាលីឈ្មោះថាជួយសាលាបាលីជាន់ខ្ពស់, ឈ្មោះថាជួយសាលាបាលីរង, ឈ្មោះថាជួយព្រះសង្ឃដែលសិក្សាព្រះពុទ្ធសាសនាឲ្យខំព្យាយាមរៀនធម៌វិន័យឲ្យបានមុតមាំទៅឡើងទៀត ដើម្បីញុំាងព្រះពុទ្ធសាសនាឲ្យឋិតនៅជាថេរវត្តកងមាតុភូមិរបស់យើងតទៅអនាគត ៗ

ព្រះពុទ្ធសាសនាដែលទាំងចំរើនរុងរឿងតទៅអនាគត មកពីអស់លោកអ្នកពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថ ប្រុសស្រីជួយឧបត្ថម្ភផង ដូចព្រះពុទ្ធដីកាថា ព្រះពុទ្ធសាសនាទាំងចំរើនឬ ទាំងវិនាសមកពីពុទ្ធ-បរិសទ្យ ៗ ព្រោះហេតុដូចនេះ, សូមលោកអ្នកកុំមើលបំណាំ, សូមស្មុះព្រួតដៃគ្នាសាងព្រះពុទ្ធសាសនាកុំបីប្រមាទ ៗ តទៅអនាគត បើសមាគមមានធនធានបរិបូណ៌ទាំងចាត់ចែងក្រៅពីករណីយកិច្ចខាងលើនេះ គឺ :–

១ – ចែកគ្រឿងសម្ភារៈ ចំពោះសាលាបាលីរង វត្តខាងខែត្រក្រៅ តាមចំនួនដែលគួរធ្វើបាន ;

២ – ថែកគ្រឿងសម្ភារៈ ចំពោះសាលាធម្មវិន័យក្នុងព្រះរាជធានី;

៣ – ថែកសៀវភៅធម៌ដល់និស្សិតទាំងនោះ;

៤ – ចាត់ព្រះសង្ឃចេញទៅសិក្សា ឯប្រទេសក្រៅមានលង្កាទ្វីប ជាដើម ។

វត្តបំណងខាងលើព្រមទាំងវត្ថុបំណងដទៃទៀត សឲ្យឃើញថា សមាគមមានឧត្តមគតិចង់ឲ្យប្រទេសកម្ពុជា សម្បូណ៌អ្នកប្រាជ្ញខាង ព្រះពុទ្ធសាសនាដើម្បីរក្សាគាំពារទីងអក្សរសាស្ត្រជាតិឲ្យឋិតថេរ ។

## ២ – ខាងអក្សរសាស្ត្រ

ព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រត្រូវឋិតនៅជាមួយគ្នា ព្រោះថា អក្សរសាស្ត្រ ជាមូលដ្ឋាននៃព្រះពុទ្ធសាសនា, បើព្រះពុទ្ធសាសនាលត់ អក្សរសាស្ត្រលាយ; អក្សរសាស្ត្រនឹងឋិតថេរបានមកពីវត្តអាពមជា ទីរក្សាទុកនូវអក្សរសាស្ត្រជាឃ្លាំងអក្សរសាស្ត្រ ដោយមានសាលាបាលី ជាន់ខ្ពស់នឹងពុទ្ធសាសនបណ្ឌិត្យជាឃ្លាំងធំ; ព្រោះហេតុនេះ សមាគម យើងបានផ្ដើមសាងបនានូវគណៈកម្មការជាច្រើន ដើម្បីនឹងបំពេញនូវ ឃ្លាំងធំ ខាងលើ ឲ្យបានចំរើននូវវត្តនវត្ថុ គឺអក្សរសាស្ត្រខ្មែរនឹងរចនា ជាតិខ្មែរឲ្យបានបោះពុម្ពសៀវភៅនិពន្ធរឿងផ្សេង ៗ ព្រមទាំងចម្រាញ់រក រាគ្និនគឺអ្នកប្រុនប្រែសប់ខាងសំដី ធ្វើសំដីនោះត្រូវមានរបៀបទៅតាមកាល សម័យ គឺ

( មានត )

# ពិធីបុណ្យព្រហ្មទាន

នៅថ្ងៃ ទី ៩ មីនា ១៩៥២

ដែលសមាគមមិត្តសាលាបាលីបានប្រគេនរង្វាន់ដល់សិស្សសាលាបាលីជាន់ខ្ពស់ ដែលប្រឡងជាប់សញ្ញាបត្រ ឆ្នាំ ១៩៥២ ។

( តពីសៀវភៅលេខ ១ — ២ — ៣ ឆ្នាំ ១៩៥២ )

---

## សុន្ទរកថានៃលោកអធិបតី

សូត្រមុនពេលប្រគេនរង្វាន់

ការរៀបរាប់មកប៉ុណ្ណេះ សឲ្យឃើញថាព្រះរាជានៃកម្ពុជរដ្ឋយើង ទ្រង់តែងមានព្រះរាជហឫទ័យជ្រះថ្លាជួយឧបត្ថម្ភគាំទ្រព្រះពុទ្ធសាសនា និងអក្សរសាស្ត្រជាតិជាដរាបរៀងរាបមក ដោយកិច្ចដ៏ប្រសើរវិសេសផ្សេងៗ មានការទ្រង់ចេញសាងព្រះផ្នួស និងការលើកដំកើងប្រមូលអ្នកប្រាជ្ញមកនៅជុំព្រះអង្គ ដោយព្រះរាជទានងារស័ក្តិនិងរង្វាន់ផ្សេងៗ ព្រមទាំងទ្រង់ព្យាយាមនិពន្ធក្បួនច្បាប់និងរឿងរ៉ាវជាច្រើន ទុកជាព្រះកេរ្តិ៍ស្នាព្រះហស្តជាអាទិ៍ ហើយទ្រង់តាំងព្រះអង្គជាទិដ្ឋានុគតិដ៏ឧត្តុង្គឧត្តមដល់ប្រជានុរាស្ត្ររបស់ព្រះអង្គ, ទើបអរិយធម៌ខ្មែរនិងវប្បធម៌ខ្មែរអាចចំលុះចំលាយនូវឧបសគ្គទាំងឡាយ ហើយយកជ័យជំនះលើកាលវេលា ដែលជាមេបំផ្លាញយ៉ាងធំមួយ ឲ្យបាននៅគង់ទ្រង់រហូតមកដល់សម័យនេះ ។

ឯវិធីចែកព្រហ្មទានក្នុងវេលានេះ ពុំមែនជារង្វាន់សម្រាប់តែសិស្ស ដែលរៀនពូកែ ដូចគេតែងធ្វើក្នុងសាលាដទៃនោះទេ ហើយពុំមែនជា

រង្វាន់សម្រាប់លើកទឹកចិត្ត ឲ្យសិស្សទាំងឡាយខំប្រឹងស្វាធ្យាយរៀនសូត្រឲ្យបានជាប់សញ្ញាប័ត្រឡើយ ព្រោះថាទោះបីគ្មានការចែករង្វាន់ដូច្នេះ ក៏គង់សិស្សទាំងឡាយនៅតែខំប្រឹងឲ្យបានសញ្ញាប័ត្រ ដែលជាវត្ថុបំណងនៃការសិក្សារបស់លោកដែរ ហើយសញ្ញាប័ត្រនោះជារង្វាន់ដ៏ប្រសើរក្រៃលែងនៃសិស្សគ្រប់រូប ជាការបញ្ជាក់ប្រច័ក្សចែងនូវផលសម្រេចនៃការខំប្រឹងប្រែងខ្វាប់ខ្វួនអស់រយៈកាលចំនួន ៤ ឆ្នាំ ៗ តែប្រដាប់ដែលផ្គូរផ្គងចំពោះសិស្សជាប់លេខខ្ពស់មានចំនួនច្រើន មានដំឡៃច្រើនជាងសិស្សជាប់លេខក្រោមៗ ជាលំដាប់, ត្រង់នេះ ជាការក្រើនរំលឹកសិស្សទាំងពួងឲ្យខំរៀនសូត្រឲ្យបានស្ទាត់ជំនាញ ឲ្យបានជាប់លេខជាន់ខ្ពស់ពុំមែនឲ្យខំប្រណាំងប្រជែងដើម្បីឈ្នះគេឈ្នះឯងដោយចំពោះនោះទេ ព្រោះការតាំងចិត្តបែបនេះអាចបណ្ដាលឲ្យកើតទោមនស្សទឹងឥស្សាឈ្នា-ទីសចំពោះសិស្សដែលឈ្នះខ្លួនវិញក៏មាន គឺចង់ឲ្យសិស្សទាំងឡាយខំយកឈ្នះចំពោះខ្លួនឯង មានឆន្ទៈដ៏ខ្ជាំងក្លា ដើម្បីបំពេញកិច្ចការរៀនសូត្រឲ្យបានប្រសើរវិសេសឡើងជាដរាប, ថ្ងៃនេះ ខំឲ្យបានគ្រាន់ជាងថ្ងៃម្សិលថ្ងៃស្អែកឲ្យបានគ្រាន់ជាងថ្ងៃនេះ តែដូច្នេះរៀងរាល់ថ្ងៃ រៀងរាល់-អាទិត្យ រៀងរាល់ខែ មិនស្លុតចិត្តថយក្រោយ ឬនៅក្រិនតែមួយកន្លែងចង់តែពីលូតចេញទៅមុខ លឿនទៅមុខជាលំដាប់ នេះហើយជាអគ្គការនៃវឌ្ឍនធម៌ល្អ ជាឧត្តមគតិដ៏ប្រពៃ ទឹងនាំយើងរាល់គ្នាទៅកាន់សេចក្ដីចំរើនបានដោយពិតប្រាកដ ។

តែបំណងសំខាន់នៃការចែកព្រហ្មទាន  ទៅចំពោះព្រះភ័ក្ត្រព្រះករុណាជាម្ចាស់ជីវិតលើត្បូង  ដែលបានស្តេចយាងមកជាព្រះរាជាធិបតីញ៉ាំងពិធីបុណ្យឲ្យប្រកបដោយមង្គលសួស្តីជ៏រុងរឿងនេះ  មានន័យ ជ្រាលជ្រៅផងសេចក្ដីដូចបានពោលមកពីខាងដើមទៅទៀត  គឺជាការគោរពដ៏ឧត្តុង្គឧត្តមថ្លៃថ្លា  ចំពោះបំណះវិជ្ជាដែលសិស្សទាំងឡាយបានបំពេញមកហើយ  ហើយដែលមានសញ្ញាប័ត្រ  ជាគ្រឿងបញ្ជាក់ថាសិស្សទាំងនេះហើយជាអ្នកដឹកនាំយើងរាល់គ្នាទៅថ្ងៃមុខ  ឲ្យដើរតាមគន្លងដែលប្រាសចាកទោសទាំងក្នុងលោកិយ  ទាំងក្នុងបរលោក  ជាពន្លឺត្រោលបំភ្លឺផ្លូវវឌ្ឍនធម៌  និងអរិយធម៌ពិតប្រាកដដល់យើង,  សិស្សទាំងនេះហើយជាស្រែបុណ្យដ៏ប្រពៃនៃយើងទាំងអស់គ្នា  ជាប្រភពនៃគតិបណ្ឌិត  ដែលអាចញ៉ាំងចិត្តរបស់យើងឲ្យត្រជាក់ឲ្យស្ងប់ស្ងាត់  ក្នុងកណ្ដាលលោកដែលកំពុងឆេះ  ដោយភ្លើងលោភៈ ទោសៈ មោហៈ នេះ ៗ  គឺការគោរពចំពោះគុណសម្បត្តិទាំងនេះហើយ  ដែលដឹកនាំយើងឲ្យចាត់ចែងធ្វើពិធីនេះ  ដើម្បីសំដែងសេចក្ដីត្រេកអរចំពោះបណ្ឌិតជាតិដែលសិស្សទាំងនេះហើយជាអ្នកទ្រទ្រង់ ៗ

ម្យ៉ាងទៀត  ការធ្វើពិធីនេះ  ក៏ចាត់ជាសេចក្ដីសុខវិសេសមួយព្រោះជាពិធីដែលញ៉ាំងទាយកឲ្យភ្លេចការដណ្ដើមយកតែម្នាក់ឯង ឲ្យភ្លេចការប្រណាំងប្រជែងគ្នាក្នុងការទទួល  និងក្នុងការតាមទារប្រយោជន៍ហើយ

ឲ្យបានតាំងខ្លួនទៅជាអ្នកឲ្យ ទៅជាអ្នកបរិច្ចាគដោយសេចក្ដីជ្រះថ្លាចំពោះឧត្ដមគតិដ៏ខ្ពង់ខ្ពស់ គឺព្រះធម៌ដែលសិស្សទាំងឡាយជាអ្នកទ្រទ្រង់ ។ គ្រាន់តែក្រឡេកឃើញព្រហ្មទានដែលខ្ចប់ ដោយក្រដាសពណ៌ក្រហមលឿង នឹងសក្ដីចិញ្ចែន ដំរៀបជាប់ៗគ្នាជារបៀបរៀបរយល្អ ក៏អាចឲ្យកើតបីតិសោមនស្សរីករាយយ៉ាងក្រៃលែង នឹងឲ្យត្រជាក់ចិត្តថ្លើមតាំងពីពេលនេះដរាបដល់ពេលវិលត្រឡប់ទៅកាន់ទីលំនៅរៀងៗខ្លួនវិញរហូតដល់ទៅពេលទីបំផុតដែលយើងនឹងចែកស្ថានចូលទៅកាន់បរលោកនាយទៀតផង ព្រោះកញ្ចប់ព្រហ្មទាននេះឯងហើយជាបុញ្ញនិធិរបស់យើងក្នុងលោកខាងមុខ ។

តែព្រហ្មទានដែលសមាគមអាចប្រមូលបានមក ដ៏ច្រើនដល់ម្ល៉េះ ដោយអាស្រ័យព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជហឫទ័យស្មោះស្ម័គ្រប្រកបដោយព្រះរាជសទ្ធាដ៏លើសលុបចំពោះព្រះពុទ្ធសាសនា បានព្រះរាជទានព្រះរាជទ្រព្យផ្ទាល់ព្រះអង្គចំណាយក្នុងកល្យាណកិច្ចនេះ មួយអន្លើដោយសម្ដេច, ទ្រង់, ឯកឧត្ដម, នូវព្រះតេជព្រះគុណ, នឹងអស់លោកអ្នកពុទ្ធបរិស័ទទាំងអស់ ដែលបានជួយជ្រោមជ្រែងផ្ដល់ទេយ្យវត្ថុក្នុងការកុសលនេះ ដោយកំឡាំងសទ្ធាដ៏ខ្លាំងក្លាទៀតផង ។

ដូច្នេះ, គង់ទីបំផុតនេះ សមាគមមិត្តសាលាបាលី សូមថ្វាយអំណរព្រះគុណដ៏លើសលុប ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសូមសំដែងសេចក្ដីអរគុណយ៉ាងក្រៃលែង ចំពោះសម្ដេច, ទ្រង់ ឯកឧត្ដម ព្រះតេជព្រះគុណនូវអស់លោកអ្នកទាំងឡាយ ព្រមទាំងសូមថ្វាយព្រះរាជកុសល ដែលកើតអំពីការកុសលដ៏ឧឡារិកនេះ និងសូមប្រសិទ្ធិពរជ័យថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គគង់នៅជាសុខក្សេមក្សាន្តសំរាន្តព្រះរាជហឫទ័យ គង់ព្រះសិរីរាជសម្បត្តិប្រកបដោយព្រះរាជសួស្ដីជ័យមង្គលគ្រប់ប្រការ មួយអន្លើដោយព្រះរាជវង្សានុវង្សអស់កាលដ៏យូរលង់តទៅ, ទាំងសម្ដេច, ទ្រង់, ឯកឧត្ដម, ព្រះតេជព្រះគុណ និងអស់លោកអ្នកជាពុទ្ធមាមកជនទាំងឡាយ ក៏សូមគុណានុភាពនៃកល្យាណកិច្ច គឺបុណ្យព្រហ្មទាននេះ ជួយទ្រទ្រង់ឲ្យបានសមប្រកបដោយសេចក្ដីសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតតាំងពីពេលនេះ ដរាបអស់កាលជាអង្វែងតទៅ ។

## សុន្ទរកថា

### នៃលោកបាងហ្វាងសាលាបាលីជាន់ខ្ពស់

សូមថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិត

សូមថ្វាយបង្គំសម្ដេច

សូមថ្វាយព្រះពរ, ចំរើនពរ, ចំពោះទ្រង់, ឯកឧត្ដម, ព្រះតេជព្រះគុណ និងអស់លោក-អ្នកទាំងឡាយ

អម្បាញ់មិញនេះ លោកអធិបតីនៃសមាគមមិត្តសាលាបាលី បានថ្លែងសេចក្ដីថ្វាយព្រះករុណាជាអម្ចាស់ជីវិតរួចហើយ អំពីកិច្ចការដ៏ប្រសើរដែលសមាគមបានធ្វើ ចំពោះសាលាបាលីជាន់ខ្ពស់ ដែលជាគ្រឹះស្ថានសម្រាប់សិក្សាវិជ្ជាផ្នែកមួយក្នុងព្រះពុទ្ធសាសនា គួរឲ្យពុទ្ធសាសនិកទាំងឡាយ មានសេចក្ដីពេញចិត្តយ៉ាងច្រើន ។

ឥឡូវនេះ, ក្នុងនាមនៃសាលាបាលីជាន់ខ្ពស់ អាត្មាភាពសូមសំដែងសេចក្ដីរីករាយដ៏លើសលុប ដោយគោរពចំពោះព្រះករុណាជាអម្ចាស់ជីវិត ដែលទ្រង់ស្ដេចមកជាព្រះរាជាធិបតីក្នុងពិធីបុណ្យចែកព្រហ្មទាន ដែលជាបុណ្យពិសេសមួយ អាចជួយអប់រំគម្ពាំងការសិក្សាព្រះពុទ្ធសាសនា ក្នុងសាលានេះជាបុណ្យនាំឲ្យសាលាបាលីជាន់ខ្ពស់ មានកិត្តិយសដ៏ប្រសើរ ជាសុភនិមិត្តក្នុងដំណើរទៅអនាគតរបស់សាលានេះផងទៀត ។

ម្យ៉ាងទៀត សាលាបាលីជាន់ខ្ពស់មានអំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលី ដែលបាននាំផ្ដើមធ្វើទូរព្រហ្មទាន គឺការចែករង្វាន់នេះ ដែលជាកិច្ចគំរិញជនទាំងឡាយគប្បីសរសើរ ព្រោះក្នុងរយៈកាល ៣៧ ឆ្នាំ ដែលជាអាយុរបស់សាលានេះ, ពិធីចែករង្វាន់ដល់សិស្សដែលប្រឡងជាប់ចេញពីសាលានេះ ទើបទឹងមានត្រឹម ៤ ដងប៉ុណ្ណោះ គឺកាលពីក្នុង គ. ស. ១៩៤២ មានពិធីចែករង្វាន់ ១ ដង

ដោយសារតុំទិ្ធកសមាគមកម្ពុជរដ្ឋ ។ ពិធីចែករង្វាន់លើកទី ២ ក្នុង គ.ស.១៩៥០ លើកទី ៣ ក្នុង គ.ស ១៩៥១ និងលើកទី ៤ គឺក្នុងគ្រានេះ មានដោយសារការចាត់ចែងរបស់សមាគមមិត្តសាលាបាលី ។

ការដែលសមាគមនេះ បានបំពេញកិច្ចប្រសើរនេះជាហេតុនាំឲ្យកើតផលប្រយោជន៍ច្រើនយ៉ាង គឺ :

១ – អាចលើកតម្លៃនៃការរៀនសូត្រក្នុងសាលានេះ ឲ្យប្រព្រឹត្តទៅក្នុងអនាគតដោយសុវត្ថិភាព ;

២ – អាចលើកទឹកចិត្តរបស់សិស្ស ដែលទើបនឹងប្រឡងជាប់ឲ្យមានបីតិប្រាមោជ្ជជាបច្ច័យនាំឲ្យសិស្សទាំងនោះមាននយោគតិ ស្ទុះទៅរកបំណះវិជ្ជាឲ្យបានកើនចម្រើនតទៅទៀត ;

៣ – សិស្សក្នុងសាលានេះគ្រប់ថ្នាក់ក្នុងបច្ចុប្បន្ននឹងក្នុងអនាគតនឹងខំប្រឹងសង្វាតរៀនសូត្រ ដោយពុំមានធ្វេសប្រហែសដោយហេតុមានជំនឿថាការរៀនសូត្រក្នុងសាលានេះ នាំឲ្យពុទ្ធបរិស័ទទាំងឡាយពេញចិត្តជ្រះថ្លាអបអរសាទរ ដោយសំគាល់ថាការសិក្សាក្នុងសាលានេះជាកម្លាំង ១ ផ្នែកអាចដឹកនាំសាធារណជនឲ្យបែរមុខទៅរកសីលធម៌, វិជ្ជាធម៌ និងការប្រឹងធម៌ដោយលំដាប់ ;

(មានត)

ទស្សនាវដ្ដីនេះ ល្អឥតក្ចឹង

ដោយផ្សាយដំណឹង ជា ២ ផ្នែក:

១- ពុទ្ធសាសនា យ៉ាងល្អឯក:

២- ខាងចំណែក អក្សរសាស្ត្រ ។

លោកអ្នកបើបាន អានសិក្សា
មេត្តាកុំភ្លេច ជួយប្រកាស
ប្រាប់គេឲ្យជាវ ច្រើនដេរដាស
ជួយអក្សរសាស្ត្រ, ពុទ្ធសាសនា ។

ថ្លៃផ្សាយប្រចាំឆ្នាំ :

ក្នុងកម្ពុជរដ្ឋ .... ១២០៛,០០

ក្រៅកម្ពុជរដ្ឋ.... ១៥០ ,០០


...... ភ្នំពេញ ......

. រោងពុម្ពព្រះបរមរាជវាំង .

...... ១៩៥២ ......